# អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប)

*"ការអភិវឌ្ឍមនុស្សប្រកបដោយសេចក្ដីថ្លៃថ្នូរ"*




សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម

P.O Box ១៦២១ ភ្នំពេញ កម្ពុជា

០៤២-៩៤១-៤៨១ / ០៤២-៩៤១-៩១៨ kape@kapekh.org

www.kapekh.org t.me/kapemedia

www.facebook.com/kapeaction

www.youtube.com/@KAPECambodia

www.linkedin.com/in/kapecambodia

www.twitter.com/KAPECambodia


**សម្គាល់:** សូមមើលអំពីផលជះរបស់គម្រោងនីមួយៗនៅលើគេហទំព័រអង្គការ ខេប។ លោកអ្នកអាចអានករណីសិក្សាបន្ថែមតាមរយៈតំណភ្ជាប់:
*http://kapekh.org/en/what-we-do/4/?pro_id=20*

# របាយការណ៍ប្រចាំឆ្នាំ ២០២៣


ចេញផ្សាយនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤

(អង្គការ ខេប បានចុះបញ្ជីនៅក្រសួងមហាផ្ទៃក្នុងឆ្នាំ ១៩៩៩ និងចុះបញ្ជីជាថ្មីនៅដើមឆ្នាំ២០១៩)

# សារប្រធានក្រុមប្រឹក្សាភិបាល

ក្នុងនាមក្រុមប្រឹក្សាភិបាលអង្គការ ខេប ខ្ញុំមានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំង និងរំភើបនៅលើរបាយការណ៍ប្រចាំឆ្នាំ២០២៣ ដែលចាប់ផ្ដើមពីខែមករា ដល់ចុងបញ្ចប់ខែធ្នូ ឆ្នាំ២០២៣នេះ។ នៅក្នុងឆ្នាំបច្ចុប្បន្ននេះគឺជាឆ្នាំដែលល្អមួយទៀតសម្រាប់អង្គការ ដែលមានការអភិវឌ្ឍកម្មវិធីខ្លាំងក្លា ហិរញ្ញវត្ថុមានស្ថិរភាព និងទំនាក់ទំនងរឹងមាំជាមួយរដ្ឋាភិបាល។ នៅក្នុងព្រឹត្តិការណ៍ដ៏សំខាន់មួយគឺអង្គការ ខេប បានរៀបចំសន្និសីទអន្តរជាតិលើកដំបូងនៅក្នុងឆ្នាំ២០២៣ ដែលជាព្រឹត្តិការណ៍មួយដ៏មានសារៈសំខាន់ក្នុងការជួយបង្កើតកេរ្តិ៍ឈ្មោះរបស់អង្គការនៅខាងក្រៅប្រទេសកម្ពុជា ក៏ដូចជានៅក្នុងប្រទេសផងដែរ។ ក្រុមប្រឹក្សាភិបាលសូមអបអរសាទរដល់ ខេប ដែលបានដំណើរការការងារដ៏រឹងមាំនៅគ្រប់ទិដ្ឋភាពទាំងអស់ ហើយយើងទន្ទឹងរង់ចាំការបន្តជោគជ័យនៅក្នុងឆ្នាំខាងមុខទៀត។



**ប្រធានក្រុមប្រឹក្សាភិបាល**

**ហ៊ាង គុយ**

ខេបគឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ ឧត្តមសិក្សា និងថ្នាក់បរិញ្ញាបត្រអប់រំជាន់ខ្ពស់ ឯកទេសប្រឹក្សាគរុកោសល្យ។ ចំនួនអ្នកទទួលផលផ្ទាល់មានជាង ១៦០ ០០០នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ ដែលបង្រៀននៅតាមសាលារៀនចំនួនជាង១៦៥ ក្នុងរាជធានី/ខេត្តចំនួន១៨។



## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈការទទួលបានការអប់រំល្អ។

## បេសកកម្ម

បេសកកម្មរបស់ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

## គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី/ច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

# សារនាយកប្រតិបត្តិ

ខេបមានសេចក្តីសោមនស្សរីករាយចែករំលែករបាយការណ៍ប្រចាំឆ្នាំសារពើពន្ធ ២០២៣ ដែលមានព្រឹត្តិការណ៍ និងសកម្មភាពសំខាន់ៗជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់។ នៅចុងបញ្ចប់ឆ្នាំនេះ អង្គការ ខេប មានគម្រោងចំនួន២១ ឬតិចជាងឆ្នាំទៅចំនួន១គម្រោង ប៉ុន្តែខេបនៅតែជាអង្គការមានស្ថិរភាពខ្ពស់ជាប្រវត្តិសាស្ត្រ។ ជាក់ស្តែង គម្រោងមួយចំនួន ដូចជាគម្រោងកុមារកម្ពុជារីករាយ បានចាប់ផ្តើមពង្រីកបន្ថែមសាលារៀនថ្មីចំនួន១៤ទៀតទៅក្នុងកម្មវិធី ដែលនាំឱ្យសាលារៀនបានគាំទ្រដោយគម្រោងមានចំនួនដល់ ៥៥សាលា ហើយគម្រោងនឹងមានផែនការពង្រីកចំនួន១៥បន្ថែមទៀតនៅឆ្នាំ២០២៤ខាងមុខនេះ។ គម្រោងសាលារៀនជំនាន់ថ្មី ក៏បានពង្រីកបន្ថែមសាលារៀនថ្មីចំនួន២ផងដែរបើធៀបនឹងកម្មវិធីនាពេលបច្ចុប្បន្ន។ ដូច្នេះ ទោះបីជាមានកម្មវិធីថយចុះបន្តិចក៏ដោយ ក៏ជំនួយហិរញ្ញប្បទានកើនឡើងដល់កម្រិតខ្ពស់ថ្មីមួយប្រមាណជា៥លានដុល្លារអាមេរិកក្នុងឆ្នាំ២០២៣ ដែលជាកម្រិតហិរញ្ញវត្ថុច្រើនបំផុតមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្ររបស់អង្គការ ខេប។

និន្នាការសំខាន់មួយនៃកម្មវិធីអង្គការ ខេប នៅឆ្នាំនេះគឺការពង្រីកទៅកាន់ការអប់រំឌីជីថលយ៉ាងឆាប់រហ័ស ស្របតាមផែនការយុទ្ធសាស្ត្រថ្មី៥ឆ្នាំរបស់ខ្លួន។ នៅឆ្នាំនេះ ខេបបានស្នងមតិអំពីការអប់រំឌីជីថលដ៏ធំមួយជាមួយដៃគូអង្គការឆាលហ្វានកម្ពុជា ហើយបានចាប់ផ្តើមអនុវត្តកម្មវិធីអប់រំឌីជីថលថ្មីចំនួន៣ដែលមានជំនួយហិរញ្ញប្បទានពីម្ចាស់ជំនួយច្រើនគ្នា រួមមាន៖ ក្រុមហ៊ុនមេតា មូលនិធិ Google-ASEAN និងអង្គការយូណេស្កូ ខណៈដែលបច្ចុប្បន្នមានកម្មវិធីអប់រំឌីជីថលចំនួន២បន្ថែមទៀតកំពុងស្ថិតក្នុងការរៀបចំផែនការផ្តល់ជំនួយហិរញ្ញប្បទានពីអង្គការឆាលហ្វានកូរ៉េ និងគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច Lichtenstein (LED)។ កម្មវិធីថ្មីទាំងនេះគ្រោងនឹងចាប់ផ្តើមប្រតិបត្តិនៅឆ្នាំ២០២៤។ ខេបក៏កំពុងទាក់ទងដៃគូឯកជនសំខាន់ៗផងដែរនៅក្នុងវិស័យឌីជីថល ដូចជា Everybody Counts (UK) និង Pearson (USA) ដើម្បីធ្វើសមាហរណកម្មការសិក្សាអប់រំដែលទទួលស្គាល់ជាសកលនៅក្នុងកម្មវិធីរបស់ខ្លួន។

និន្នាការដ៏សំខាន់មួយទៀតនៅក្នុងកម្មវិធីឆ្នាំ២០២៣ ទាក់ទងនឹងការបង្កើនការយកចិត្តទុកដាក់លើការអប់រំបំណិនជីវិតជាមួយដៃគូជាយុទ្ធសាស្ត្រដ៏សំខាន់គឺមូលនិធិរបស់ក្រុមហ៊ុន Gap ដើម្បីលើកកម្ពស់កម្មវិធីសិក្សាការអប់រំបំណិនជីវិតសម្រាប់កុមារី ដែលទទួលស្គាល់ជាសាកល (P.A.C.E.) ក៏ដូចជាភាពជាដៃគូថ្មីជាមួយ UNICEF ដែលខេបកំពុងអភិវឌ្ឍន៍ការសាកល្បងបំណិនជីវិតមូលដ្ឋាន និងសៀវភៅណែនាំអំពីការអប់រំបំណិនជីវិតថ្មី ដែលលើកកម្ពស់ការទទួលបានជំនាញទន់។

ក្នុងអំឡុងឆ្នាំ២០២៣ ខេបបានរៀបចំសន្និសីទអន្តរជាតិលើកដំបូងរបស់ខ្លួនដែលមានឈ្មោះថា សន្និសីទអន្តរជាតិស្តីពីសាលារៀនស្វយ័ត ដែលជាគន្លឹះកំណែទម្រង់វិស័យអប់រំ។ អ្នកសិក្សា អ្នកអនុវត្តគម្រោង មន្ត្រីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ជាង១០០នាក់បានចូលរួមអង្គសន្និសីទនេះ ដែលបានប្រារព្ធធ្វើឡើងនៅសណ្ឋាគារ សុខា ភ្នំពេញ។



សន្និសីទនេះគឺជាជំហានយុទ្ធសាស្ត្រ ដ៏សំខាន់មួយឆ្ពោះទៅរកការលើកកម្ពស់ប្រវត្តិសាលារៀនជំនាន់ថ្មីជាគំរូក្នុងតំបន់ ដែលអាចជួយចម្លងការជួយប្រើប្រាស់សាលារៀនស្វយ័តទៅកាន់បណ្តាប្រទេសដទៃទៀត ដូចជា ប្រទេសឡាវ ថៃ និងបង់ក្លាដែស។

ខេបក៏សម្រេចបាននូវរបកគំហើញសំខាន់ៗមួយចំនួនតាមរយៈការបោះពុម្ពសៀវភៅណែនាំដំបូងរបស់កម្ពុជាស្តីពីវិធីសាស្ត្រសិក្សាបែបគម្រោង ដែលបច្ចុប្បន្ននេះ វាជាយុទ្ធសាស្ត្រគរុកោសល្យដ៏សំខាន់របស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តសៀវភៅណែនាំ និងគាំទ្រដល់ដំណើរការថ្នាក់ជាតិ ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយ និងការអនុវត្តរបស់ ខ្លួន។ ខេបបានបន្តធ្វើការផ្លាស់ប្តូរពីម្ចាស់ជំនួយទ្វេភាគី និងពហុភាគីបន្តិចម្តងៗឆ្ពោះទៅរកមូលនិធិឯកជន ម្ចាស់ជំនួយសាជីវកម្ម និងរាជរដ្ឋាភិបាលកម្ពុជា។

ក្នុងឆ្នាំ២០២៣ ខេបមានស្ថាប័នម្ចាស់ជំនួយចំនួន១៥ ដែលក្នុងនោះមានចំនួនតែ៥ប៉ុណ្ណោះជាទ្វេភាគី ឬពហុភាគី។ ម្យ៉ាងវិញទៀត ចំនួនថវិកាតិចជាង២០% នៃប្រាក់ចំណូលគឺបានមកពីទ្វេភាគី/ពហុភាគី បើប្រៀបធៀបទៅនឹងថវិកា៨០%ក្នុងទសវត្សរ៍ចុងក្រោយនេះ។ ការផ្លាស់ប្តូរនេះ បានជួយធ្វើឱ្យខេបមានសិទ្ធិសេរីភាពកាន់តែច្រើនក្នុងការអភិវឌ្ឍន៍កម្មវិធី ជៀសវាងបាននូវការដឹកនាំមុខពីម្ចាស់ជំនួយ និងកាត់បន្ថយសម្ពាធលើការគ្រប់គ្រង គេចផុតពីការទាមទារនៃការិយាល័យធិបតេយ្យនៃម្ចាស់ជំនួយធំៗ។

ខេបសូមថ្លែងអំណរគុណជាថ្មីម្តងទៀតចំពោះដៃគូ និងអ្នកពាក់ព័ន្ធទាំងអស់សម្រាប់ការគាំទ្ររបស់ពួកគេក្នុងអំឡុងឆ្នាំ២០២៣កន្លងមក ហើយយើងទន្ទឹងរង់ចាំធ្វើការរួមគ្នាដើម្បីសម្រេចបាននូវផលវិជ្ជមានបន្ថែមទៀតនៅឆ្នាំថ្មីខាងមុខនេះ៕

នាយកប្រតិបត្តិ

KAMPUCHEA ACTION TO PROMOTE EDUCATION

សៅ វណ្ណា



# មាតិកា


សារប្រធានក្រុមប្រឹក្សាភិបាល ..... ២
សារនាយកប្រតិបត្តិ ..... ៣
មាតិកា ..... ៤
សេចក្តីសង្ខេប ..... ៥-៦
ការឆ្លុះបញ្ចាំងទៅថ្ងៃអនាគត ..... ៦
ព័ត៌មានសំខាន់ៗ និងព្រឹត្តិការណ៍អន្តរជាតិ ..... ៧-១៣
ធីធីអូ អ៊ីមផត អិចផត ឯ.ក ..... ១៤
ខេបប្រតិបត្តិបច្ចេកទេសលើកម្មវិធីជាផ្នែកៗ ..... ១៥

- គម្រោង សាលារៀនជំនាន់ថ្មី **(NGS)** ..... ១៦-១៧
- មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី **(NGPRC)** ..... ១៨-១៩
- គម្រោង កុមារកម្ពុជារីករាយ **(HCC)** ..... ២០-២១
- គម្រោង លើកកម្ពស់លទ្ធភាពជំនាញការងារ និងការធ្វើចំណាកស្រុកប្រកបដោយប្រសិទ្ធភាពដល់យុវជនកម្ពុជា **(BMZ/REACH)** ..... ២២-២៤
- កម្មវិធីអប់រំបរិយាបន្ន **(IEP)** ..... ២៥
- គម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី **(LSLAG)** ..... ២៦
- កម្មវិធីអាហារូបករណ៍របស់កម្មវិធីអភិវឌ្ឍន៍ជំនាញការងារឌីជីថល **(DWD)** ..... ២៧
- គម្រោង សៀវភៅសម្រាប់កម្ពុជា **(BfC)** ..... ២៨
- គម្រោង ងាយស្រួលរៀន **(E2L)**-ខេត្តព្រៃវែង ..... ២៩
- គម្រោង ងាយស្រួលរៀន **(E2L)**-ខេត្តក្រចេះ ..... ៣០
- គម្រោង សហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិច តំបន់១ **(FOSTER)** ..... ៣១-៣២
- គម្រោង សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម **(CO-SAVED)** ..... ៣៣
- គម្រោង អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ **(USE-SDP2)** ..... ៣៤
- គម្រោង ពង្រឹងគុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា **(EQUAL)** ..... ៣៥
- កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈភាពជាអ្នកដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រឹងភាពជាអ្នកដឹកនាំ និងសមភាពយេនឌ័រ **(MoEYS-LPD)** ..... ៣៦
- គម្រោង អប់រំបំណិនជីវិតមូលដ្ឋាន **(LLSE)** ..... ៣៧
- កម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន **(ADLP)** ..... ៣៨
- កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ **(KDLP)** ..... ៣៩

សេចក្តីសង្ខេបហិរញ្ញវត្ថុឆ្នាំ២០២៣ ..... ៤០
ថ្នាក់គ្រប់គ្រងអង្គការ ខេប ឆ្នាំ២០២៣ ..... ៤១
រចនាសម្ព័ន្ធអង្គការ ខេប ឆ្នាំ២០២៣ ..... ៤២



**រៀបចំដោយ**
លោក អឿ សាវីន
*មន្ត្រីទំនាក់ទំនងជាន់ខ្ពស់*

**សរសេរ និងកែសម្រួលជាភាសាអង់គ្លេសដោយ**
លោក ឃីត ប្រៃដិនបើក
*ទីប្រឹក្សាបច្ចេកទេសជាន់ខ្ពស់*

**ពិនិត្យ និងកែសម្រួលភាសាខ្មែរដោយ**
លោក ហ៊ិន ស៊ីមហួន
*នាយករងប្រតិបត្តិ/ប្រធានបច្ចេកទេស*
លោក ឈួន សារ៉ាន
*ប្រធានរដ្ឋបាល និងធនធានមនុស្ស*

**ផ្តល់ទិន្នន័យ និងព័ត៌មានគម្រោងដោយ**
លោក អ៊ុល រុន (NGS)
*ប្រធានកម្មវិធីសាលារៀនជំនាន់ថ្មី/ទីប្រឹក្សាជាតិជាន់ខ្ពស់*
លោក បូ សម្បត្តិ (សេចក្តីសង្ខេបហិរញ្ញវត្ថុ)
*នាយកគ្រប់គ្រងហិរញ្ញវត្ថុ*
លោក ម៉ៃ សារិទ្ធិ (HCC &BMZ/REACH)
*អ្នកសម្របសម្រួលបច្ចេកទេស និងតស៊ូមតិ*
បណ្ឌិត ស៊ុន សុម៉ារ៉ា (NGPRC)
*អ្នកសម្របសម្រួលការបណ្តុះបណ្តាល*
លោកស្រី ហ៊ឹម ម៉ារី IEP (DWD/LSLAG)
*ប្រធានសម្របសម្រួលកម្មវិធីអប់រំបរិយាបន្ន*
លោក ពេជ្រ សុភឿន (BfC)
*ប្រធានគម្រោង*
លោក ទុំ ទីតូណា (BMZ/REACH)
*ប្រធានគម្រោង*
កញ្ញា មុល សុធា (LSLAG)
*មន្ត្រីបណ្តុះបណ្តាលគម្រោង*
លោកស្រី ស៊ីម ផល្លី (DWD)
*មន្ត្រីគាំពារកុមារ និងយេនឌ័រ*
លោក ផល សុវណ្ណធី (COSAVED)
*អ្នកឯកទេសគុណភាពអប់រំ*
លោក កុល វណ្ណី (FOSTER)
*ប្រធានគម្រោង*
លោកស្រី ប៉ៅឡា ម៉ាសា (MoEYS LPD)
*ទីប្រឹក្សាអប់រំ*
លោក ស សុផាណាក់ (ADLP & KDLP)
*អ្នកសម្របសម្រួលផ្នែកបច្ចេកវិទ្យាអប់រំ*
លោក ស្លេះ តហៀត (EQUAL)
*ប្រធានគម្រោង*
លោក នូ ស៊ីណាត (LLSE & E2I-PV)
*ប្រធានគម្រោង*
លោក មុំ ទ្បៃ (E2L-KTR)
*ប្រធានគម្រោង*
លោក ផាន់ ប៊ុនណាត (USE-SDP2)
*អ្នកសម្របសម្រួលការវាយតម្លៃទទួលស្គាល់គុណភាពអប់រំ*
លោក ស៊ុំ វណ្ណៈ (TTO)
*ប្រធានបោះពុម្ពផ្សាយ (ធីធីអូ)*

# សេចក្ដីសង្ខេប

ក្នុងអំឡុងឆ្នាំ២០២៣ ខេបរក្សាបាននូវកម្មវិធីដ៏ធំជាប្រវត្តិសាស្ត្រដែលក្ដោបលើគម្រោងចំនួន២១ (សូមមើលតារាងខាងក្រោម) ដែលតិចជាងឆ្នាំមុនចំនួន១គម្រោង។ នៅក្នុងរបាយការណ៍ថ្មី ទោះបីជាមានការថយចុះចំនួនគម្រោងតិចតួចក៏ដោយ ក៏គម្រោងដែលមានស្រាប់ជាច្រើនរបស់ខេបបានពង្រីកវិសាលភាពរបស់ពួកគេ ខណៈដែលផលប័ត្រហិរញ្ញប្បទានមានការពង្រីករហូតដល់ជាង ២០.៦៣១លានរៀល។

គម្រោងដែលអនុវត្តដោយខេប បានគ្របដណ្ដប់លើខេត្តចំនួន១៨ និងផ្ដល់ផលដល់កុមារ និងយុវជនប្រមាណជាង១៦០.០០០នាក់។ ខេបមានម្ចាស់ជំនួយចំនួន១៥ នៅគ្រប់ផ្នែកចាប់ពីមូលនិធិធំៗរហូតដល់ដៃគូសាជីវកម្ម ក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា។ ខេបនៅតែបន្តមានម្ចាស់ជំនួយទ្វេភាគី និងពហុភាគីមួយចំនួន ប៉ុន្តែសារៈសំខាន់ពួកគេជាប្រភពហិរញ្ញប្បទានបន្តធ្លាក់ចុះដែលជាផ្នែកនៃយុទ្ធសាស្ត្រងាកចេញពីការទទួលហិរញ្ញប្ប *(បន្តទៅទំព័រ ៦...)*




| គម្រោងចំនួន២១ក្នុងឆ្នាំ២០២៣ | | | លក្ខខណ្ឌ |
|---|---|---|---|
| ១. | ADLP | កម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន | បញ្ចប់ |
| ២. | BfC | សៀវភៅសម្រាប់កម្ពុជា | បន្ត |
| ៣. | COSAVED | សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម | បន្ត |
| ៤. | E2L-PV | ងាយស្រួលរៀន-ខេត្តព្រៃវែង | បញ្ចប់ |
| ៥. | E2L-Kr | ងាយស្រួលរៀន-ខេត្តក្រចេះ | បន្ត |
| ៦. | EQUAL | ពង្រឹងគុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា | បន្ត |
| ៧. | FLP | កម្មវិធីអក្ខរកម្មហិរញ្ញវត្ថុ | ថ្មី |
| ៨. | FOSTER | សហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិច តំបន់១ | បន្ត |
| ៩. | HCC | កុមារកម្ពុជារីករាយ | បន្ត |
| ១០. | KDLP | កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ | ថ្មី |
| ១១. | LLSE | កម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាន | ថ្មី |
| ១២. | LSLAG | គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី * * | បន្ត |
| ១៣. | DWD | កម្មវិធីអាហារូបករណ៍របស់កម្មវិធីអភិវឌ្ឍន៍ជំនាញការងារឌីជីថល | ថ្មី |
| ១៤. | MIDL | កម្មវិធីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងឌីជីថល | ថ្មី |
| ១៥. | MLPDP | កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈភាពជាអ្នកដឹកនាំ | បញ្ចប់ |
| ១៦. | NGPRC | មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | បន្ត |
| ១៧. | NGSI (Secondary) | កម្មវិធីសាលារៀនជំនាន់ថ្មី (កម្រិតមធ្យមសិក្សា) | បន្ត |
| ១៨. | NGSI (Primary) | កម្មវិធីសាលារៀនជំនាន់ថ្មី (កម្រិតបឋមសិក្សា) | បន្ត |
| ១៩. | BMZ/REACH | បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ | បន្ត |
| ២០. | EGLA | កម្មវិធីវាយតម្លៃការសិក្សាថ្នាក់ដំបូង | បញ្ចប់ |
| ២១. | USE-SDP 2 | អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ | បញ្ចប់ |

(...បន្តពីទំព័រ ៥) ទានបែបនេះ។ ហេតុផលនៅពីក្រោយយុទ្ធសាស្ត្រនេះគឺដើម្បីបង្កើនឯករាជ្យភាពរបស់ខ្លួនពីការដឹក នាំមុខដោយម្ចាស់ជំនួយ ដែលជារឿយៗផ្ទុយនឹងគោលដៅ និងជំនឿដើមរបស់ខេប។

ខេបក៏បន្តមានមោទនភាពយ៉ាងខ្លាំងចំពោះទំនាក់ទំនងជិតស្និទ្ធរបស់ខ្លួនជាមួយក្រសួងអប់រំ យុវជន និងកីឡា។ ខេបប្រហែលជាអង្គការតែមួយគត់ដែលទទួលបានជំនួយហិរញ្ញប្បទានដោយផ្ទាល់ពីក្រសួង រួមទាំងបង្កាន់ដៃបង់ពន្ធ។ ក្រសួងបានអនុម័តផ្តល់ហិរញ្ញប្បទានផ្ទាល់ដល់ឆ្នាំទី៩សម្រាប់ឆ្នាំ ២០២៤ ដើម្បីបន្តការអនុវត្តកំណែទម្រង់សាលារៀនជំនាន់ថ្មី។ ក្រសួងអប់រំ យុវជន និងកីឡាបានបន្តជាម្ចាស់ជំនួយដ៏ធំបំផុតរបស់ខេប ដែលផ្តល់ហិរញ្ញប្បទានប្រចាំឆ្នាំចំនួនជាង ៧.៤៧៦លានរៀលដល់ខេប ក្នុងអំឡុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ដើម្បីគាំទ្រដល់កំណែទម្រង់អប់រំសាលារៀនជំនាន់ថ្មី និងប្រតិបត្តិមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីនៃវិទ្យាស្ថានជាតិអប់រំ (NGPRC)។ ជាពិសេសនោះគឺបច្ចុប្បន្ននេះ ខេបកំពុងពង្រីកកម្មវិធីសាលារៀនជំនាន់ថ្មីនៅទីតាំងថ្មីចំនួនពីរដែលតាមផែនការនៅក្នុងខេត្តសៀមរាប និងខេត្តព្រៃវែង។ ទីតាំងបន្ថែម នេះក៏បានបញ្ចូលទៅក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មី តាមរយៈកិច្ចព្រមព្រៀងគម្រោងចុងក្រោយបំផុតរបស់ក្រសួងអប់រំ យុវជន និងកីឡាជាមួយធនាគារអភិវឌ្ឍន៍អាស៊ី។ សាលារៀនជំនាន់ថ្មីសរុបចំនួន៨នឹងទទួលបានការគាំទ្រតាមរយៈគម្រោងថ្មីនេះ។

ទាក់ទងនឹងការបោះពុម្ពផ្សាយ ខេបបានបន្តផលិតសៀវភៅណែនាំ និងអត្ថបទស្រាវជ្រាវសំខាន់ៗមួយចំនួនធំ ដើម្បីផ្តល់មូលដ្ឋានភស្តុតាងរឹងមាំសម្រាប់កម្មវិធីរបស់ខ្លួន។ ភាគច្រើននៃការបោះពុម្ពផ្សាយទាំងនេះត្រូវបានសហការជាមួយមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ដែលខេបគ្រប់គ្រងក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា។ សៀវភៅណែនាំ និងអត្ថបទសំខាន់ៗដែលផលិតក្នុងឆ្នាំនេះរួមមានការបោះពុម្ពផ្សាយអំពីវិធីសាស្ត្រសិក្សាបែបគម្រោង ការគិតបែបគណនា និងសៀវភៅណែនាំដែលបានកែសម្រួលស្តីពីការរៀនតាមបែបស្ថាបនានិយម។ ខេបបានផលិតអត្ថបទស្រាវជ្រាវចំនួន១៥ ស្តីពីសាលារៀនស្វយ័តដែលជាផ្នែកមួយនៃ ***សន្និសីទអន្តរជាតិស្តីពីសាលារៀនស្វយ័ត*** ដែលរៀបចំឡើងដោយខេបក្នុងខែកញ្ញា ឆ្នាំ២០២៣។ សៀវភៅ និងការបោះពុម្ពផ្សាយទាំងនេះ អាចរកបាននៅលើគេហទំព័ររបស់អង្គការ ខេប តាមតំណភ្ជាប់៖ http://www.kapekh.org/en/publications-media/26/។

នៅឆ្នាំ២០២៣ ខេបមានកំណើនបទពិសោធន៍យ៉ាងឆាប់រហ័សលើចំនួនគម្រោងដែលផ្តោតលើការអប់រំឌីជីថល។ គម្រោងថ្មីទាំងនេះ ភាគច្រើនបង្កើតបាននូវការពង្រីកទំនាក់ទំនងជាមួយវិស័យឯកជន ដូចជា ក្រុមហ៊ុនមេតា និង Google ដែលបានផ្តល់ហិរញ្ញប្បទានដល់គម្រោងថ្មីដើម្បីអភិវឌ្ឍ និងផ្សព្វផ្សាយកម្មវិធីសិក្សាថ្មីស្តីពី ICT និងប្រព័ន្ធផ្សព្វផ្សាយ និងអក្ខរកម្មឌីជីថលព័ត៌មានវិទ្យា (MIDL)។ ខេបក៏រំពឹងថានឹងទទួលបានហិរញ្ញប្បទានជាង ៤.១១០លានរៀលផងដែរដែលផ្តោតលើការអប់រំឌីជីថលនៅឆ្នាំ២០២៤ តាមរយៈម្ចាស់ជំនួយដូចជា អង្គការឆោលហ្វានកូរ៉េ និងស្ថាប័ន Lichtenstein (LED)។

ស្ថានភាពហិរញ្ញវត្ថុទាំងមូលរបស់ខេបបានបន្តរក្សាស្ថិរភាពក្នុងអំឡុងឆ្នាំនេះ ដែលមានប្រាក់ចំណូលប្រចាំឆ្នាំកើនឡើងពី **១៧.៧៧៨លានរៀល**ក្នុងឆ្នាំសារពើពន្ធ ២០២២ ដល់ **២០.៦៣១លានរៀល** ក្នុងឆ្នាំសារពើពន្ធ ២០២៣ ឬកើនឡើង**១៧%**។ នៅចុងឆ្នាំនេះ ខេបមានម្ចាស់ជំនួយ និងដៃគូចំនួន១៥ រួមទាំងម្ចាស់ជំនួយថ្មី ឬចាស់ ដូចជា ***មូលនិធិគីនថាន*** ***ក្រុមហ៊ុនមេតា*** និង***អង្គការ WeWorld***។ ទោះបីជាយ៉ាងណាក៏ដោយ គួរកត់សម្គាល់ថា ចំនួនប្រហែល **៣៧%** នៃប្រាក់ចំណូលរបស់ខេប បច្ចុប្បន្ននេះបានមកពី***ក្រសួងអប់រំ យុវជន និងកីឡា*** ដែលធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជាក្លាយជាម្ចាស់ជំនួយធំជាងគេរបស់ខេប។ ចំណែក**៥០%**ទៀតបានមកពីមូលនិធិឯកជន និងវិស័យឯកជន ខណៈដែលនៅសល់គឺបានមកពីទ្វេភាគី ឬពហុភាគី។ អត្រាប្រើប្រាស់ហិរញ្ញប្បទានក្នុងអំឡុងឆ្នាំនេះមានចំនួន **៨៧%** ដែលពិតជាទំហំមួយដ៏ខ្ពស់របស់ខេប។ ដូចកាលពីឆ្នាំមុន ខេបមានធនធានចំនួន **៦២%** បានចំណាយលើការគាំទ្រអ្នកទទួលផល រួមទាំងសេវាកម្មអប់រំ សម្ភារ និងបរិក្ខាសាលារៀន ជំនួយសាលា និងការសិក្សាស្រាវជ្រាវក្នុងឆ្នាំសារពើពន្ធឆ្នាំ២០២៣។

## ការឆ្លុះបញ្ចាំងទៅថ្ងៃអនាគត...!

ដោយសារគម្រោងចំនួន៥គ្រោងនឹងបញ្ចប់នៅឆ្នាំ២០២៣ ខេបបានបន្តវិនិយោគដ៏ធំទៅក្នុងការអភិវឌ្ឍកម្មវិធីដែលត្រូវនឹងផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំរបស់ខ្លួន។ ការបង្កើតគម្រោងថ្មីផ្តោតលើវិធីសាស្ត្ររួមមួយចំពោះការអភិវឌ្ឍសាលារៀន វឌ្ឍនភាពក្នុងការអប់រំឌីជីថល និងសមភាពយេនឌ័រ។ សរុបមក ការបង្កើតគម្រោងចំនួន១៤បានដាក់ស្នើទៅម្ចាស់ជំនួយក្នុងឆ្នាំ ២០២៣សម្រាប់ពិនិត្យ និងអនុម័ត។ ក្នុងចំណោមគម្រោងទាំងនេះ មានគម្រោងចំនួន៩ទទួលបានជោគជ័យ ខណៈដែលគម្រោងចំនួន៤ទៀតមិនទាន់សម្រេច (សូមមើលមូលនិធិអាស៊ី ADB អង្គការយូណេស្កូ និងអង្គការ ROTA[១]) ដែលនេះបង្កើតបានជាអត្រាជោគជ័យ៦៤%។ ការអនុម័តចំនួន៣ទៀតគឺសម្រាប់គម្រោងពង្រីកបន្ថែម ខណៈដែលនៅសល់គឺសម្រាប់គម្រោងថ្មី។ ជាលទ្ធផលកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍កម្មវិធីក្នុងអំឡុងឆ្នាំនេះ ខេបរំពឹងថានឹងមានគម្រោងអនុវត្តយ៉ាងហោចណាស់ចំនួន១៨ ឬច្រើនជាងនេះក្នុងឆ្នាំសារពើពន្ធបន្ទាប់ អាស្រ័យលើស្ថានភាពសំណើសុំគម្រោងមិនទាន់សម្រេច។

## សេចក្តីសង្ខេបការអភិវឌ្ឍកម្មវិធីឆ្នាំ២០២៣

| គម្រោង | ដៃគូ | ម្ចាស់ជំនួយ | លក្ខខណ្ឌ | រយៈពេល |
|---|---|---|---|---|
| ១. ស្រាវជ្រាវគោលនយោបាយពន្លកចំណេះ | មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | មូលនិធិអាស៊ី-AusAID | កំពុងរង់ចាំ | កំពុងរង់ចាំ |
| ២. គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ | ក្រសួងអប់រំ យុវជន និងកីឡា | ធនាគារអភិវឌ្ឍន៍អាស៊ី | កំពុងរង់ចាំ | ១ឆ្នាំ |
| ៣. កម្មវិធីពន្លឿនបំណិនសំណេរឌីជីថល (DViTSA) | ក្រសួងអប់រំ យុវជន និងកីឡា ក្រុមហ៊ុន Apptessence | អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ច Lichtenstein | ជោគជ័យ | ១ឆ្នាំ |
| ៤. គម្រោងលើកកម្ពស់ការអប់រំឌីជីថលសម្រាប់ទាំងអស់គ្នាសិក្សា (IDEAL) | ក្រសួងអប់រំ យុវជន និងកីឡា | អង្គការឆោលហ្វាន/កូរ៉េ | ជោគជ័យ | ៣ឆ្នាំ |
| ៥. គម្រោងអភិវឌ្ឍន៍កម្មវិធីបំណិនជីវិតមូលដ្ឋាន | ក្រសួងអប់រំ យុវជន និងកីឡា | អង្គការយូនីសេហ្វ | ជោគជ័យ | ៦ខែ |
| ៦. កម្មវិធីកសាងសមត្ថភាពផ្នែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអក្ខរកម្មឌីជីថល (MIDL) (ពង្រីកបន្ត) | អង្គការយូនីស្កូ | UNPRPD | កំពុងរង់ចាំ | ៦ខែ |
| ៧. កម្មវិធី CSOs ដើម្បីលើកកម្ពស់ពលរដ្ឋសកម្ម | អង្គការ WeWorld-GVC អង្គការឆោលហ្វាន, CRDT | សហភាពអឺរ៉ុប | មិនជោគជ័យ | ៣ឆ្នាំ |
| ៨. គម្រោង អ្នកសិក្សាសកល | អង្គការ CARE | អង្គការ ROTA | កំពុងរង់ចាំ | ៣ឆ្នាំ |
| ៩. គម្រោងកុមារកម្ពុជារីករាយ (ពង្រីកបន្ត) | សមាគមគ្រួសារយើង | មូលនិធិគីនថាន | ជោគជ័យ | ១ឆ្នាំ |
| ១០.កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ (ពង្រីកបន្ត) | ក្រសួងអប់រំ យុវជន និងកីឡា | មេតា | ជោគជ័យ | ១ឆ្នាំ |
| ១១.គម្រោងអប់រំជំនិតសម្រាប់កុមារី (ពង្រីកបន្ត) | ក្រសួងអប់រំ យុវជន និងកីឡា | ក្រុមហ៊ុន Gap, Inc. | ជោគជ័យ | ២ឆ្នាំ |
| ១២.មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (ពង្រីកបន្តឆ្នាំទី៤) | មូលនិធិគ្រួសារត្រកូលហ្វ្រេងស៍ | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| ១៣.គម្រោងសាលារៀនជំនាន់ថ្មី/កម្រិតបឋមសិក្សា (ពង្រីកបន្តឆ្នាំទី៥) | មូលនិធិគ្រួសារត្រកូលហ្វ្រេងស៍ | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |
| ១៤.គម្រោងសាលារៀនជំនាន់ថ្មី/កម្រិតមធ្យមសិក្សា (ពង្រីកបន្តឆ្នាំទី៧) | មូលនិធិគ្រួសារត្រកូលហ្វ្រេងស៍ | ក្រសួងអប់រំ យុវជន និងកីឡា | ជោគជ័យ | ១ឆ្នាំ |

[១] *អង្គការ ROTA:* http://bit.ly/3y4p3bJ

## អង្គការ ខេប បានរៀបចំសន្និសីទអន្តរជាតិលើសាលារៀនស្វយ័ត

អង្គការ ខេប បានរៀបចំសន្និសីទអន្តរជាតិលើកដំបូងរបស់ខ្លួន នៅសណ្ឋាគារភ្នំពេញ សុខា ក្នុងរាជធានីភ្នំពេញ នៅថ្ងៃទី២៨-២៩ ខែកញ្ញា ឆ្នាំ២០២៣។ វាជាកិត្តិយសដ៏ធំធេងសម្រាប់ខេបដែលមានវត្តមានឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ជាវាគ្មិនដ៏សំខាន់បានអញ្ជើញចូលរួម។ សន្និសីទនេះបានបើកសម្ពោធលេខាធិការដ្ឋានអន្តរជាតិថ្មីមួយដែលនឹងត្រូវគ្រប់គ្រងដោយអង្គការ ខេប មានឈ្មោះថា លេខាធិការដ្ឋានអន្តរជាតិសាលារៀនជំនាន់ថ្មី។ លេខាធិការដ្ឋានកំពុងត្រូវបានបង្កើតឡើងដើម្បីទាក់ទាញការយកចិត្តទុកដាក់ដល់កិច្ចខិតខំប្រឹងប្រែងជាសាកលក្នុងការបង្កើតសាលារៀនសាធារណៈស្វយ័ត ដែលជាយុទ្ធសាស្ត្រដ៏សំខាន់មួយក្នុងការជំរុញកំណែទម្រង់អប់រំដោយផ្តោតលើការកែលម្អគុណភាពអប់រំនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ផ្សេងទៀត។ សន្និសីទនេះផ្តោតជាពិសេសលើសាលារៀនស្វយ័តគំរូជាក់លាក់ ដែលបច្ចុប្បន្ននេះសាលារៀនជំនាន់ថ្មីបានពង្រីកនៅក្នុងប្រទេសចំនួនពីរក្នុងតំបន់ (ចាប់ផ្តើមដំបូងនៅប្រទេសកម្ពុជា នឹងបន្ទាប់គឺប្រទេសឡាវ)។ គំរូស្រដៀងគ្នាសាលារៀនស្វយ័តក៏ត្រូវបានដាក់បង្ហាញជា*សាលាលំដាប់ពិភពលោក*ផងដែរនៅក្នុងប្រទេសថៃ សាលារៀនធម្មនុញ្ញនៅសហរដ្ឋអាមេរិក សាលា Academies នៅចក្រភពអង់គ្លេសជាដើម។ មានមនុស្សជាង១០០នាក់បានចូលរួមសន្និសីទនេះ។ សន្និសីទនេះមានវាគ្មិនអន្តរជាតិជាច្រើននាក់ រួមទាំងអ្នកមកពីសាកលវិទ្យាល័យជាតិឡាវ មូលនិធិ HEAD មកពីប្រទេសសិង្ហបុរី និងមូលនិធិ Lamplaimat មកពីប្រទេសថៃ។ អង្គការ ខេប សង្ឃឹមថាសន្និសីទនេះនឹងក្លាយជាជំហានដំបូងដ៏សំខាន់ឆ្ពោះទៅរកកិច្ចខិតខំប្រឹងប្រែងក្នុងតំបន់បន្ថែមទៀត ដើម្បីបង្កើតសាលារៀនស្វយ័ត៕












*ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានថ្លែងសុន្ទរកថាគន្លឹះក្នុងសន្និសីទអន្តរជាតិស្តីពីសាលារៀនស្វយ័ត នៅសណ្ឋាគារ សុខា ភ្នំពេញ ដែលរៀបចំឡើងដោយអង្គការ ខេប នាថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣។ អង្គការ ខេបមានកិត្តិយសយ៉ាងក្រៃលែងដែលមានឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡាបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងអង្គសន្និសីទនេះ ហើយមានការកោតសរសើរយ៉ាងខ្លាំងចំពោះគំនិត និងយោបល់របស់គាត់។*

## អង្គការ ខេប ទទួលការអញ្ជើញពីមូលនិធិអាស៊ាន ដើម្បីទទួលពានរង្វាន់ភាពជាដៃគូ




នៅឆ្នាំ២០២៣ អង្គការ ខេប បានទទួលពានរង្វាន់ពីមូលនិធិអាស៊ាន និង Google ក្នុងការអនុវត្តកម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន (ADLP)។ កម្មវិធីនេះផ្តោតលើការកាត់បន្ថយគម្លាតរបស់អ្នកប្រើប្រាស់ឌីជីថលនៅក្នុងប្រទេសកម្ពុជា និងប្រទេសអាស៊ានដទៃទៀត ដោយការពារការរីករាលដាលព័ត៌មានក្លែងក្លាយនៅតាមអនឡាញ។ កម្មវិធីនេះបានបណ្តុះបណ្តាលគ្រូបង្គោលជាតិជាង៧០នាក់ ដែលធ្វើការនៅតាមកម្រិតជាច្រើនដើម្បីពង្រឹងសមត្ថភាពរបស់ប្រជាជនដែលងាយរងគ្រោះក្នុងការទប់ទល់នឹងឥទ្ធិពលបំផ្លិចបំផ្លាញពីព័ត៌មានក្លែងក្លាយ និងព័ត៌មានមិនពិត។ លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការ និង លោក ស សុផាណាក់ អ្នកសម្របសម្រួល ICT ប្រចាំអង្គការ ខេប បានធ្វើដំណើរទៅកាន់កោះបាលី ប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃទី១៣-១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ដើម្បីចូលរួមក្នុងពិធីប្រគល់ពានរង្វាន់ និងកិច្ចប្រជុំឆ្លុះបញ្ចាំងពីផលជះគម្រោង និងលទ្ធភាពបន្តកម្មវិធី៕

## NOREC បានអញ្ជើញអង្គការ ខេប ទៅចូលរួមកិច្ចប្រជុំលើកដំបូង ដើម្បីចាប់ផ្តើមកម្មវិធីផ្លាស់ប្តូរបុគ្គលិកក្នុងតំបន់



លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការ ខេប និងលោក ស សុផាណាក់ អ្នកសម្របសម្រួលកម្មវិធីផ្លាស់ប្តូរបុគ្គលិក (រូបនៅកណ្តាល) ឈរជាមួយលោក យាន សុចិត្រា (ឆ្វេង) និងកញ្ញា ស៊ាត ឈុនឡាយ (រូបនៅខាងស្តាំ) ដែលជាអ្នកស្ម័គ្រចិត្តទៅធ្វើការនៅបង់ក្លាដែស។ (នៅ Kathmandu ប្រទេសនេប៉ាល់)

អង្គការ ខេប បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយ NOREC ក្នុងឆ្នាំ២០២៣ ដើម្បីចូលរួមក្នុងកម្មវិធីផ្លាស់ប្តូរបុគ្គលិកជាមួយអង្គការបង់ក្លាដែសមានឈ្មោះថា Nobo Jibo ដើម្បីស្វែងយល់អំពីកម្មវិធីរវាងគ្នាទៅវិញទៅមកដោយសង្ឃឹមលើការលើកកម្ពស់ការចែករំលែកគំនិតច្នៃប្រឌិតក្នុងការអភិវឌ្ឍរវាងអង្គការទាំងពីរ។ កម្មវិធីផ្លាស់ប្តូរនេះមានរយៈពេល២ឆ្នាំ ដែលបុគ្គលិកកម្ពុជាពីរនាក់ទៅធ្វើការនៅប្រទេសបង់ក្លាដែស ខណៈដែលបុគ្គលិកបង់ក្លាដែសពីរនាក់មកធ្វើការនៅក្នុងប្រទេសកម្ពុជា ក្នុងការស្វែងយល់អំពីកម្មវិធីសាលារៀនជំនាន់ថ្មី។ នាយកប្រតិបត្តិអង្គការ ខេប និងអ្នកសម្របសម្រួលកម្មវិធីបានធ្វើដំណើរទៅកាន់ទីក្រុង Kathmandu ប្រទេសនេប៉ាល់ក្នុងអំឡុងថ្ងៃទី២-៨ ខែតុលា ឆ្នាំ២០២៣ ដើម្បីចូលរួមពិធីសម្ពោធកម្មវិធីផ្លាស់ប្តូរបុគ្គលិក និងនាំយកអ្នកស្ម័គ្រចិត្តពីអង្គការ ខេប ចំនួន២នាក់ទៅធ្វើការតម្រង់ទិសអំពីរបៀបផ្លាស់ប្តូរដែលនឹងធ្វើការលាតបង្ហាញ៕

## វត្តមានចូលរួមក្នុងកិច្ចប្រជុំកំពូលសន្តិភាពអន្តរជាតិនៃអង្គការ HWPL



លោក សៅ វណ្ណា នាយកប្រតិបត្តិអង្គការ ខេប បានអញ្ជើញចូលរួមសន្និសីទអន្តរជាតិស្តីពីការលើកកម្ពស់ជំនាញដោះស្រាយជម្លោះ ដែលជាផ្នែកមួយនៃការអប់រំបំណិនជីវិតនៅក្នុងតំបន់អាស៊ីប៉ូស៊ីហ្វិក។ កិច្ចប្រជុំកំពូលសន្តិភាពអន្តរជាតិនៃអង្គការ HWPL បានធ្វើឡើងនៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង ក្នុងអំឡុងថ្ងៃទី១៧-២១ ខែកញ្ញា ឆ្នាំ២០២៣ ដើម្បីប្រមូលផ្តុំអ្នកអប់រំ អ្នកនិពន្ធ និងមេដឹកនាំនយោបាយ ដើម្បីធ្វើការរួមគ្នាឆ្ពោះទៅរកសន្តិភាពពិភពលោក។ HWPL គឺជាអង្គការសន្តិភាពអន្តរជាតិដែលបង្កើតឡើងសម្រាប់សន្តិភាពពិភពលោក និងការបញ្ចប់សង្គ្រាម។ សន្និសីទនៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង មានអ្នកចូលរួមជាង៥០០នាក់ ហើយបានធ្វើការផ្សព្វផ្សាយសន្និកសន្ទាប់ដើម្បីបង្កើតទំនាក់ទំនងការងារជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៅក្នុងប្រទេសជាច្រើននៅទូទាំងតំបន់អាស៊ីប៉ូស៊ីហ្វិក សម្រាប់បណ្តុះបណ្តាលយុវជនឱ្យធ្វើការងារដើម្បីសន្តិភាព។ អង្គការ ខេប សង្ឃឹមថានឹងចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា (MoU) ជាមួយអង្គការ HWPL នៅក្នុងឆ្នាំ២០២៤ ដើម្បីចាប់ផ្តើមកិច្ចខិតខំប្រឹងប្រែងកសាងសកម្មភាពដោះស្រាយជម្លោះដាក់ទៅក្នុងកម្មវិធីរបស់ខ្លួនជាប្រក្រតី៕

## អង្គការ ខេប បានរៀបចំដំណើរទស្សនកិច្ចសិក្សាឱ្យមូលនិធិគីនចាន ដើម្បីពង្រីកកម្មវិធីនៅក្នុងប្រទេសកម្ពុជា



*គណៈប្រតិភូមកពីមូលនិធិគីនចាន បានថតរូបជាមួយអភិបាលខេត្តរតនគិរី ក្នុងបេសកកម្មប្រមូលព័ត៌មាន។*

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ អង្គការ ខេប បានរៀបចំដំណើរទស្សនកិច្ចសិក្សាមួយជូនដល់លោក Hartmut Giesecke ប្រធានមូលនិធិគីនចាន និងអមដោយកូនស្រីរបស់គាត់ គឺលោកស្រី Kiyoko Giesecke ដើម្បីពិនិត្យមើលទីតាំងថ្មីៗសម្រាប់ពង្រីកផែនការកម្មវិធីរបស់គម្រោងកុមារកម្ពុជារីករាយ។ បច្ចុប្បន្ននេះ មូលនិធិគីនចានដែលមានមូលដ្ឋាននៅ Lichtenstein បានគាំទ្រសាលាបឋមសិក្សាចំនួន៥៥ នៅតំបន់ដាច់ស្រយាលតាមរយៈអង្គការ ខេប ហើយគ្រោងនឹងបង្កើនវិសាលភាពកម្មវិធីរហូតដល់១០០សាលា។ មូលនិធិបានបោះទុនជាង៧លានដុល្លាររួចហើយនៅក្នុងប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាសម្រាប់ការធ្វើទំនើបកម្មគុណភាព ហើយសង្ឃឹមថានឹងវិនិយោគក្នុងបរិមាណប្រហាក់ប្រហែលនេះក្នុងរយៈពេល៥ឆ្នាំខាងមុខ។ តំណាងមូលនិធិបានជួបជាមួយអ្នកពាក់ព័ន្ធសំខាន់ៗជាច្រើននៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងដំណើរទស្សនកិច្ចរយៈពេលពីរសប្តាហ៍ រួមមាន៖ អភិបាលខេត្តមួយចំនួន ប្រធានមន្ទីរអប់រំខេត្ត ព្រមទាំងថ្នាក់ដឹកនាំសាលារៀននៅមូលដ្ឋាន និងមេដឹកនាំសហគមន៍នៅក្នុងតំបន់គោលដៅ៕

## អង្គការ ខេប ត្រូវបានអញ្ជើញចូលរួមក្នុងសន្និសីទអន្តរជាតិស្តីពីការអប់រំគ្រូបង្រៀន






*លោក ផាន់ ប៊ុណ្ណាត អ្នកសម្របសម្រួលការវាយតម្លៃទទួលស្គាល់គុណភាពសាលារៀនជំនាន់ថ្មី បានបញ្ចេញទស្សនៈស្តីពីការអប់រំគ្រូបង្រៀនដល់អ្នកអប់រំអន្តរជាតិ។*

ខណៈពេលអង្គការ ខេប មានការរីកចម្រើនដោយភាពលេចធ្លោ ក្លាយជាប្រភពដ៏សំខាន់ផ្នែកជំនួយផ្នែកបច្ចេកទេស និងមានកម្មវិធីឈានមុខគេ អង្គការបានទទួលការអញ្ជើញឱ្យចូលរួមក្នុងសន្និសីទសំខាន់ៗកាន់តែច្រើនឡើង ដើម្បីធ្វើផែនការសម្រាប់ការអភិវឌ្ឍប្រព័ន្ធអប់រំនាពេលអនាគត។ នៅខែមិថុនា ឆ្នាំ២០២៣ អង្គការ ខេប បានបញ្ជូនទីប្រឹក្សាជាន់ខ្ពស់ពីររូបទៅចូលរួមសិក្ខាសាលាអន្តរជាតិស្តីពី*ការអប់រំគ្រូបង្រៀននៅប្រទេសកម្ពុជា និងអនាគតឆ្ពោះទៅកោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព (SDGs)* ដែលបានរៀបចំឡើងនៅសណ្ឋាគារ Hyatt Regency ក្នុងរាជធានីភ្នំពេញ។ សន្និសីទនេះទទួលបានឧបត្ថម្ភពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ លោក អ៊ុល រុន ទីប្រឹក្សាជាតិជាន់ខ្ពស់ និងលោក ផាន់ ប៊ុណ្ណាត អ្នកសម្របសម្រួលការទទួលស្គាល់គុណភាពនៃកម្មវិធីសាលារៀនជំនាន់ថ្មី លោកទាំងពីរបានចូលរួមក្នុងសិក្ខាសាលានេះក្នុងនាមជាតំណាងឱ្យអង្គការ ខេប ហើយបានចូលរួមចំណែកចែករំលែកការងារដ៏មានតម្លៃជាច្រើនទាក់ទងនឹងអង្គការក្នុងការអប់រំគ្រូបង្រៀន រួមមាន៖ សារៈសំខាន់នៃការប្រឹក្សាគរុកោសល្យ កម្មវិធីសុសវែថ្មីៗស្តីពីការអប់រំគ្រូបង្រៀន និងការលើកកម្ពស់ការងារគម្រោងនៅក្នុងថ្នាក់រៀននៅប្រទេសកម្ពុជា៕

## អង្គការ ខេប ទទួលបានការទទួលស្គាល់អំពីការវិនិយោគដ៏ច្រើនពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងការស្តារនីតិសម្បទាសាលារៀន

ក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ ខេបបានវិនិយោគជាង ២,៧លានដុល្លារអាមេរិកក្នុងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធសាលាបឋមសិក្សា ដោយមានការគាំទ្រពីមូលនិធិគីនចាន។ ថ្នាក់រៀនរាប់រយបន្ទប់នៅតាមតំបន់ដាច់ស្រយាលត្រូវបានស្តារឡើងវិញតាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ។ ក្រសួងអប់រំ យុវជន និងកីឡា បានទទួលស្គាល់ចំពោះកិច្ចខិតខំប្រឹងប្រែងទាំងនេះក្នុងពិធីដ៏ឱឡារិកមួយនៅសាលាបឋមសិក្សាឈើខ្លឹម ក្នុងខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣។ ពិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម វង ភិរុណ អនុរដ្ឋលេខាធិការ ព្រមទាំងអភិបាលរងខេត្ត ប្រធានមន្ទីរអប់រំ និងអ្នកចូលរួមជាច្រើននាក់ទៀត។ លោក Hartmut Giesecke និងកូនស្រីរបស់លោកក៏មានវត្តមាននៅក្នុងពិធីនេះ រួមទាំងវត្តមានចូលរួមពីសំណាក់លោកនាយកប្រតិបត្តិអង្គការ ខេប និងបុគ្គលិកគម្រោងជាច្រើននាក់ទៀតនៅក្នុងពិធីនេះ៕



# អង្គការ ខេប បានរៀបចំអង្គវិបស្សនាបុគ្គលិកប្រចាំឆ្នាំលើកដំបូងដោយជោគជ័យ ក្រោយពីមានការផ្ទុះរីករាលដាលជំងឺកូវីដ-១៩មក



អង្គការ ខេប បានរៀបចំអង្គវិបស្សនាបុគ្គលិកដោយជោគជ័យនៅខែមេសា ឆ្នាំ២០២៣ ក្នុងខេត្តព្រះសីហនុ។ នេះគឺជាអង្គវិបស្សនាបុគ្គលិកលើកដំបូងរបស់អង្គការចាប់តាំងពីពេលផ្ទុះឡើងនូវជំងឺរាតត្បាតកូវីដ-១៩ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាមិនអនុញ្ញាតឱ្យមានការប្រជុំជាលក្ខណៈធំៗ។ នៅពេលដែលអ្វីៗបានវិលមករកភាពប្រក្រតីឡើងវិញ ទីបំផុត អង្គការ ខេប បាននាំបុគ្គលិកខ្លួនទាំងអស់រួមគ្នារៀបចំអង្គវិបស្សនានៅកន្លែងតែមួយ ក្នុងគោលបំណងធ្វើការឆ្លុះបញ្ចាំងពីការអនុវត្តកម្មវិធី និងគម្រោងនានាកាលពីឆ្នាំមុន រួមទាំងការរៀបចំយុទ្ធសាស្ត្រថ្មីៗ និងលើកទិសដៅសម្រាប់ពេលអនាគត។ នៅក្នុងឆ្នាំ២០២៣នេះ អង្គការ ខេប បានរៀបចំអង្គវិបស្សនាជាលក្ខណៈធំដែលមានសមាជិកបុគ្គលិកជាង ១០០ នាក់ដែលមកពីទូទាំង១៣រាជធានី/ខេត្ត៕

# អង្គការ ខេប បានរៀបចំពិធីសម្ពោធកម្មវិធីអក្ខរកម្មឌីជីថលខ្មែរជាមួយក្រុមហ៊ុនមេតា និងក្រ.អយក




នាយកប្រតិបត្តិអង្គការ ខេប អញ្ជើញចូលរួមក្នុងការជួយបើកពិធីសម្ពោធជាមួយក្រុមហ៊ុនមេតា និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីដាក់ដំណើរកម្មវិធីអក្ខរកម្មឌីជីថលខ្មែរ (KDLP)។

នៅខែតុលា ឆ្នាំ២០២៣ ខេបនិងដៃគូខ្លួនគឺក្រុមហ៊ុនមេតា បានចាប់ផ្តើមរៀបចំពិធីសម្ពោធកម្មវិធីអក្ខរកម្មឌីជីថលខ្មែរ (KDLP) សម្រាប់អនុវត្តនៅសាលារៀនជំនាន់ថ្មី។ កម្មវិធីនេះមានគោលបំណងលើកកម្ពស់គុណភាពអប់រំជំនាញឌីជីថលដោយប្រើកម្មវិធីសិក្សា WeLearnDigital ដែលបង្កើតឡើងដោយក្រុមហ៊ុនមេតា។ ខេបនឹងធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើមូលដ្ឋានីយកម្មកម្មវិធីសិក្សានេះឱ្យវាសមស្របនឹងបរិបទកម្ពុជា។ ពិធីសម្ពោធជាផ្លូវការបានធ្វើឡើងនៅសណ្ឋាគារ Hyatt Regency ក្នុងរាជធានីភ្នំពេញ និងមានអ្នកចូលរួមប្រមាណជា៥០នាក់។ ក្នុងពិធីសម្ពោធនេះ លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានគូសបញ្ជាក់ថា រដ្ឋាភិបាលបានដាក់ចេញនូវការអប់រំនៅជួរមុខគេ ដែលក្លាយទៅជាអាទិភាពខ្ពស់ក្នុងចំណោមកំណែទម្រង់សំខាន់ៗដែលរដ្ឋាភិបាលអនុវត្ត។ អង្គការ ខេប បានផ្តល់តម្លៃខ្ពស់ទៅលើកិច្ចសហការរបស់ខ្លួនជាមួយក្រុមហ៊ុនមេតា ដែលជាជំហានដ៏សំខាន់មួយឆ្ពោះទៅមុខក្នុងការផ្សព្វផ្សាយទៅកាន់វិស័យឯកជន ជាពិសេសតាមរយៈជំនាញឌីជីថល៕

## ការបោះពុម្ពផ្សាយដ៏សំខាន់មួយរបស់អង្គការ ខេប ត្រូវបានបើកដំណើរការដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើការផ្សព្វផ្សាយនៅថ្នាក់ជាតិ




*ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន បានផ្តល់ការណែនាំអំពីការរំពឹងទុកសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនក្នុងពិធីសម្ពោធសៀវភៅសិក្សាបែបគម្រោងនៅសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប។*

ការបោះពុម្ពផ្សាយសំខាន់មួយដែលបានបង្កើតឡើងដោយអង្គការ ខេប ក្នុងអំឡុងឆ្នាំ២០២៣ ទាក់ទងនឹងសៀវភៅវិធីសាស្ត្រសិក្សាបែបគម្រោង បានរចនាឡើងដោយក្រុមការងារសាលារៀនជំនាន់ថ្មី។ សៀវភៅណែនាំនេះឆ្លើយតបទៅនឹងសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីចងក្រងនូវវិធីសាស្ត្របង្រៀនជាទម្រង់សៀវភៅបណ្តុះបណ្តាល។ វិធីសាស្ត្រសិក្សាបែបគម្រោងត្រូវបានគេមើលឃើញថាជាមធ្យោបាយមួយដើម្បីគាំទ្រដល់ការបង្រៀនជំនាញការគិតកម្រិតខ្ពស់ ដូចជា ការវិភាគ ការច្នៃប្រឌិត និងការវាយតម្លៃ។ ទោះបីជាសាលារៀនជំនាន់ថ្មីបាននឹងកំពុងបង្កើតគម្រោងសម្រាប់សិស្សរាប់ពាន់នាក់ជារៀងរាល់ឆ្នាំក៏ដោយ ក៏កម្មវិធីបណ្តុះបណ្តាលនេះផ្តល់ឱ្យគ្រូបង្រៀនសម្រេចបាននូវលទ្ធផល ដែលមិនទាន់មានការចងក្រងជាប្រព័ន្ធរហូតមកដល់ពេលនេះ។




ដោយទទួលបានសមិទ្ធផលដ៏សំខាន់នេះ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានស្នើឱ្យអង្គការ ខេប រៀបចំពិធីសម្ពោធសៀវភៅនៅសាលាជំនាន់ថ្មី វិទ្យាល័យព្រែកលៀប ក្នុងរាជធានីភ្នំពេញដែលបានប្រព្រឹត្តិទៅនៅខែសីហា ឆ្នាំ២០២៣។ សៀវភៅនេះត្រូវបានអនុម័តជាផ្លូវការដោយក្រសួងអប់រំ យុវជន និងកីឡា នឹងត្រូវដាក់ឱ្យប្រើប្រាស់នៅតាមវិទ្យាស្ថានគរុកោសល្យ កម្មវិធីបង្រៀន និងនៅកន្លែងផ្សេងៗទៀត ដើម្បីលើកកម្ពស់ការផ្សព្វផ្សាយ អំពីវិធីសាស្ត្រសិក្សាបែបគម្រោង៕

## អង្គការ ខេប បានគាំទ្រសន្និសីទស្តីពីការអប់រំ STEM ដែលរៀបចំឡើងដោយមូលនិធិ HEAD ប្រទេសសិង្ហបុរី



*ការពិភាក្សារបស់វាគ្មិនស្តីពីការអប់រំ STEM៖ មូលនិធិ HEAD និងអង្គការ ខេប ប្រមូលផ្តុំអ្នកជំនាញកំណែទម្រង់ការអប់រំនៅវេទិកាអប់រំ STEM ដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រអប់រំ STEM ថ្មីៗ។*

កិច្ចសហការដ៏សំខាន់មួយដែលបានរៀបចំឡើងនៅឆ្នាំ២០២៣ ទាក់ទងនឹងភាពជាដៃគូរបស់អង្គការ ខេប ជាមួយមូលនិធិ HEAD ប្រទេសសិង្ហបុរី។ កាលពីថ្ងៃទី៤-៥ ខែមេសា ឆ្នាំ២០២៣ អ្នកអនុវត្តកម្មវិធីស្ទែម (STEM) និងគ្រូប្រឹក្សាគរុកោសល្យចំនួន៤៥នាក់មកពីមជ្ឈមណ្ឌល SEAMEO STEM-ED ក្រសួងអប់រំ យុវជន និងកីឡា សាលារៀន និងអង្គការមិនមែនរដ្ឋាភិបាលមកពីអាស៊ីអាគ្នេយ៍បានមកជួបជុំគ្នានៅមជ្ឈមណ្ឌលអាស៊ានសម្រាប់ការអប់រំស្ថិតក្នុងវិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី ដើម្បីពិភាក្សាអំពីការអប់រំ STEM និងប្រឹក្សាគរុកោសល្យនៅក្នុងតំបន់ដោយផ្តោតសំខាន់លើប្រទេសកម្ពុជា (សូមមើល https://headfoundation.org/2023/06/19/stem-mentoring-forum/)៕

## ខេបបានបញ្ជូនក្រុមអ្នកបណ្ដុះបណ្ដាលទៅប្រទេសឡាវ ដើម្បីជួយដល់ការអភិវឌ្ឍសាលាជំនាន់ថ្មី

មូលនិធិគ្រួសារត្រកូលហ្វ្រេងស៍កំពុងគាំទ្រដល់ការអភិវឌ្ឍសាលារៀនជំនាន់ថ្មីក្នុងប្រទេសឡាវតាំងពីឆ្នាំ២០១៨មក។ ដើម្បីពន្លឿនការអនុវត្តសកម្មភាពអភិវឌ្ឍន៍គ្រូបង្រៀននៅទីនោះ មូលនិធិបានស្នើសុំអង្គការ ខេប ឱ្យជួយផ្ដល់វគ្គសិក្ខាសាលាមូលដ្ឋានស្ដីពីវិធីសាស្ត្រសាលារៀនជំនាន់ថ្មីដែលកំពុងអនុវត្តនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។ អង្គការ ខេប បានបញ្ជូនអ្នកអប់រំចំនួន៣នាក់ទៅកាន់ប្រទេសឡាវដើម្បីជំនួយបណ្ដុះបណ្ដាលនេះ។ កម្មវិធីបណ្ដុះបណ្ដាលនេះមានរយៈពេល១០ថ្ងៃ ដែលបានធ្វើឡើងនៅចុងខែកក្កដា ឆ្នាំ២០២៣ នៅទីក្រុងវៀងចន្ទន៍។ ក្រុមការងារអង្គការ ខេប បានបណ្ដុះបណ្ដាលអ្នកអប់រំឡាវប្រមាណជា៣០នាក់។ វគ្គបណ្ដុះបណ្ដាលនេះទទួលបានការស្វាគមន៍យ៉ាងកក់ក្ដៅពីសហសេវិកឡាវ ហើយសង្ឃឹមថាកិច្ចសហប្រតិបត្តិការរវាងឡាវ និងកម្ពុជានឹងបន្តនាពេលខាងមុខ។



*លោក អ៊ុល រុន ទីប្រឹក្សាជាតិជាន់ខ្ពស់របស់អង្គការ ខេប បានធ្វើបទបង្ហាញស្ដីពីវិធីសាស្ត្រសាលារៀនជំនាន់ថ្មីដល់អ្នកអប់រំនៅប្រទេសឡាវ។*

## ទស្សនកិច្ចសិក្សាសម្រាប់អ្នកអប់រំកម្ពុជានៅប្រទេសថៃ




*លោកគ្រូ អ្នកគ្រូ និងអ្នកគ្រប់គ្រងមកពីវិទ្យាល័យព្រែកលៀប ថតរូបជាមួយសហការីថៃមកពីវិទ្យាល័យ Nong Bua ក្នុងខេត្តបូរីរ៉ាម ក្នុងប្រទេសថៃ។*

នៅថ្ងៃទី២៥-២៧ ខែមិថុនា ឆ្នាំ២០២៣ អង្គការ ខេប បានរៀបចំដំណើរទស្សនកិច្ចសិក្សាទៅកាន់ខេត្តបូរីរ៉ាមក្នុងប្រទេសថៃ ដែលមានអ្នកអប់រំកម្ពុជាជិត២០០នាក់ដែលកំពុងធ្វើការនៅក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មី។ ខេត្តបូរីរ៉ាមមានអ្នកនិយាយភាសាខ្មែរជាច្រើន និងជាកន្លែងដ៏ស័ក្តិសម ជាពិសេសសម្រាប់ធ្វើទស្សនកិច្ចផ្ទាល់។ ទស្សនកិច្ចផ្ទាល់នេះមានគោលបំណងពង្រីកទស្សនៈរបស់អ្នកអប់រំនៅក្នុងប្រព័ន្ធ NGS ដោយធ្វើការណែនាំអំពីការអនុវត្តការអប់រំល្អនៅក្នុងប្រព័ន្ធអប់រំផ្សេងទៀត។ សាលារៀនដែលបានចូលរួមនៅក្នុងដំណើរទស្សនកិច្ចនេះ រួមមាន៖ វិទ្យាល័យព្រែកលៀប វិទ្យាល័យ គោកព្រីង វិទ្យាល័យ ព្រែកអញ្ចាញ សាលាបឋមសិក្សាអគ្គមហេសី និងសាលាអនុវត្ត។ ដំណើរទស្សនកិច្ចនេះបានធ្វើនៅសាលារៀនចំនួន៣ដែលមានភាពខុសគ្នាខ្លាំងក្នុងការសិក្សាអប់រំ។ សាលាទាំង៣នេះរួមមាន៖ សាលា Lamplaimat វិទ្យាល័យ Chulaphorn Science និងវិទ្យាល័យ Nong Bua។ ដំណើរទស្សនកិច្ចនេះមានការធ្វើបទបង្ហាញ ការសង្កេតថ្នាក់រៀន និងការប្រជុំឆ្លុះបញ្ចាំងនៅពេលបញ្ចប់ដំណើរទស្សនកិច្ច។ សាលារៀនកម្ពុជាមួយចំនួនក៏បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាជាមួយសាលារៀននៅប្រទេសថៃ ដើម្បីធានាថា ការប្រាស្រ័យទាក់ទងគ្នារវាងពួកគេបន្ទាប់ពីបញ្ចប់ដំណើរទស្សនកិច្ចសិក្សានៅតែបន្ត៕

# ធីធីអូ អ៊ីមផត អិចផត ឯ.ក

*“សម្ភារៈជំនួយការសិក្សាដែលមានប្រសិទ្ធភាព និងតម្លៃសមរម្យ ”*

## សេចក្ដីសង្ខេប

### អំពីយើង

ធីធីអូជាក្រុមហ៊ុនក្នុងស្រុក ផលិតនិងចែកចាយសម្ភារបង្រៀន និងរៀនទាំងក្នុងនិងក្រៅថ្នាក់។

### ផលិតផល

សម្ភារបង្រៀនរួមមាន៖

- ល្បែងសិក្សាគណិតវិទ្យា ២៤ (បឋម)
- ល្បែងសិក្សាគណិតវិទ្យា ១៣ (មធ្យម)
- ល្បែងសិក្សាភាសា ៣២
- ល្បែងសិក្សាវិទ្យាសាស្ត្រ ២
- ទម្រង់វាយតម្លៃអំណាន ៣ កម្រិត

### ទទួលស្គាល់

ផលិតផលទទួល ស្គាល់ និងបានប្រកាសអនុញ្ញាតឱ្យបោះពុម្ពផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា។



### សូមទំនាក់ទំនងមកយើងខ្ញុំតាមអាស័យដ្ឋានខាងក្រោម៖

ទូរសព្ទដៃ៖ ០៩៩ ៣៣៣ ១០២
អ៊ីមែមល៖ info@tts-kape.org
គេហទំព័រ៖ www.tts-kape.org និងចុច “LIKE” និងចុច “Share” ទំព័របណ្ដាញសង្គម: www.facebook.com/ttskape
ឬស្កេន QR Code ↓

↑ ធីធីអូ (TTO) បានចូលរួមតាំងពិព័រណ៍ក្នុងថ្ងៃប្រារព្ធពិធីពិពរ័ណ៌សៀវភៅថ្នាក់ជាតិលើកទី១០នៅសាលកោះពេជ្រ រាជធានីភ្នំពេញ (រូបខាងលើ) និងពិធីពិព័រណ៌សៀវភៅថ្នាក់ខេត្តក្នុងខេត្តសៀមរាប (រូបខាងក្រោម) ដែលជាឱកាសក្នុងការបង្ហាញ ផ្សព្វផ្សាយអំពីសម្ភារសិក្សា និងមានកម្មវិធីបញ្ចុះតម្លៃពិសេសដល់អតិថិជន។ ↓





# កម្មវិធីតាមផ្នែកបច្ចេកទេសរបស់អង្គការ ខេប

ជាច្រើនឆ្នាំមកនេះ ខេបបានទទួលជោគជ័យក្នុងការដាក់បញ្ចូលកម្មវិធីតាមផ្នែកបច្ចេកទេសចម្រុះគ្នា ស្របតាមផែនការយុទ្ធសាស្ត្រខេប។ កាលពីដំបូង ខេបបានវិនិយោគជាចម្បងទៅលើផ្នែកតែពីរប៉ុណ្ណោះ គឺ៖ ការអភិវឌ្ឍគ្រូបង្រៀន និងកម្មវិធីអប់រំបរិយាបន្ន។ អំឡុងពេលផ្នែកទាំងពីរនៃយុទ្ធសាស្ត្រនេះនៅតែជាផ្នែកវិនិយោគជំនាញកម្រិតខ្ពស់បំផុតនោះ ខេបក៏មានជំនាញទាំង៧ផ្នែកបន្ថែមផ្សេងទៀត ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម។ កម្រិតចម្រុះទាំងនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងផែនការយុទ្ធសាស្ត្ររបស់ខេប (ឆ្នាំ២០២១-២០២៥) ដែលគេហៅថា ការបង្កើនជំនាញបច្ចេកទេសចម្រុះគ្នានៅក្នុងដំណើរការកម្មវិធីរបស់ខេប។ ការផ្លាស់ប្តូរដ៏សំខាន់មួយក្នុងការចាត់ថ្នាក់តាមផ្នែកបច្ចេកទេសគឺការលុបចេញនូវកម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវ វិស័យអប់រំក្នុងបរិបទជំងឺកូវីដ-១៩ (ដំណើរការប្រក្រតីភាពនៅក្នុងប្រព័ន្ធអប់រំមានសន្ទុះឡើងវិញ) និងការកើនឡើងនូវចំនួនគម្រោងដ៏ច្រើនដែលផ្តោតលើ ICT ក្នុងការអប់រំ។



យុទ្ធសាស្ត្របច្ចេកទេសតាមផ្នែកនីមួយៗត្រូវបានពន្យល់នៅក្នុងតារាងខាងក្រោម ទាក់ទងនឹងគម្រោងនីមួយៗរបស់ខេបនាពេលបច្ចុប្បន្ននេះ។

## លំដាប់គម្រោងតាមផ្នែកបច្ចេកទេសរបស់អង្គការ ខេប ក្នុងឆ្នាំ២០២៣

| គម្រោងរបស់អង្គការ ខេប ក្នុងឆ្នាំ២០២៣ | ពាក្យបំព្រួញ | ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ | ICT សម្រាប់ការអប់រំ | ការអភិវឌ្ឍគ្រូបង្រៀន | កម្មវិធីអប់រំបរិយាបន្ន | កម្មវិធីអំណានថ្នាក់ដំបូង | កម្មវិធីមត្តេយ្យសិក្សា | វចនាបថហេដ្ឋារចនាសម្ព័ន្ធ | ការអភិវឌ្ឍបណ្ណាល័យ | កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព |
|---|---|---|---|---|---|---|---|---|---|---|
| ១. កម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន | ADLP | | ✓ | | | | | | · | |
| ២. គម្រោង សៀវភៅសម្រាប់កម្ពុជា | BfC | | | | | | | | ✓ | |
| ៣. គម្រោង សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម | COSAVED | | · | ✓ | ✓ | ✓ | ✓ | | ✓ | ✓ |
| ៤. គម្រោង ងាយស្រួលរៀន – ខេត្តព្រៃវែង | E2L-PV | | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៥. គម្រោង ងាយស្រួលរៀន – ខេត្តក្រចេះ | E2L-Kr | | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៦. គម្រោង ពង្រឹងគុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា | EQUAL | | · | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៧. កម្មវិធីអក្ខរកម្មហិរញ្ញវត្ថុ | FLP | | · | ✓ | · | · | | | · | ✓ |
| ៨. កម្មវិធីអាហារូបករណ៍របស់កម្មវិធីអភិវឌ្ឍន៍ជំនាញការងារឌីជីថល | DWD | | ✓ | | | | | | | |
| ៩. គម្រោង សហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិច តំបន់១ | FOSTER | | · | ✓ | ✓ | ✓ | ✓ | | ✓ | ✓ |
| ១០.គម្រោង កុមារកម្ពុជារីករាយ | HCC | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ១១.កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ | KDLP | | ✓ | ✓ | · | | | | | ✓ |
| ១២.កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន | LLSE | | | ✓ | | | | | | ✓ |
| ១៣.គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី | LSLAG | | | | ✓ | | | | | ✓ |
| ១៤.គម្រោងអក្ខរកម្មឌីជីថលប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន | MIDL | | ✓ | ✓ | · | | | | | ✓ |
| ១៥.កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈភាពជាអ្នកដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា | MLPDP | | ✓ | | ✓ | | | | | |
| ១៦.មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | NGPRC | ✓ | ✓ | ✓ | · | | | | | · |
| ១៧.កម្មវិធីសាលារៀនជំនាន់ថ្មី (កម្រិតបឋមសិក្សា) | NGS-P | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ |
| ១៨.កម្មវិធីសាលារៀនជំនាន់ថ្មី (កម្រិតមធ្យមសិក្សា) | NGS-S | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ |
| ១៩.បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ | REACH IV | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ |
| ២០.គម្រោង វាយតម្លៃការសិក្សាថ្នាក់ដំបូង | EGLA | | | | | ✓ | | | | |
| ២១.គម្រោង អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ២ | USE-SDP2 | | ✓ | ✓ | | | | ✓ | ✓ | ✓ |
| សរុបគម្រោងកំពុងដំណើរការក្នុងផ្នែកនីមួយៗ | | 1 | / . | / 3 | / / | 7 | 2 | 2 | / / | / 3 |

# គម្រោង សាលារៀនជំនាន់ថ្មី (NGS)

*"សាលារៀនរដ្ឋមានស្តង់ដាជាសាលារៀនឯកជន "*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | ក្រសួងអប់រំ យុវជន និងកីឡា<br>មូលនិធិគ្រួសារត្រកូលហ្វ្រេង |
| **អ្នកទទួលផលផ្ទាល់** | ៦ ៦៧៩ នាក់ (មធ្យមសិក្សា)<br>២ ៥០៨ នាក់ (បឋមសិក្សា)<br>**៩ ១៨៧ នាក់ (សរុប)** |
| **ថវិកាឆ្នាំសិក្សា២០២៣** | ៦.៧៨០.០០០.០០០រៀល |
| **តម្លៃឯកតាក្នុងសិស្សម្នាក់** | ៨៦០.៩០៧,៣២រៀល (មធ្យម)<br>៤១០.៦៨៥,៨១រៀល (បឋម) |
| **ខេត្តគោលដៅ** | ៥ (ភ្នំពេញ កំពង់ចាម កំពង់ស្ពឺ កណ្តាល និងស្វាយរៀង) |
| **ស្រុកគោលដៅ** | ៧ |
| **សាលាមធ្យមសិក្សាគោលដៅ** | ៦ |
| **សាលាបឋមសិក្សាគោលដៅ** | ៤ |
| **កាលបរិច្ឆេទចាប់ផ្តើម** | ខែតុលា ឆ្នាំ២០១៥ |
| **កាលបរិច្ឆេទបញ្ចប់** | មិនមានកាលបរិច្ឆេទបញ្ចប់ |

## សនិទានភាពកម្មវិធី

សាលារៀនជំនាន់ថ្មី សំដៅលើកំណែទម្រង់អប់រំដែលសម្ពោធដោយក្រសួងអប់រំ យុវជន និងកីឡាក្នុងឆ្នាំ ២០១៥ ដើម្បីបង្កើតសាលារៀនសាធារណៈ **"ស្វយ័ត"** ជាមួយនឹងអាណត្តិក្នុងការបង្កើតនវានុវត្តន៍ និងកែលម្អគុណភាពអប់រំ។ ការទទួលបានមូលនិធិវិនិយោគខ្ពស់គឺផ្អែកលើស្តង់ដាអភិបាលកិច្ច និងវិជ្ជាជីវៈខ្ពស់។ ផ្លូវអភិវឌ្ឍន៍ថ្មីនេះស្វែងរកការផ្លាស់ប្តូរសាលារដ្ឋទៅតាមកម្រិតថ្នាក់ដើម្បីឱ្យពួកគេអាចសម្រេចបាននូវស្តង់ដា **'អតិបរមា'** នៃការអប់រំ ជាពិសេសនៅក្នុងមុខវិជ្ជា STEM។ ក្រោមគោលនយោបាយថ្មីរបស់សាលារៀនជំនាន់ថ្មី ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការប្តេជ្ញាចិត្តយ៉ាងសំខាន់ដើម្បីធ្វើការវិនិយោគយ៉ាងយកចិត្តទុកដាក់នៅក្នុងសាលាទាំងនោះក្រោមលក្ខខណ្ឌដែលធានាបាននូវស្តង់ដាអភិបាលកិច្ចល្អ។ គោលនយោបាយថ្មីនេះជំរុញឱ្យសាលារៀនប្រកាន់ខ្ជាប់នូវស្តង់ដាអប់រំខ្ពស់ ដោយមានប្រព័ន្ធវាយតម្លៃទទួលស្គាល់គុណភាពតឹងរ៉ឹងរបស់ខ្លួនដែលភ្ជាប់ទៅនឹងការវិនិយោគជាបន្តបន្ទាប់។

## បច្ចុប្បន្នភាពគម្រោង

កម្មវិធីសាលាជំនាន់ថ្មីបានបញ្ចប់ប្រតិបត្តិការឆ្នាំទី៨ របស់ខ្លួន ដោយមានការគាំទ្រថវិកាពីក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងអំឡុងពេលឆ្នាំនេះ ប្រព័ន្ធ NGS បានបន្តពង្រឹងប្រតិបត្តិការផ្ទៃក្នុងរបស់ខ្លួន ដោយផ្តោតលើផ្នែកសំខាន់ៗមួយចំនួន រួមទាំងការកែលម្អការគ្រប់គ្រងហិរញ្ញវត្ថុតាមសាលារៀន ការទទួលស្គាល់គុណភាពអប់រំសាលារៀន ការពិនិត្យតាមដាន និងការវាយតម្លៃ។ ប្រព័ន្ធ NGS ក៏បន្តផ្តល់នូវវេទិកាដ៏សំខាន់មួយដល់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអនុវត្តគំនិតផ្តួចផ្តើមពិសោធន៍ថ្មីៗ ដូចជាកម្មវិធីបង្កើតជំនាញបច្ចេកវិទ្យាហ្គេម និងការអភិវឌ្ឍសៀវភៅណែនាំបណ្តុះបណ្តាល ទំនើបៗ ដូចជាកម្មវិធីដែលទើបតែបង្កើតស្តីពី **"ការអនុវត្តវិធីសាស្ត្រការងារគម្រោង"**។

## ព្រឹត្តិការណ៍ធំៗឆ្នាំ២០២៣

- **ការពន្លឿននិរន្តរភាព៖** ការរួមចំណែករបស់ឪពុកម្តាយចំពោះសាលាជំនាន់ថ្មីបានបន្តបំបែកកំណត់ត្រាឈានដល់ ១.៨ លានដុល្លារក្នុងឆ្នាំ២០២៣។
- **ការថយចុះតម្លៃឯកតា៖** តម្លៃឯកតាបានបន្តធ្លាក់ចុះក្នុងអំឡុងឆ្នាំនេះ ដោយសារការគាំទ្រពីមាតាបិតាសម្រាប់កម្មវិធីបានកើនឡើងយ៉ាងខ្លាំង។
- **ការបង្កើតសាលាឧបសម្ព័ន្ធរបស់វិទ្យាល័យព្រះស៊ីសុវត្ថិនៅវិទ្យាល័យយុគន្ធរ៖** ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចដាក់កម្មវិធីសាលារៀនជំនាន់ថ្មីនៅវិទ្យាល័យយុគន្ធរ ក្នុងទម្រង់ជាឧបសម្ព័ន្ធរបស់វិទ្យាល័យព្រះស៊ីសុវត្ថិទៅក្នុងបរិវេណវិទ្យាល័យយុគន្ធរ ដែលបង្កើតបានជាសាលារៀនជំនាន់ថ្មីទី១១ ក្នុងប្រព័ន្ធ *NGS*។
- **ចំនួនសិស្សកើនឡើងខ្លាំង៖** ចំនួនសិស្សដែលបានចុះឈ្មោះក្នុងប្រព័ន្ធ *NGS* បានបន្តកើនឡើងនៅឆ្នាំនេះ ឈានដល់សិស្សសរុប ៩.១៨៧នាក់ កើនឡើងពីសិស្ស ៧.៩៧០នាក់ក្នុងឆ្នាំ២០២២ ឬកើនឡើង១៥%។
- **សន្និសីទអន្តរជាតិស្តីពីសាលារៀនស្វយ័ត៖** ការិយាល័យ *NGS* បានរៀបចំសន្និសីទអន្តរជាតិដ៏ធំមួយ ដើម្បីលើកកម្ពស់បញ្ញត្តិនៃសាលារៀនស្វយ័តមិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងនៅក្នុងតំបន់ផងដែរ។ តំណាងមកពីប្រទេសមួយចំនួន រួមទាំងសិង្ហបុរី ថៃ និងឡាវ បានធ្វើបទបង្ហាញគួរឱ្យទាក់ទាញអារម្មណ៍ ហើយសន្និសីទបានដាក់មូលដ្ឋានគ្រឹះសម្រាប់ការបង្កើតលេខាធិការដ្ឋាន *NGS* អន្តរជាតិ។
- **ការបញ្ចប់សៀវភៅបណ្តុះបណ្តាលវិធីសាស្ត្រសិក្សាបែបគម្រោង៖** ក្រុមការងារ *NGS* បានអនុវត្តសកម្មភាពថ្មីដ៏សំខាន់មួយ ដើម្បីផលិតសៀវភៅណែនាំបណ្តុះបណ្តាលដែលផ្តោតលើវិធីសាស្ត្រការងារគម្រោង។ សៀវភៅនេះបានរៀបចំជាប្រព័ន្ធ និងចងក្រងឯកសារចំណេះដឹង និងការអនុវត្តនៅក្នុងការងារគម្រោងដែលត្រូវបានបង្កើតឡើងដោយសាលារៀនជំនាន់ថ្មី។
- **ផែនការពង្រីក៖** ការកើនឡើងនៃការគាំទ្រមាតាបិតាចំពោះប្រព័ន្ធ *NGS* បានរំដោះធនធានដែលផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡាសម្រាប់ការចំណាយលើការអនុវត្ត។ ជាលទ្ធផល ក្រសួងអប់រំ យុវជន និងកីឡា បានឯកភាពគ្នាក្នុងការអនុញ្ញាតឱ្យកម្មវិធីពង្រីក២សាលាថ្មីថែមទៀត។
- **ពិន្ទុសូន្យក្នុងតេស្ត *EGRA* បានធ្លាក់ចុះមកតិចជាង ៩%៖** ការធ្វើតេស្ត *EGRA* នៅក្នុងសាលារៀនជំនាន់ថ្មី បានបង្ហាញថា កុមារនៅក្នុងសាលាបឋមសិក្សា *NGS* មានអត្រាអានខ្ពស់បំផុតជាងគម្រោងអភិវឌ្ឍន៍ណាមួយក្នុងប្រទេសកម្ពុជា។ កុមារស្ទើរតែទាំងអស់អាចអានពាក្យនៅថ្នាក់ទី១ សូម្បីតែនៅសាលាជនបទក៏ដោយ។ នេះប្រៀបធៀបជាមួយនឹងពិន្ទុអានថ្នាក់ជាតិ ដែល ៥៨% នៃកុមារថ្នាក់ទី១ មិនចេះអានសូម្បីតែមួយពាក្យបន្ទាប់ពីការសិក្សាពេញមួយឆ្នាំ។

## សកម្មភាពសំខាន់ៗក្នុងឆ្នាំ២០២៣

- **ការពង្រីកវគ្គសិក្សាមនុស្សយន្តនៅក្នុងសាលារៀនជំនាន់ថ្មីទាំងអស់៖** បន្ទាប់ពីការសាកល្បងជោគជ័យនៅវិទ្យាល័យ ហ៊ុន សែន កំពង់ចាមក្នុងឆ្នាំ២០២២ ប្រព័ន្ធ NGS បានពង្រីកកម្មវិធីមនុស្សយន្តដល់សាលារៀនទាំងអស់នៅឆ្នាំ២០២៣។
- **ការប្រឹក្សាគរុកោសល្យគ្រូបង្រៀន៖** ការចាប់ផ្តើមនៃការបង្រៀនតាមសាលារៀនបានបន្តបង្កើនល្បឿននៅឆ្នាំ២០២២ ដោយមានគ្រូប្រឹក្សាគរុកោសល្យសរុបចំនួន ៣៨នាក់ ត្រូវបានបែងចែកទៅឱ្យប្រព័ន្ធ NGS។
- **ការអភិវឌ្ឍសៀវភៅបណ្តុះបណ្តាល៖** បុគ្គលិក NGS បានបន្តយកចិត្តទុកដាក់យ៉ាងខ្លាំងលើការបង្កើតសៀវភៅបណ្តុះបណ្តាលបច្ចេកទេសថ្មីៗលើប្រធានបទសំខាន់ៗ ដូចជា វិធីសាស្ត្រសិក្សាបែបគម្រោង ការសិក្សាចល័ត និងការគិតបែបគណនា។
- **ការបង្កើតជំនាញបច្ចេកវិទ្យាហ្គេម៖** អង្គការ ខេប បានរកមូលនិធិសម្រាប់គំនិតផ្តួចផ្តើមថ្មីមួយទាក់ទងនឹងបច្ចេកវិទ្យាហ្គេម ដែលជាសកម្មភាពមួយដែលកំពុងរីកចម្រើនលឿនបំផុតនៅក្នុងវិស័យ ICT។ គំនិតផ្តួចផ្តើមនេះត្រូវបានកំណត់រចនាសម្ព័ន្ធជាគំនិតផ្តួចផ្តើមបង្កើនល្បឿនអភិវឌ្ឍជំនាញ ដើម្បីជួយក្រសួងអប់រំ យុវជន និងកីឡា អនុវត្តតាមការរំពឹងទុក ដើម្បីពន្លឿនការបណ្តុះបណ្តាលយុវជនកម្ពុជាឱ្យឆ្លើយតបនឹងបញ្ហាប្រឈមនៃសតវត្សរ៍ទី២១។
- **ការវាយតម្លៃទទួលស្គាល់គុណភាព និងការធ្វើរបាយការណ៍៖** ការិយាល័យទទួលស្គាល់គុណភាពអប់រំ NGS បាននឹងកំពុងធ្វើការយ៉ាងយកចិត្តទុកដាក់ដើម្បីវាយតម្លៃសាលារៀនទាំងអស់ និងចេញរបាយការណ៍ និងអនុសាសន៍ទៅកាន់ក្រុមប្រឹក្សាភិបាល NGS ដែលទទួលបន្ទុកផ្នែកការទទួលស្គាល់គុណភាព។ សាលារៀនទាំងអស់បានឆ្លងផុតតម្រូវការទទួលស្គាល់គុណភាព លើកលែងតែសាលារៀនមួយ។
- **ដំណើរទស្សនកិច្ចទៅកាន់ប្រទេសថៃ៖** ជាផ្នែកនៃដំណើរការអភិវឌ្ឍន៍គ្រូបង្រៀន កម្មវិធី NGS ជួយរៀបចំទស្សនកិច្ចសិក្សាទៅសាលារៀនក្នុងប្រទេសថៃសម្រាប់គ្រូបង្រៀន NGS។ ក្នុងខែកក្កដា ឆ្នាំ២០២៣ គ្រូបង្រៀនជិត២០០នាក់បានទៅទស្សនកិច្ចសិក្សាសាលារៀននៅប្រទេសថៃក្នុងខេត្ត Buriram។

***ការបោះពុម្ពថ្មីស្តីពីវិធីសាស្ត្រសិក្សាបែបគម្រោង៖** ការិយាល័យ NGS បានបង្កើតសៀវភៅបណ្តុះបណ្តាលថ្មីស្តីពីវិធីសាស្ត្រការសិក្សាបែបគម្រោង ដែលមានសារៈសំខាន់ចំពោះប្រព័ន្ធអប់រំ។ **"ការអនុវត្តសៀវភៅបណ្តុះបណ្តាលការងារគម្រោង"** មានគោលបំណងជួយអ្នកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា គ្រប់លំដាប់ថ្នាក់ ក្នុងការលើកកម្ពស់ការបង្រៀននិងរៀនបែបការងារគម្រោងនៅក្នុងសាលារៀនទាំងអស់ ដើម្បីលើកកម្ពស់បំណិនគិតស៊ីជម្រៅ និងបង្កើតថ្មី។ ➔*



*↑ **សិស្សបង្ហាញការងារគម្រោងក្នុងពិធីសម្ពោធ៖** សិស្សមកពីទូទាំងប្រព័ន្ធ NGS បង្ហាញគម្រោងរបស់ពួកគេជូនរដ្ឋមន្ត្រីក្រសួងអប់រំក្នុងពិធីសម្ពោធឯកសារបណ្តុះបណ្តាលការសិក្សាបែបគម្រោង។*






*← **ការវិនិយោគថ្មីលើការបង្កើតសាលប្រជុំ៖** ប្រព័ន្ធ NGS បានធ្វើការវិនិយោគបន្ថែមក្នុងការបង្កើតសាលប្រជុំថ្មីសម្រាប់សាលាចំនួនពីរនៅវិទ្យាល័យគោកព្រីង និងបឋមសិក្សាព្រះរាជអគ្គមហេសី ។ សាលប្រជុំថ្មីនេះជួយសម្រួលយ៉ាងខ្លាំងដល់ការកសាងសមត្ថភាពសិស្ស និងគ្រូបង្រៀន។*

## សមិទ្ធផលសំខាន់ៗរបស់ NGS

សាលារៀនជំនាន់ថ្មីបានបន្តផ្តល់នូវលទ្ធផលខ្លាំងទាក់ទងនឹងគុណភាពចម្រុះ ដែលលើសពីពិន្ទុតេស្ត។ សិស្សជាងមួយពាន់នាក់បានទទួលមេដាយមាស ប្រាក់ និងសំរិទ្ធក្នុងឆ្នាំ២០២៣ ខណៈពេលដែលសាលារៀនបង្ហាញពីអត្រាខ្ពស់នៃការឆ្លងភូមិសិក្សាទៅសាកលវិទ្យាល័យ និងអត្រាបោះបង់ការសិក្សាទាប។ លទ្ធផលបែបនេះជួយបង្ហាញអំពីភាពត្រឹមត្រូវនៃការវិនិយោគខ្ពស់។




## ការស្រាវជ្រាវជាក់ស្តែងអំពី NGS

ក្នុងអំឡុងឆ្នាំសិក្សា អង្គការ ខេប បានបោះជំហានដំបូងដ៏សំខាន់មួយដើម្បីបង្កើតលេខាធិការដ្ឋានអន្តរជាតិ NGS ដែលនឹងទទួលខុសត្រូវក្នុងការសម្របសម្រួលការសិក្សាជាក់ស្តែងលើសាលារៀនស្វយ័តទូទាំងតំបន់ និងផ្សព្វផ្សាយគំនិតតាមរយៈបណ្តាញ និងការបោះពុម្ពផ្សាយ។ ការបោះពុម្ពលើកដំបូងត្រូវបានចេញផ្សាយនៅខែកញ្ញា ឆ្នាំ២០២៣ ជាមួយនឹងអត្ថបទស្រាវជ្រាវចំនួន ១៥។

### កត្តាវាស់វែងសំខាន់ៗរបស់កម្មវិធីសាលារៀនជំនាន់ថ្មី (២០២២-២០២៣)

| កត្តាវាស់វែង | NGS | ថ្នាក់ជាតិ |
|---|---|---|
| ១. អត្រាប្រឡងជាប់បាក់ឌុប (ក្នុងចំណោមសិស្សផ្នែកវិទ្យាសាស្ត្រ)៖ | ៧៧% | ៦៨% |
| ២. សិស្សដែលប្រឡងជាប់បាក់ឌុបមាននិទ្ទេស A, B, ឬ C៖ | ៣៩% | ២០% |
| ៣. អត្រាឆ្លងភូមិសិក្សាទៅសាកលវិទ្យាល័យ៖ | ៩២% | ១៣,៦៩%* |
| ៤. សិស្សដែលទទួលបានមេដាយ/ពានរង្វាន់៖ | ១៤២៣ | គ្មាន |
| ៥. សិស្សដែលសិក្សា ICT ៣ ម៉ោង/សប្តាហ៍ ឬច្រើនជាងនេះ៖ | ១០០% | ០% |
| ៦. អត្រាសិស្សបោះបង់ការសិក្សា | ១,១% | អនុ.វិ.: ១៦,៦%<br>វិ.: ១៨,៥% |
| ៧. សាលាមធ្យមសិក្សាដែលបានទទួលស្គាល់គុណភាព៖ | ១០០% | គ្មាន |
| ៨. គ្រូបង្រៀនមធ្យមសិក្សាដែលមានសញ្ញាបត្រ ៤ ឆ្នាំ ឬខ្ពស់ជាងនេះ៖ | ៩០% | ៤៣% |
| ៩. គ្រូបង្រៀនដែលបានបំពេញផែនការគន្លងអាជីព៖ | ១០០% | គ្មាន |

*ការចុះឈ្មោះសរុប (ឧត្តមសិក្សា)
ប្រភព: MoEYS, ២០២៣; EMIS, ២០២៣; ធនាគារពិភពលោកឆ្នាំ ២០១៨



**ការបង្កើនការគាំទ្រសម្រាប់ការរៀនបែបសហការ៖** *គ្រូប្រឹក្សាគរុកោសល្យនៅក្នុងសាលាបឋមសិក្សាបាននិងកំពុងពង្រឹងការគាំទ្ររបស់ពួកគេដើម្បីលើកកម្ពស់ការរៀនបែបសហការនៅក្នុងថ្នាក់រៀន។*



**ឧបសម្ព័ន្ធរបស់វិទ្យាល័យព្រះស៊ីសុវត្ថិ៖** *របនាសម្ព័នអាគារថ្មី និងទំនើបមួយត្រូវបានផ្តល់ទៅឱ្យវិទ្យាល័យយុគន្ធរ ដោយការិយាល័យនាយករដ្ឋមន្ត្រី ដើម្បីធ្វើជាទីតាំងពង្រីកកម្មវិធី NGS ទៅក្នុងសាលារៀន។ ឧបសម្ព័ន្ធនេះត្រូវបានគ្រប់គ្រងដោយក្រុមអ្នកគ្រប់គ្រងពិសេសនៅវិទ្យាល័យព្រះស៊ីសុវត្ថិជំនាន់ថ្មី។*



**ការទទួលបានពានរង្វាន់ដ៏ច្រើន៖** *សិស្ស NGS បន្តទទួលបានពានរង្វាន់សិក្សារាប់រយ មិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែមាននៅតាមប្រទេសក្នុងតំបន់ផងដែរ។*






**ការអភិវឌ្ឍបច្ចេកវិទ្យាហ្គេមថ្មី៖** *សិស្សនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ចូលរួមក្នុងការសាកល្បងថ្មី ដើម្បីរៀនជំនាញបច្ចេកវិទ្យាហ្គេម ដែលនឹងជួយពួកគេធ្វើការនៅក្នុងវិស័យ ICT ដែលកំពុងរីកចម្រើនលឿនបំផុត។ ការសាកល្បងនេះបានបង្កើតកម្មវិធីសិក្សាថ្មីតែមួយគត់ដែលបញ្ចូលក្នុងសាលារៀនជំនាន់ថ្មី ដែលជាកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា លើកកម្ពស់សកម្មភាពបង្កើនល្បឿនអភិវឌ្ឍន៍ជំនាញដោយសហការជាមួយវេទិកាសេដ្ឋកិច្ចពិភពលោក។*

**ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់នាយកសាលា NGS៖** *នាយកសាលាទាំងអស់ ក៏ដូចជាបុគ្គលិកគ្រប់គ្រងសំខាន់ៗនៅក្នុងការិយាល័យ NGS បានធ្វើដំណើរទៅប្រទេសថៃក្នុងខែសីហា ដើម្បីចូលរួមក្នុងសិក្ខាសាលាបណ្តុះបណ្តាលភាពជាអ្នកដឹកនាំពិសេសជាមួយ Ajarn Wichian Chayabang ដែលជាអ្នកអប់រំឈានមុខរបស់ប្រទេសថៃ។ សិក្ខាសាលានេះត្រូវបានឧបត្ថម្ភដោយមូលនិធិ Lamplaimat នៃប្រទេសថៃ។*





**ការចុះវាយតម្លៃការទទួលស្គាល់គុណភាពសាលារៀន៖** *ក្រុមការងារវាយតម្លៃទទួលស្គាល់គុណភាពអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ចុះទៅពិនិត្យការអនុលោមតាមលក្ខណៈវិនិច្ឆ័យនៃការអនុវត្តរបស់ NGS។ សកម្មភាពនៃការចុះវាយតម្លៃទទួលស្គាល់គុណភាពនេះមានតួនាទីសំខាន់កាន់តែខ្លាំងឡើងនៅក្នុង NGS។*

# មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC)

*“ការផ្តល់សិទ្ធិអំណាចដល់អ្នកអប់រំប្រកបដោយក្រមសីលធម៌ និងការប្រតិបត្តិដោយផ្អែកលើភស្តុតាង”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | ក្រសួងអប់រំ យុវជន និងកីឡា |
| **អ្នកទទួលផលផ្ទាល់** | គរុនិស្សិតចំនួន២៥រូប |
| **ថវិកាឆ្នាំសិក្សា២០២៣** | ៦៩៦.១៥០.០០០រៀល |
| **តម្លៃឯកតាក្នុងគរុនិស្សិតម្នាក់** | ២៧.៨៤៦.០០០រៀល |
| **ខេត្តគោលដៅ** | ទីតាំងគរុនិស្សិតថ្នាក់ជាតិ |
| **ស្រុកគោលដៅ** | មិនមាន |
| **សាលាគោលដៅ** | គ្រឹះស្ថានឧត្តមសិក្សា |
| **កាលបរិច្ឆេទចាប់ផ្តើម** | ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩ |
| **កាលបរិច្ឆេទបញ្ចប់** | មិនកំណត់ |

## ក្របខ័ណ្ឌកម្មវិធីសិក្សា

NGPRC ផ្តល់នូវការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ដល់គរុនិស្សិតដែលត្រូវបានជ្រើសរើសដោយមានការប្រកួតប្រជែង និងជាគ្រូដែលមានឧត្តមភាព។ គរុនិស្សិតសិក្សាក្របខ័ណ្ឌកម្មវិធីសិក្សាមាន**៤មុខវិជ្ជា**សំខាន់ៗ ដែលរួមមានម៉ូឌុលសរុបចំនួន៣០ និង ៨៩ ប្រធានបទរង។ គរុនិស្សិតសិក្សាទ្រឹស្តីរយៈពេល៩ខែ ដែលក្នុងនោះរួមមានការចុះកម្មសិក្សាប្រតិបត្តិរយៈពេល៣ខែជាពេលដែលគរុនិស្សិតនឹងអនុវត្តជំនាញប្រឹក្សាគរុកោសល្យតាមរយៈសុសវែរអប់រំថ្មីបំផុត។ កម្មវិធីសិក្សានេះត្រូវបានរចនាដោយមានកាត់តម្រឹម និងរួមបញ្ចូលមុខងារបច្ចេកវិទ្យាជាច្រើន ដើម្បីនាំយកការអប់រំកម្ពុជាចូលក្នុងសតវត្សរ៍ទី២១។ ទន្ទឹមគ្នានេះផងដែរ កម្មវិធីសិក្សាមានដាក់បញ្ចូលកម្មសិក្សាបន្ថែមមួយទៀត នោះគឺក្លឹបសិក្សាជំនាញទន់ និងភាពជាអ្នកដឹកនាំ។ ព័ត៌មានលម្អិតនៃមុខវិជ្ជានីមួយៗក្នុងកម្មវិធីសិក្សាមានចំនួន៤សំខាន់ៗដូចខាងក្រោម៖

១) **សីលធម៌វិជ្ជាជីវៈ និងការប្រឹក្សាគរុកោសល្យ៖** ម៉ូឌុលទាំងនេះគ្របដណ្តប់ទៅលើមូលដ្ឋានគ្រឹះសម្រាប់ក្រមសីលធម៌ក្នុងវិជ្ជាជីវៈបង្រៀន និងប្រើប្រាស់សម្ភារអន្តរកម្មជាច្រើនដូចជាវីដេអូ និងសុសវែរ ដើម្បីបង្កើតការពិភាក្សាជេញដោលពីបញ្ហា។

២) **ការស្រាវជ្រាវអប់រំ៖** ម៉ូឌុលទាំងនេះជួយដល់គរុនិស្សិតឱ្យស្គាល់ពីរបៀបនៃការសិក្សាស្រាវជ្រាវ និងអានអត្ថបទជាច្រើនដែលពួកគេពើបប្រទះ ដែលជាផ្នែកជួយដល់កិច្ចការអានរបស់ពួកគេ។

៣) **បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងវិស័យអប់រំ៖** ម៉ូឌុលទាំងនេះណែនាំដល់គរុនិស្សិតឱ្យស្គាល់កម្មវិធីសុសវែរអប់រំជាច្រើន ដែលត្រូវបានប្រើប្រាស់ក្នុងបរិបទសាលារៀនជំនាន់ថ្មី ហើយជាពិសេសនោះ គឺសុសវែរថ្មីមួយដែលមានឈ្មោះថា Observic ដែលប្រើប្រាស់នូវបច្ចេកទេសដើម្បីជួយគាំទ្រគ្រូក្នុងការកែលម្អដល់ការអនុវត្តការបង្រៀនផ្ទាល់របស់ពួកគេ។

៤) **វិធីសាស្ត្របង្រៀន៖** ម៉ូឌុលទាំងនេះជួយគរុនិស្សិតឱ្យយល់ដឹងពីរបៀបដែលវិធីសាស្ត្របង្រៀនសំខាន់ៗ ដូចជា ការរៀនបែបស្ថាបនា ការរៀនបែបសហការ និងការងារគម្រោង ដែលគេប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពក្នុងថ្នាក់រៀនសាលារៀនជំនាន់ថ្មី។




*មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីបំពាក់ដោយបន្ទប់សិក្សាទំនើបសម្រាប់គរុនិស្សិតក្នុងការសិក្សា ដែលរួមមានបន្ទប់សិក្ខាសាលាចំនួនពីរ និងសាលប្រជុំមួយ ។*

## សង្ខេបភាពកម្មវិធី

**គោលបំណង៖** *ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ដើម្បីជួយដល់ការពង្រីកសាលារៀនជំនាន់ថ្មីជាសាលារដ្ឋស្វយ័តដែលទទួលបានការវិនិយោគខ្ពស់ពីរដ្ឋាភិបាល និងទាមទារគ្រូបង្រៀនមានស្តង់ដារខ្ពស់ធ្វើការនៅទីនោះ។*

**ចក្ខុវិស័យ៖** ចក្ខុវិស័យរបស់មជ្ឈមណ្ឌល គឺដើម្បីផ្លាស់ប្តូរចរិតលក្ខណៈសាលារៀននៅប្រទេសកម្ពុជាឱ្យមានចលនាយន្តការជួយទ្រទ្រង់តាមរយៈគ្រូប្រឹក្សាគរុកោសល្យដែលមានបទពិសោធន៍ប្រចាំនៅសាលារៀន ដែលជួយបណ្តុះគ្រូបង្រៀនឱ្យរីកចម្រើនទាំងវិជ្ជាជីវៈ និងសីលធម៌ ធ្វើឱ្យសាលារៀនរបស់ពួកគាត់មានភាពរីករាយ និងជាកន្លែងទាក់ទាញការសិក្សា។

**បេសកកម្ម៖** មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីធ្វើការស្រាវជ្រាវ ដែលនឹងផ្តល់ព័ត៌មានកាន់តែប្រសើរដល់ការបណ្តុះបណ្តាលគ្រូបង្រៀនដែលមានសមត្ថភាពរឹតតែរឹងមាំ ស្វែងយល់ពីរបៀបផ្តល់ប្រឹក្សាគរុកោសល្យដល់គ្រូបង្រៀនផ្សេងទៀតតាមវិធីមានប្រសិទ្ធភាព និងគ្មានការគំរាមកំហែង។

## សកម្មភាពសំខាន់ៗ

- ក្នុងឆ្នាំ២០២៣នេះ មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីត្រូវបានផ្តល់សិទ្ធិស្របច្បាប់ដោយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ ដល់គរុនិស្សិត (ជំនាន់ទី៤) ដែលនឹងត្រូវបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រឹមតែរយៈពេលពេញមួយឆ្នាំតែប៉ុណ្ណោះ។ មជ្ឈមណ្ឌលបានអនុវត្តកម្មសិក្សាប្រតិបត្តិដោយផ្ទាល់ ក្នុងបរិបទពីរផ្សេងគ្នាគឺបរិបទសាលារៀនជំនាន់ថ្មី និងសាលារៀនធម្មតា ដោយផ្តល់ការអនុវត្តជាក់ស្តែងសម្រាប់គរុនិស្សិតជំនាន់ទី៤នេះ។
- បានរៀបចំ និងសហការរៀបចំសន្និសីទ និងវេទិកាអន្តរជាតិជាច្រើន ដូចជាសន្និសីទអន្តរជាតិស្តីពី សាលារៀនស្វយ័តជាគន្លឹះនៃកំណែទម្រង់អប់រំ សន្និសីទអន្តរជាតិលើកទី៣ស្តីពី ការប្រឹក្សាគរុកោសល្យ(CICME-2023) វេទិកាការអប់រំស្ទែម (STEM) ជាដើម។
- កិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីលើកកម្ពស់ការអប់រំស្ទែម (STEM) និងការផ្តល់ប្រឹក្សាគរុកោសល្យ៖ មូលនិធិ HEAD (ប្រទេសសឹង្ហបុរី) EMCAST (ប្រទេសកូរ៉េ) សាកលវិទ្យាល័យ Texas A&M (សហរដ្ឋអាមេរិក)។ល។
- ទន្ទឹមនឹងគ្នានេះផងដែរ មជ្ឈមណ្ឌលកំពុងសហការជាមួយសាកលវិទ្យាល័យ Texas A&M សហរដ្ឋអាមេរិក ដើម្បីធ្វើការស្រាវជ្រាវប្រតិបត្តិលើប្រធានបទជាច្រើន ដែលនឹងចងក្រងជាកម្រងស្នាដៃស្រាវជ្រាវក្នុងការបោះពុម្ពដែលមានលក្ខណៈវិជ្ជាជីវៈដូចដែលបានគ្រោងទុក។
- មជ្ឈមណ្ឌលមានវឌ្ឍនភាពយ៉ាងឆាប់រហ័ស ដើម្បីក្លាយជាកំណប់ទ្រព្យដ៏សំខាន់របស់វិទ្យាស្ថានជាតិអប់រំ តាមរយៈការជួយគាំទ្រដល់វិទ្យាស្ថានក្នុងដំណើការកំណែទម្រង់ជាច្រើនដូចជា ជួយគាំទ្រដំណើរការកំណែទម្រង់សាលាអនុវត្ត គាំទ្រការកែលម្អកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ កំណែទម្រង់នាយកដ្ឋានស្រាវជ្រាវ បង្កើតក្លឹបសិក្សានិងសហគមន៍សិក្សាវិជ្ជាជីវៈជាដើម។

## ផលជះនៃគម្រោង

- **បង្កើតទម្រង់រៀនបែបសិក្ខាសាលាក្នុងការអប់រំកម្រិតឧត្តមសិក្សា៖** គរុនិស្សិតទាំងអស់ត្រូវសិក្សាក្នុងទម្រង់សិក្ខាសាលាដែលមានចំនួនមិនលើសពី១៣នាក់ក្នុងមួយថ្នាក់។ ការពិភាក្សាការងារជាក្រុម និងការធ្វើបទបង្ហាញជាញឹកញាប់គឺជាលក្ខណៈពិសេសនៃវគ្គសិក្សា ដែលមានលក្ខណៈពិសេសសម្រាប់ការងារអប់រំកម្រិតឧត្តមសិក្សានៅកម្ពុជា។
- **ការដាក់បញ្ចូលបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(ICT) សម្រាប់ជំនួយដល់ការប្រឹក្សាគរុកោសល្យ៖** គរុនិស្សិតទាំងអស់ត្រូវបានបំពាក់បំប៉ន និងបណ្តុះបណ្តាលឱ្យចេះប្រើបច្ចេកវិទ្យា(ICTs) សម្រាប់ការអប់រំ ដែលក្នុងនោះរួមមាន៖ ហ្គូហ្គលក្លាសរូម(Google Classroom) ហ្សូមមីតធីង (Zoom Meeting) ហ្គូហ្គលមីត (Google Meet) អហ្វសឺវីក (Observic) វ៉ុលហ្វ្រេម(Wolfram)។ល។ ដើម្បីជួយដល់គ្រូបង្រៀនទាំងអស់តាមរយៈការជួបផ្ទាល់ និងតាមអនឡាញ។
- **បង្កើតទម្រង់ប្រឹក្សាគរុកោសល្យតាមសាលារៀន៖** មជ្ឈមណ្ឌលបាននឹងកំពុងបង្កើតវិធីសាស្ត្រថ្មីមួយដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនតាមរយៈការបង្កើតក្របខណ្ឌមួយដែលជួយទ្រទ្រង់ដល់ការប្រឹក្សាគរុកោសល្យតាមសាលារៀន។
- **ការងារពាក់ព័ន្ធនឹងគម្រោងស្រាវជ្រាវ៖** គរុនិស្សិតក៏មានឱកាសធ្វើជាជំនួយការស្រាវជ្រាវសម្រាប់គម្រោងស្រាវជ្រាវផ្សេងៗជាច្រើន ដែលផ្តល់ជូនដោយមជ្ឈមណ្ឌល។
- **ការបញ្ជូនគ្រូប្រឹក្សាគរុកោសល្យតាមស្ថាប័នផ្សេងៗក្រៅពីជំនាន់ថ្មី៖** គិតត្រឹមដំណាច់ឆ្នាំ២០២៣ មជ្ឈមណ្ឌលបានចែកសញ្ញាបត្រជូនដល់បេក្ខជនជ័យលាភីចំនួន១០៣រូប។ ក្នុងរយៈពេលបួនឆ្នាំចុងក្រោយនេះ មានគ្រូប្រឹក្សាគរុកោសល្យចំនួន៤៥រូបក្នុងចំណោមគ្រូប្រឹក្សាគរុកោសល្យទាំងអស់ ត្រូវបានបញ្ជូនទៅតាមសាលារៀនជំនាន់ថ្មី ខណៈដែលនៅសល់២៥រូបផ្សេងទៀតត្រូវបានចាត់តាំងទៅតាមសាលាគរុកោសល្យ និងចំណែក៣៣រូបទៀតត្រូវបានចាត់តាំងទៅប្រឹក្សាតាមសាលារៀនសាកល្បង ដែលគាំទ្រដោយកម្មវិធីអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ ដែលគាំទ្រហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។
- **ការជ្រើសរើសគរុនិស្សិតសម្រាប់ជំនាន់ទី៥៖** គរុនិស្សិតចំនួន៣១រូបត្រូវបានជ្រើសរើសសម្រាប់ការសិក្សានៅក្នុងជំនាន់ទី៥ដែលជាឆ្នាំទី៥នៃការប្រតិបត្តិការរបស់មជ្ឈមណ្ឌលក្នុងឆ្នាំ២០២៣។
- **ការគាំទ្របន្តដល់គ្រូប្រឹក្សាគរុកោសល្យ៖** មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីបន្តផ្តល់ការគាំទ្រដល់គ្រូប្រឹក្សាគរុកោសល្យនៅគ្រឹះស្ថានសិក្សាគោលដៅតាមរយៈការបង្កើតសមាគមគ្រូប្រឹក្សាគរុកោសល្យកម្ពុជា (CAM)។ សមាគម CAM បានដើរតួជាសមាគមគ្រូប្រឹក្សាគរុកោសល្យវិជ្ជាជីវៈ។

| បណ្តុះបណ្តាល & បែងចែកប៉ុស្តិ៍ | ជំនាន់ទី១ | ជំនាន់ទី២ | ជំនាន់ទី៣ | ជំនាន់ទី៤ | ជំនាន់ទី៥ | សរុប |
|---|---|---|---|---|---|---|
| បណ្តុះបណ្តាល | ២៥ | ៣២ | ២១ | ២៥ | ៣១ | |
| បែងចែកប៉ុស្តិ៍ NGS/គ្រឹះស្ថានសិក្សាផ្សេងៗ | ១៧/៨ | ១៩/១៣ | ៧/១៤ | ២/២៣ | មិនទាន់កំណត់ | ៤៥/៥៨ |
| ចាកចេញពីកម្មវិធី | ៤ | | | | -- | ៤% |

## បច្ចុប្បន្នភាពគម្រោង

- មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីបានជ្រើសរើសបេក្ខជនចំនួន៣១ នាក់ ក្នុងឆ្នាំ២០២៣ ដែលមានជំនាញចំនួន៤ផ្សេងគ្នា៖ ភាសាអង់គ្លេស វិទ្យាសាស្ត្រសង្គម វិទ្យាសាស្ត្រពិត និងការអប់រំកម្រិតបឋមសិក្សា។
- ក្លឹបសិក្សាស្រាវជ្រាវអប់រំ ត្រូវបានបង្កើតឡើងដើម្បីជួយគរុនិស្សិតក្នុងដំណើរការសរសេរបញ្ចប់សារណារខ្លី។
- ស្របពេលជាមួយគ្នានេះដែរ កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំត្រូវបានកែលម្អជាលើកទី៤ ដើម្បីបំពេញតម្រូវការរបស់គរុនិស្សិតឱ្យកាន់តែប្រសើរឡើង។ ជាពិសេសឱ្យស្របទៅនឹងកម្មវិធីសិក្សាសាលារៀនជំនាន់ថ្មី ដែលនេះឆ្លុះបញ្ចាំងពីការសិក្សាលើកម្មវិធីពិតជាក់ស្តែងដោយស្វ័យប្រវត្តិ។
- មជ្ឈមណ្ឌលបានអនុវត្ត និងប្រកាន់ខ្ជាប់នូវគោលការណ៍កាត់បន្ថយប្លាស្ទិកដោយលើកកម្ពស់វិធីសាស្ត្រដែលមានអំណោយផលដល់បរិស្ថាន និងជីវៈចម្រុះ។
- មជ្ឈមណ្ឌលបានបង្កើតភាពជាដៃគូវិជ្ជាជីវៈជាមួយស្ថាប័នជាតិ និងអន្តរជាតិល្បីៗជាច្រើន។
- មជ្ឈមណ្ឌលបានរៀបចំស្នើសុំពីក្រសួងមុខងារសាធារណៈ និងការទទួលស្គាល់សម្រាប់គ្រូប្រឹក្សាគរុកោសល្យពីគណៈកម្មការមុខងារសារធារណៈ។
- បន្តជួយគាំទ្រដល់ដំណើរការកំណែទម្រង់នៅវិទ្យាស្ថានជាតិអប់រំ ដូចជា ការគាំទ្រសាលាអនុវត្តរបស់វិទ្យាស្ថាន កែតម្រូវកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ បង្កើតក្លឹបសិក្សានិងសហគមន៍សិក្សាវិជ្ជាជីវៈ និងគាំទ្រដល់នាយកដ្ឋានស្រាវជ្រាវជាដើម។

## រូបភាពសកម្មភាពសំខាន់ៗ



*ការជ្រើសរើសគរុនិស្សិតជំនាន់ទី៥៖ បេក្ខជនសម្រាប់ជំនាន់ទី ៥ ប្រឡងចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់មជ្ឈមណ្ឌលសម្រាប់ឆ្នាំសិក្សា២០២៣។ បេក្ខជនត្រូវបានជ្រើសរើសដោយការប្រកួតប្រជែង តាមរយៈការប្រឡងសំណេរ ការសម្ភាសន៍ផ្ទាល់មាត់ និងការបង្ហាញថ្នាក់រៀន។*



*សន្និសីទអន្តរជាតិលើកទី៣ ស្តីពីការប្រឹក្សាគរុកោសល្យ (CICME-2023) នៅថ្ងៃទី ២២-២៤ ខែវិច្ឆិកា ឆ្នាំ ២០២៣ ក្រោមអធិបតីភាព ឯ.ឧ. បណ្ឌិត អ៊ុម រម្យណី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។*



*ទិវាសម្អាត នៅពេលដែលគរុនិស្សិតជួយសម្អាតអគារមជ្ឈមណ្ឌស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី និងបរិវេណជុំវិញ ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវ។*



*គរុនិស្សិតប្រឹក្សាគរុកោសល្យជំនាន់ទី៥ គឺជាបេក្ខជនដែលត្រូវបានជ្រើសរើសចុងក្រោយចេញពីក្នុងចំណោមបេក្ខជនចំនួន១៨០រូប។*




*សិក្ខាសាលាតម្រង់ទិសសម្រាប់គរុនិស្សិតប្រឹក្សាគរុកោសល្យជំនាន់ទី៥ ស្តីពី «យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំកាត់បន្ថយប្លាស្ទិក» ដែលបានចាប់ផ្តើមអនុវត្តនៅក្នុង NGPRC ចាប់ពីថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០២៣។ ។*



*ការតម្រង់ទិសគរុនិស្សិតស្តីពីការចុះកម្មសិក្សាប្រតិបត្តិប្រឹក្សាគរុកោសល្យនៅសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប និងបឋមសិក្សាព្រះនរោត្តម។*



*ការបោះជំរំ និងសិក្ខាសាលាស្តីពី ជំនាញទន់ និងភាពជាអ្នកដឹកនាំ សម្រាប់គរុនិស្សិតប្រឹក្សាគរុកោសល្យ ជំនាន់ទី៤ នៅរមណីយដ្ឋាន ភូមិសុខារ៉ាវី ខេត្តព្រៃវែង។*

# ២០ គម្រោង កុមារកម្ពុជារីករាយ (HCC)

*"បង្កើតគំរូអប់រំដែលមានគុណភាពខ្ពស់សម្រាប់សាលារៀននៅតំបន់ដាច់ស្រយាលនិងជនបទ"*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | មូលនិធិគីនចាន |
| អ្នកទទួលផលផ្ទាល់ (សរុប) | ២៤ ៨៨៨នាក់ (ស្រី ៩ ៤៩៥នាក់) |
| កម្រិតមត្តេយ្យសិក្សា | ៧៦ (ស្រី ២៧នាក់) |
| កម្រិតបឋមសិក្សា | ២៤ ៨១២នាក់ (ស្រី ៩ ៤៦៨នាក់) |
| ថវិកាឆ្នាំសិក្សា២០២៣ | ៧.២៣៧.៤២៦.០២៩រៀល |
| តម្លៃឯកតាក្នុងសិស្សម្នាក់ | ២៩០.៧៩៩,៨២រៀល |
| ខេត្តគោលដៅ | ៥ (សៀមរាប កំពង់ចាម ត្បូងឃ្មុំ ក្រចេះ រតនគិរី) |
| ស្រុកគោលដៅ | ១៦ |
| សាលាបឋមសិក្សាគោលដៅ | ៥៥ |
| សាលារៀនជុំទី១ | ១២ |
| សាលារៀនជុំទី២ | ១៣ |
| សាលារៀនជុំទី៣ | ១៦ |
| សាលារៀនជុំទី៤ | ១៤ |
| សាលាមត្តេយ្យសិក្សាគោលដៅ | ១ |
| កាលបរិច្ឆេទចាប់ផ្តើម | ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ |
| កាលបរិច្ឆេទបញ្ចប់ | មិនមានពេលបញ្ចប់ |

## គោលបំណងសំខាន់ៗ

១- លទ្ធភាពទទួលបានការអប់រំ (ជាពិសេសសម្រាប់កុមារី និងកុមារដែលងាយរងគ្រោះ) មានភាពប្រសើរឡើងនៅក្នុងតំបន់គោលដៅ។

២- សាលាមានប្រសិទ្ធភាពរបស់សាលា (គុណភាពនៃការអប់រំ) ធ្វើឱ្យមានភាពប្រសើរឡើង តាមរយៈការអភិវឌ្ឍ និងការអនុវត្តកម្មវិធី សាលាកុមារមេត្រីទាំងក្នុងនិងក្រៅថ្នាក់រៀន ទៅតាមតម្រូវការរបស់កុមារងាយរងគ្រោះ ជាពិសេសកុមារី។

៣- សមត្ថភាពអាន និងគណិតវិទ្យារបស់កុមារមានភាពប្រសើរឡើងពីកម្រិតមូលដ្ឋាន ជាពិសេសនៅថ្នាក់ដំបូង (ថ្នាក់ទី ១-៣)។

៤- សមត្ថភាពគ្រប់គ្រងរបស់ដៃគូក្នុងមូលដ្ឋានក្នុងការគ្រប់គ្រងជំនួយអភិវឌ្ឍន៍មានការកើនឡើងតាមរយៈការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ និងគុណភាព ព្រមទាំងការផ្សព្វផ្សាយដល់សហគមន៍។

៥- បង្កើនលទ្ធភាពទទួលបានសេវាមត្តេយ្យសិក្សាប្រកបដោយគុណភាពនៅក្នុងឃុំហាន់ជ័យ។

## បច្ចុប្បន្នភាពគម្រោង

**សាវតារ៖** គម្រោង HCC ជាគម្រោងធំបំផុតមួយរបស់ខេប បើនិយាយពីចំនួនសាលានិងចំនួនសិស្ស ហើយក៏ជាគម្រោងធំបំផុតទី២ បើនិយាយពីថវិកា (បន្ទាប់ពីសាលាជំនាន់ថ្មី)។ គម្រោងនេះមិនធម្មតាដែលមូលនិធិគីនចានបានតាំងចិត្តក្នុងជំនួយបើកចំហរជាជាងក្របខ័ណ្ឌគម្រោងកំណត់ពេលវេលាដ៏តឹងរឹងដូចដែលធម្មតានៅក្នុងគម្រោងដែលផ្តល់មូលនិធិទ្វេភាគីជាច្រើន។

**ដំណើរការប្រក្រតីភាព៖** នៅពេលដែលកូវីដរាតត្បាតកាលពីពីរបីឆ្នាំមុន តែបច្ចុប្បន្ន កម្មវិធីកុមារកម្ពុជារីករាយបានបន្តការវិលមករកភាពប្រក្រតីវិញ ដោយផ្តោតលើការគាំទ្រក្នុងសាលាដោយមិនមានតម្រូវការគាំទ្រដល់ការរៀនសូត្រតាមភូមិ ដូចកាលពីពេលដែលសាលារៀនត្រូវបានបិទក្នុងរយៈពេលយូរនោះទេ។ ជាលទ្ធផល ការវិនិយោគបានងាកទៅរកបញ្ហាសំខាន់ៗ ដូចជា ការអប់រំគ្រូបង្រៀន ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍន៍បណ្ណាល័យ និងការកែលម្អការគ្រប់គ្រងសាលារៀន។ ជាមួយគ្នានេះ កម្មវិធីនេះក៏បានចាប់ផ្តើមពង្រីកវិសាលភាពគ្របដណ្តប់សាលារៀនផងដែរ បន្ទាប់ពីបានផ្អាកអស់រយៈពេល២ឆ្នាំក្នុងអំឡុងពេលកូវីដរាតត្បាត។

**ការបណ្តុះបណ្តាលគ្រូបង្រៀន៖** គម្រោងនេះបានរក្សាការវិនិយោគយ៉ាងធំក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន និងជាពិសេសការធ្វើឱ្យប្រសើរឡើងយ៉ាងខ្លាំងនៃគ្រូបង្រៀនកិច្ចសន្យាដោយប្រើវិធីប្រឹក្សាគរុកោសល្យ។ តាមរយៈការសហការជាមួយមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី គម្រោងនេះអាចទទួលបានគ្រូប្រឹក្សាគរុកោសល្យពេញម៉ោងពីរនាក់ដែលធ្វើការពេញម៉ោងលើការបណ្តុះបណ្តាលគ្រូ និងផ្តល់មតិកែលម្អជាបន្តបន្ទាប់លើការបង្រៀនរបស់ពួកគេតាមរយៈការសង្កេតក្នុងថ្នាក់ធម្មតា។

**ផែនការពង្រីក៖** នៅឆ្នាំ២០២៣ គម្រោង HCC បានបង្កើនចំនួនសាលារៀនគោលដៅពី ៤១ ទៅ ៥៥ សាលាបឋមសិក្សា។ សាលារៀនគោលដៅត្រូវបានរៀបចំជាវដ្តដែលបង្ហាញពីចំនួនឆ្នាំនៃជំនួយអភិវឌ្ឍន៍ដែលសាលានឹងទទួលបាន។ វដ្តនៃការអភិវឌ្ឍអាចមានរយៈពេលពី ៣ ទៅ ៥ ឆ្នាំ អាស្រ័យលើចំនួនជំនួយដែលសាលាត្រូវការ។ វដ្តទី៤ មានសាលាបឋមសិក្សាចំនួន១៤បានកំពុងធ្វើការបណ្តាក់ទុនយ៉ាងច្រើនក្នុងការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនៃថ្នាក់រៀនជាង១០០ នៅឆ្នាំនេះ។ គម្រោងនេះបានចាប់ផ្តើមរៀបចំផែនការសម្រាប់វដ្តទី ៥ ដែលមានសាលារៀនចំនួន ១៥ បន្ថែមទៀតដែលនឹងក្លាយជាសាលាគោលដៅនៅឆ្នាំ២០២៤។

## រូបភាពសកម្មភាព



*ការអប់រំបំណិនជីវិត៖ សិស្សនៅសាលាបឋមសិក្សាសំបួរ អនុវត្តជំនាញមានប្រយោជន៍ដែលបានរៀននៅក្នុងសួនដីវៈចម្រុះរបស់សាលាដែលត្រូវបានបង្កើតឡើងជាផ្នែកមួយនៃវិធីសាស្ត្រអភិវឌ្ឍន៍របស់គម្រោងកុមារកម្ពុជារីករាយ។*




*ក្រសួងអប់រំ យុវជន និងកីឡា ទទួលស្គាល់ជាផ្លូវការនូវការរួមចំណែករបស់មូលនិធិគីនចានដល់ការអប់រំនៅកម្ពុជា៖ នៅខែតុលា ឆ្នាំ២០២៣ ឯកឧត្តម វង កិរុណា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធអគារសិក្សាថ្មី និងសមិទ្ធិផលនានានៅសាលាចំនួន៤១ ដែលបានឧបត្ថម្ភថវិកាដោយមូលនិធិគីនចាន។ លោកតា ហាត់មុត ដឹស៊ីកេ ប្រធានមូលនិធិបានមកពីប្រទេសអាល្លឺម៉ង់ដើម្បីចូលរួមក្នុងពិធីនេះ។*

## សកម្មភាពសំខាន់ៗ

- **ការគាំទ្រសកម្មភាពមត្តេយ្យសិក្សានៅក្នុងទីតាំងមួយសម្រាប់ឃុំហាន់ជ័យ៖** គម្រោងនេះបានគាំទ្រសេវាកម្មមត្តេយ្យសិក្សាដែលមានគុណភាពខ្ពស់នៅក្នុងសាលាសហគមន៍មួយ រួមមាន៖ អាហារសម្រន់នៅសាលារៀន ការបណ្តុះបណ្តាលគ្រូបង្រៀន និងយុទ្ធនាការចុះឈ្មោះចូលរៀន។
- **ការកសាងសមត្ថភាពគ្រូបង្រៀនកិច្ចសន្យា៖** គម្រោងបានជួលបុគ្គលិកពេញម៉ោងពីរនាក់ ដើម្បីផ្តល់ការគាំទ្រយ៉ាងយកចិត្តទុកដាក់ដល់គ្រូបង្រៀនកិច្ចសន្យា ដើម្បីកែលម្អការអនុវត្តគរុកោសល្យរបស់ពួកគេ។
- **ការតាមដានការប្រើប្រាស់ជំនួយសាលា៖** សាលារៀនជាង ២៩ បានទទួលជំនួយសម្រាប់អភិវឌ្ឍកម្មវិធីដោយខ្លួនឯង ដើម្បីលើកកម្ពស់ការអភិវឌ្ឍដែលដឹកនាំដោយភាគីពាក់ព័ន្ធ។
- **បច្ចុប្បន្នភាពស្តីពីការគាំទ្រអ្នកថែទាំសាលា៖** ក្រុមប្រឹក្សាឃុំបានប្តេជ្ញាចិត្តក្នុងការបង់ប្រាក់ឱ្យអ្នកថែទាំសាលា ដើម្បីធានាថាការវិនិយោគដ៏ធំនៅក្នុងហេដ្ឋារចនាសម្ព័ន្ធសាលារៀនអាចទ្រទ្រង់បាន។
- **ការរៀបចំការវាយតម្លៃអំណានថ្នាក់ដំបូងពីក្រុមខាងក្រៅ (EGRA)** នៅដើមគ្រា និងពាក់កណ្តាលគម្រោង និងការវាយតម្លៃគណិតវិទ្យាថ្នាក់ដំបូង (EGMA) ដើម្បីតាមដានផលជះលើលទ្ធផលសិក្សា។
- **ការលើកកម្ពស់ថ្នាក់រៀន៖** រួមទាំងការផ្តល់សម្ភារបង្រៀននិងរៀន ក៏ដូចជាការបណ្តុះបណ្តាលអំពីរបៀបប្រើប្រាស់វាឱ្យមានប្រសិទ្ធភាព។
- **ការបំប៉នភាពជាអ្នកដឹកនាំ និងគ្រប់គ្រង៖** នាយកសាលាបានទទួលការគាំទ្រជាបន្តបន្ទាប់ដើម្បីជួយពួកគេក្នុងការច្នៃប្រឌិត និងធ្វើការកាន់តែជិតស្និទ្ធជាមួយសហគមន៍មូលដ្ឋាន។
- **រៀបចំសកម្មភាពឆ្លើយតបរហ័ស៖** គ្រូបង្រៀនបានទទួលការបង្វឹកពីគម្រោងដើម្បីរៀបចំសកម្មភាពដើម្បីគាំទ្រសិស្សដែលជួបការលំបាកក្នុងការសិក្សា។
- **ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD)៖** ដោយផ្អែកលើគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ឥឡូវនេះ CPD ត្រូវបានគាំទ្រតាមរយៈការវិនិយោគផ្ទាល់ក្នុងការសាកល្បងក្នុងសាលាចំនួន៥។
- **ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាលារៀន៖** ការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធបានបន្តដោយផ្តោតលើបណ្ណាល័យ និងការកែលម្អដល់សាលារៀនថ្មីចំនួន១៥នៃវដ្តទី ៥ ដើម្បីនាំពួកគេឡើងទៅកាន់ស្តង់ដារដូចគ្នានឹងសាលារៀនវដ្តមុនៗ។
- **ការអនុវត្តក្រុមប្រឹក្សាកុមារ៖** ក្រុមប្រឹក្សាកុមារទទួលបានជំនួយជាសាច់ប្រាក់ ដើម្បីបង្កើនភាពជាម្ចាស់របស់សាលា និងការចូលរួមក្នុងការគ្រប់គ្រង។

# ផលជះរបស់គម្រោង

ដូចដែលបានកត់សម្គាល់ខាងលើ គម្រោង HCC បានកើនឡើងជាលំដាប់នូវចំនួនសាលា ហើយឥឡូវនេះជាគម្រោងធំបំផុតទីពីររបស់ខេបលើមូលនិធិ។ ចាប់តាំងពីការចាប់ផ្តើមនៅក្នុងឆ្នាំ២០១៨មក ខេបបានទទួលប្រាក់ជាង៥លានដុល្លារអាមេរិកពីមូលនិធិគីនចាន ដើម្បីធ្វើឱ្យប្រសើរឡើងនូវសាលារៀននៅតាមតំបន់ដាច់ស្រយាលនិងជនបទដោយរចនាគម្រោងរួមបញ្ចូលវិធីសាស្ត្រចំរុះដែលបង្កើតឡើងដោយខេប ដែលត្រូវបានគេស្គាល់ថា '**គម្រោងងាយស្រួលរៀន**'។

គម្រោងនេះទទួលជោគជ័យលើផ្នែកជាច្រើន រួមទាំងការកែលម្អហេដ្ឋារចនាសម្ព័ន្ធ សេវាបណ្ណាល័យ ការរៀនរបស់សិស្ស ការបណ្តុះបណ្តាលគ្រូបង្រៀន និងការគាំទ្រសហគមន៍ប្រកបដោយនិរន្តរភាព។ សមិទ្ធផលដ៏គួរឱ្យចាប់អារម្មណ៍បំផុតមួយរបស់គម្រោងគឺការខិតខំប្រឹងប្រែងដ៏ជោគជ័យរបស់ខ្លួន ក្នុងការផ្សារភ្ជាប់ការវិនិយោគជាមួយនឹងការប្តេជ្ញាចិត្តរយៈពេលវែងពីក្រុមប្រឹក្សាឃុំ ដើម្បីផ្តល់ប្រាក់ខែដល់អ្នកថែទាំសាលាជាអចិន្ត្រៃយ៍ក្នុងការរក្សាបានការវិនិយោគសំខាន់ៗដែលធ្វើឡើងដោយគម្រោង HCC ក្នុងការធ្វើឱ្យប្រសើរលើហេដ្ឋារចនាសម្ព័ន្ធសាលារៀន។ ថ្មីៗនេះ គម្រោងទទួលបានការចាប់អារម្មណ៍ពីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្ត ដែលនាំឱ្យមានការទទួលស្គាល់កាន់តែខ្លាំងឡើងលើកិច្ចខិតខំប្រឹងប្រែងរបស់គម្រោងក្នុងការលើកកម្ពស់ការអប់រំ (សូមមើលរូបខាងលើស្តាំ)។

លទ្ធផលសំខាន់មួយទៀតក្នុងគម្រោងឆ្នាំនេះគឺលទ្ធផលអំណានសិស្សថ្នាក់ទី១ ទី២ ទី៣ មានភាពប្រសើរឡើង។ ដោយផ្អែកលើលទ្ធផលអំណានសិស្ស (EGRA) ប្រចាំឆ្នាំ លើពិន្ទុសូន្យសម្រាប់ការអានពាក្យបានបន្តធ្លាក់ចុះក្រោម ៤០% នៅឆ្នាំនេះសម្រាប់សិស្សថ្នាក់ទី១។ ការប្រៀបធៀបពិន្ទុសូន្យនៃសិស្ស ៥៨% ក្នុងចំណោមកុមារដែលចូលរួមក្នុងកម្មវិធីកែលម្អអំណានថ្នាក់ជាតិ (សូមមើលរូបខាងក្រោម)។ ដូចគ្នានេះដែរ ជំនាញក្នុងការអានអក្សរ និងពាក្យមានភាពប្រសើរឡើងជាលំដាប់ចាប់តាំងពីឆ្នាំមូលដ្ឋាន។



*ក្រុមការងារគម្រោង HCC និងតំណាងមូលនិធិគីនចានជួបជាមួយអភិបាលខេត្តរតនគិរី ដើម្បីចែករំលែកគំនិត និងបញ្ហាប្រឈម។*






*សាលារៀនប្រើប្រាស់បណ្ណាល័យសតវត្សរ៍ទី២១ ដើម្បីលើកកម្ពស់កន្លែងពិសេសសម្រាប់ក្លឹបសិក្សា ដែលជាកន្លែងសម្រាប់សិស្សខ្សោយអាចពង្រឹងជំនាញរៀនសូត្ររបស់ពួកគេ។*






*កុមារជួយកុមារ: កុមារថ្នាក់ទី៦ជួយសិស្សថ្នាក់ទី២នៅសាលាបឋមសិក្សាកន្ទួត។*



*សិស្សថ្នាក់មត្តេយ្យនៅឃុំហាន់ជ័យខេត្តកំពង់ចាមរៀនគូររូបភាពដោយប្រើសម្ភារៈនៅក្នុងមូលដ្ឋាន។*



*គ្រូរៀបចំការបង្ហាញរបស់សិស្សដោយប្រើបច្ចេកទេសរៀនពីវគ្គបំប៉ន។*

# ២២ គម្រោង លើកកម្ពស់លទ្ធភាពជំនាញការងារ និងការធ្វើចំណាកស្រុកប្រកបដោយប្រសិទ្ធភាពដល់យុវជនកម្ពុជា (BMZ/REACH)

*“ សហគមន៍រឹងមាំ ធ្វើឱ្យសាលារៀនរីកចម្រើន! ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការវីវើល/ឆាលហ្វាន Deutch-land/BMZ |
| **អ្នកទទួលផលផ្ទាល់** | ២១ ៩៧៤(ស្រី១០៩៦០នាក់) |
| **ថវិកាឆ្នាំសិក្សា២០២៣** | ១.១១៦.៩៩៣.៧៥១,១៨រៀល |
| **តម្លៃឯកតាក្នុងសិស្សម្នាក់** | ៥០.៨៣២,៥២រៀល |
| **ខេត្តគោលដៅ** | ចំនួន៤ខេត្ត |
| **ស្រុកគោលដៅ** | ចំនួន៨ស្រុក |
| **សាលាបឋមសិក្សាគោលដៅ** | ចំនួន៤៤ សាលារៀន |
| **កាលបរិច្ឆេទចាប់ផ្តើម** | ខែមករា ឆ្នាំ២០១២ |
| **កាលបរិច្ឆេទបញ្ចប់** | ខែធ្នូ ឆ្នាំ២០២៤ |

## គោលបំណង

**គោលដៅរយៈពេលវែង៖** គោលដៅរបស់គម្រោង BMZ/REACH គឺដើម្បីបង្កើនការការពារកុមារ និងផលជះនៃការសិក្សារបស់កុមារក្នុងវិស័យជាច្រើន រួមមាន៖ លេខ អក្សរ និងបំណិនជីវិតតាមរយៈយុទ្ធសាស្រ្ត **'ចំរុះ'** ដែលលើកកម្ពស់អភិបាលកិច្ចឱ្យប្រសើរឡើង និងប្រកបដោយនិរន្តរភាព ព្រមទាំងបរិយាកាសសិក្សាដែលមានគុណភាពខ្ពស់ទាំងនៅសាលា និងតាមគេហដ្ឋានក្នុងខេត្តគោលដៅទាំង៤។

**គោលបំណងបន្ទាន់៖** រួមចំណែកដល់ការបំពេញសិទ្ធិសង្គម និងសិទ្ធិសេដ្ឋកិច្ចដល់កុមារ និងយុវជនកម្ពុជាដែលងាយរងគ្រោះ ដោយមានហានិភ័យនៃការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព។ គម្រោង BMZ/REACH គឺជាគម្រោងធំមួយទៀតរបស់ខេប ដែលប្រើវិធីសាស្រ្តអភិវឌ្ឍន៍រួម ដើម្បីដោះស្រាយទិដ្ឋភាពជាច្រើននៃបរិយាកាសសិក្សារបស់កុមារ រួមទាំងការចូលរៀននៅសាលា បរិយាកាសសិក្សា ការចូលរួមសហគមន៍ ការការពារកុមារ។ល។ ស្របតាមគោលការណ៍សាលាកុមារមេត្រី។

## បច្ចុប្បន្នភាពគម្រោង

ការផ្តល់មូលនិធិសម្រាប់គម្រោងនេះត្រូវបានបន្តផ្តល់ដោយអង្គការ WeWorld ដែលជាអង្គការអ៊ីតាលី អង្គការឆាលហ្វាន់អាល្លឺម៉ង់ និងក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់កិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ)។ សម្រាប់ឆ្នាំសិក្សា ២០២២-២៣ BMZ/REACH បានបន្តអនុវត្តសកម្មភាពជាច្រើននៅក្នុងសាលារៀនគោលដៅដោយមានការសហការយ៉ាងជិតស្និទ្ធជាមួយដៃគូថ្នាក់ខេត្ត ការិយាល័យអប់រំស្រុក និងសាលាគោលដៅ ដោយបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដែលពាក់ព័ន្ធដល់គ្រូបង្រៀនទាក់ទងនឹងការបង្រៀន និងរៀន ហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការគ្រប់គ្រងបណ្ណាល័យជាដើម ដើម្បីលើកកម្ពស់គុណភាពអប់រំ។ នៅក្នុងលក្ខខណ្ឌនៃការអប់រំបញ្ចូលគ្នា កម្មវិធីប្រព័ន្ធរំឭកទុកជាមុន (EWS) ដែលបានបង្កើតឡើងដោយគម្រោងត្រូវបានដាក់បញ្ចូលចំនួន៦០%នៃសាលារៀនគោលដៅតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល និងបច្ចេកវិទ្យា។ ប្រព័ន្ធ EWS មានគោលបំណងជួយសម្រួលដល់ការងាររដ្ឋបាលរបស់គ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលា ដូចជាទាក់ទងនឹងការពង្រឹងគុណភាពការគ្រប់គ្រងសិស្ស និងការរក្សាសិស្សនៅក្នុងសាលា។ តាមរយៈការងារបណ្តាញជាមួយអ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ យុទ្ធនាការផ្សព្វផ្សាយពីការយល់ដឹងបានជួយលើកកម្ពស់ឱកាសការងារ និងការបណ្តុះបណ្តាលជំនាញសម្រាប់យុវជន ក៏ដូចជាការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ សម្រាប់ឆ្នាំសិក្សាថ្មី គម្រោងនឹងបន្តពង្រឹងការអនុវត្តសកម្មភាពរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដែលបានកំណត់។

## សកម្មភាពសំខាន់ៗ

***គម្រោង BMZ/REACH បន្តអនុវត្តសកម្មភាពសំខាន់ៗចំនួន ១៣ រួមមាន៖***

១. ការលើកកម្ពស់ការអភិវឌ្ឍន៍កុមារតូចដោយការជួយសាលារៀនបង្កើត និងគាំទ្រថ្នាក់មត្តេយ្យសិក្សាដែលបណ្តុះបណ្តាលគ្រូយ៉ាងយកចិត្តទុកដាក់។

២. ការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំកាន់តែប្រសើរឡើង តាមរយៈការបង្កើតផែនការកែលម្អសាលារៀន អាហាររូបករណ៍ សកម្មភាពគូសផែនទីសាលារៀន យុទ្ធនាការចុះឈ្មោះចូលរៀន ការចុះសួរសុខទុក្ខគ្រួសារដែលមានកុមារងាយ

## រូបភាពសកម្មភាពសំខាន់ៗ



*ការលើកកម្ពស់ការដាក់បញ្ចូលការអប់រំបំណិនជីវិតនៅក្នុងកម្មវិធីសិក្សាផ្លូវការ៖ សិស្សានុសិស្សនៅបឋមសិក្សាកោះកណ្តាលមើលថែសួនបន្លែរបស់ពួកគេ ដែលជាផ្នែកមួយនៃកម្មវិធីបំណិនជីវិតរបស់គម្រោង។ បំណិនជីវិតកសិកម្មគឺគ្រាន់តែជាប្រភេទបំណិនជីវិតមួយក្នុងចំណោមប្រភេទបំណិនជីវិតជាច្រើនដែលបង្រៀននៅក្នុងសាលាដែលគាំទ្រដោយគម្រោង។ បំណិនជីវិតកសិកម្មផ្តោតលើបច្ចេកទេសកសិកម្មដែលមិនប៉ះពាល់ដល់បរិស្ថាន ដែលជៀសវាងការប្រើប្រាស់ថ្នាំសម្លាប់ស្មៅ និងថ្នាំសម្លាប់សត្វល្អិតក្នុងការដាំដុះ។ កម្មវិធីនេះក៏បានណែនាំសិស្សអំពីកសិកម្មអ៊ីដ្រូប៉ូនិច និងបច្ចេកទេសទំនើបផ្សេងទៀតក្នុងការដាំដុះផងដែរ។*



*ការកសាងបណ្តាញ និងភាពជាដៃគូក្នុងចំណោមអ្នកផ្តល់សេវាវិជ្ជាជីវៈ៖ យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ឱកាសការងារ និងការបណ្តុះបណ្តាលជំនាញសម្រាប់យុវជន ក៏ដូចជាការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពនៅក្នុងតំបន់គោលដៅគម្រោង។ កម្រងព័ត៌មាននៃយុទ្ធនាការនេះ ដោយមានការចូលរួមពីបុគ្គលសំខាន់ៗជាច្រើនរូប រួមមាន៖ អភិបាលរងក្រុងកំពង់ឆ្នាំង នាយករងវិទ្យាស្ថានពហុបច្ចេកទេស មន្រ្តីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងមេឃុំជាច្រើននាក់។ យុទ្ធនាការនេះទទួលបានការគាំទ្រយ៉ាងល្អពីយុវជន និងសមាជិកសហគមន៍ និងបង្ហាញពីការរីកចម្រើននៃបញ្ហាវិជ្ជាជីវៈក្នុងគម្រោង។*

វង្គគ្រោះ និងការបញ្ជូនបន្តកុមារដែលមានសុខភាពមិនល្អ មានជំងឺរ៉ាំរ៉ៃ និងពិការបានទទួលការគាំទ្រ។

៣. ការលើកកម្ពស់សិទ្ធិកុមារនិងការការពារកុមារតាមរយៈការកសាងសមត្ថភាពក្រុមប្រឹក្សាកុមារ ការលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រ និងកម្មវិធីបំណិនជីវិត ដែលបង្កើនភាពពាក់ព័ន្ធនៃការអប់រំដល់សហគមន៍មូលដ្ឋាន។

៤. ការកសាងសមត្ថភាពដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងដល់អ្នកគ្រប់គ្រងសាលា។

៥. គាំទ្រដល់ការជួសជុល និងការកែលម្អបរិស្ថានសាលារៀន (ឧ. ការធ្វើឱ្យប្រសើរឡើងនូវថ្នាក់រៀន បណ្ណាល័យសតវត្សទី២១ ។ល។)។

៦. ការលើកកម្ពស់អក្ខរកម្មនៅថ្នាក់បឋមសិក្សា ដោយប្រើគំរូនៃការអាន កញ្ចប់ល្បែងសិក្សាសម្រាប់អាន និងបច្ចេកវិទ្យាអប់រំ។

៧. បណ្តុះបណ្តាលគណៈកម្មការគ្រប់គ្រងសាលារៀនដើម្បីបង្កើនការចូលរួមរបស់ពួកគេក្នុងវិស័យអប់រំ។

៨. ការកសាងសមត្ថភាពគ្រូបង្រៀន និងអ្នកគ្រប់គ្រងសាលាលើវិធីសាស្ត្របង្រៀនថ្មី បង្កើតសម្ភារជំនួយការបង្រៀន និងប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំ។

៩. គាំទ្រការកែលម្អគុណភាពនៃការបង្រៀន និងបរិយាកាសសិក្សានៅក្នុងសាលារៀនតាមរយៈការបណ្តុះបណ្តាល (ឧ. ការអាន គណិត និងបំណិនជីវិត ដូចជាការធ្វើចំណាកស្រុកដោយសុវត្ថិភាព) និងការគាំទ្រដោយផ្ទាល់នូវសម្ភារ និងការត្រួតពិនិត្យការលើកកម្ពស់ការរៀនសូត្រ។

១០. ការលើកកម្ពស់ការចូលរួមរបស់មាតាបិតាក្នុងការគាំទ្រការរៀនសូត្ររបស់កុមារនៅផ្ទះដោយផ្តល់សេវាកម្មតម្រង់ទិសអំណានតាមរយៈគ្រូបង្វឹកអំណានដែលបានបណ្តុះបណ្តាល និងការពង្រឹងពីគណៈកម្មការទ្រទ្រង់សាលារៀន។

១១. គាំទ្រអភិបាលកិច្ចល្អនៅក្នុងប្រព័ន្ធសាលារៀនតាមរយៈការកសាងសមត្ថភាពលើភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលា គោលនយោបាយការពារកុមារ ការគ្រប់គ្រងទិន្នន័យ ការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន (PoE និង DoE) និងការត្រួតពិនិត្យ និងគាំទ្រក្រុមប្រឹក្សាកុមារ។

១២. ពង្រឹងប្រព័ន្ធព្រមានជាមុននៅក្នុងសាលារៀនគោលដៅ និងផ្តល់ការឆ្លើយតបយ៉ាងរហ័សសម្រាប់កុមារដែលងាយរងគ្រោះក្នុងការបោះបង់ការសិក្សា និងគ្រួសាររបស់ពួកគេដោយការលើកកម្ពស់ការចូលរួមយ៉ាងសកម្មរបស់ក្រុមប្រឹក្សាកុមារ។

១៣. ការកសាងបណ្តាញ និងភាពជាដៃគូជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាជ្ញាធរមូលដ្ឋាន និងសាលារៀនគោលដៅនៅថ្នាក់ស្រុក ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានការងារ និងឱកាសការងារសម្រាប់យុវជននៅជនបទ។

## ផលជះគម្រោង



**វគ្គបណ្តុះបណ្តាលគ្រូបង្រៀនអំពីប្រព័ន្ធព្រមានជាមុន EWS**

*គម្រោង BMZ/REACH បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសយ៉ាងច្រើនដល់បុគ្គលិកនៅក្នុងសាលារៀនគោលដៅ ដើម្បីបង្កើនសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាក្នុងការងារប្រចាំថ្ងៃរបស់ពួកគេ។ នេះរួមបញ្ចូលទាំងការគ្រប់គ្រងទិន្នន័យនៃស្ថិតិសិស្ស ការតាមដានសិស្ស(ប្រព័ន្ធព្រមានជាមុន) ការកែលម្អទំនាក់ទំនងជាមួយឪពុកម្តាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងការរៀបចំគេហទំព័រ។ ការពង្រឹងសមត្ថភាពបែបនេះ ជួយបានច្រើនក្នុងការពង្រឹងសមត្ថភាពទូទៅរបស់សាលា។*



*← ការបង្រៀនពីមិត្តភក្តិ (រូបនៅខាងឆ្វេង) និងសេវាបណ្ណាល័យដែលប្រសើរឡើង (ខាងក្រោម) គឺជាយុទ្ធសាស្ត្រសំខាន់ពីរដែលត្រូវបានប្រើប្រាស់ដោយគម្រោងដើម្បីបង្កើនអក្ខរកម្មថ្នាក់ដំបូង។ គម្រោងនេះបានធ្វើឱ្យការវិនិយោគយ៉ាងច្រើនក្នុងការធ្វើឱ្យប្រសើរឡើងនូវ បណ្ណាល័យ និងសេវាកម្មអាននៅក្នុងសាលារៀនជាច្រើន ដើម្បីដោះស្រាយកង្វះខាតធ្ងន់ធ្ងរនៃកម្រិតអក្ខរកម្មរបស់កុមារ។ ↓*








លទ្ធផលនៃការសិក្សារបស់សិស្សនៅក្នុងសាលាដែលមានអន្តរាគមន៍ គឺមានភាពប្រសើរជាងសាលាប្រៀបធៀបដោយយោងលើការធ្វើតេស្ត EGRA: លទ្ធផលខាងលើបង្ហាញថាអន្តរាគមន៍នៅក្នុងសាលាគោលដៅកំពុងមានផលជះលើអំណានថ្នាក់ដំបូង ដោយផ្អែកលើកិច្ចការចំនួន៦នៅក្នុងការធ្វើតេស្ត។ កិច្ចការទាំងនេះ រួមមាន៖

- ការអានព្យញ្ជនៈ
- ការអានស្រៈ
- ការអានតួអក្សរ
- ការអានពាក្យ
- អានស្ទាត់
- ការអានដើម្បីយល់ន័យ

ភាពខុសគ្នានៃការអនុវត្តរួមមានចំណុចទិន្នន័យខាងក្រោម៖

- ការអានព្យញ្ជនៈ (អក្សរក្នុងមួយនាទី): 28.03 VS 25.39
- ការអានស្រៈ (អក្សរក្នុងមួយនាទី): 18.26 vs 16.25
- ការអានតួអក្សរទូទៅ (អក្សរក្នុងមួយនាទី): 37.17 vs 25.59
- ការអានពាក្យដែលធ្លាប់ស្គាល់ (ពាក្យក្នុងមួយនាទី): 24.83 vs 16.80
- ការអានស្ទាត់ជំនាញ (ពាក្យក្នុងមួយនាទី): 35.38 vs 22.13
- ការអានដើម្បីយល់ដឹង (សំណួរត្រូវបានឆ្លើយយ៉ាងត្រឹមត្រូវ): 2.65 vs 1.56 សំណួរ (ក្នុងចំណោមសំណួរសរុបចំនួន៥ដែលត្រូវបានសួរ)





*អាហារូបករណ៍ និងការចែកសៀវភៅ ដែលមានគោលបំណងជួយដល់កុមារក្រីក្របំផុត (រូបខាងលើ) រួមជាមួយនឹងការបង្កើនការចូលរួមជាមួយសិស្សតាមរយៈក្រុមប្រឹក្សាកុមារជួយលើកកម្ពស់ការរួមបញ្ចូលសិស្ស។*

## ករណីសិក្សា

កុមារីម្នាក់ក្នុងចំណោមកុមារីងាយរងគ្រោះ ដែលសិក្សានៅសាលាបឋមសិក្សាប្រជាគុមានបញ្ហាភ្នែក។ អង្គុយលើគ្រែឈើដោយទឹកមុខស្មើ នាងមានឈ្មោះថា សែម សុភាព។ នាងរស់នៅភូមិប៉ាឡា ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។ បន្ទាប់ពីបុគ្គលិកគម្រោងបានប្រមូល និងផ្ទៀងផ្ទាត់ប្រភពព័ត៌មាន ដើម្បីស្វែងរកការគាំទ្រពីក្រុមការងារគ្រប់គ្រងគម្រោង ដើម្បីជួយសម្រាលដល់ សុភាព ឱ្យមានអាហារ និងថ្លៃធ្វើដំណើរទៅព្យាបាលនៅមន្ទីរពេទ្យព្រះអង្គឌួងក្នុងរាជធានីភ្នំពេញ។

នៅខែមករា ឆ្នាំ២០២៣ នាងត្រូវបានគ្រូពេទ្យហៅទៅពិនិត្យស្ថានភាពសុខភាពភ្នែកបន្ទាប់ពីការធ្វើតេស្តឈាម និងការពិនិត្យរាងកាយ។ ដោយសារតែស្ថានភាពទន់ខ្សោយរបស់នាង មិនអាចធ្វើការវះកាត់ភ្នែកបាន នាងត្រូវបានបញ្ជូនត្រឡប់ទៅផ្ទះវិញដើម្បីកែលម្អសុខភាពដោយធ្វើការណាត់ជួបបន្តនៅខែកុម្ភៈ ឆ្នាំ២០២៣។

ក្រោយការណាត់ជួប និងណែនាំពីគ្រូពេទ្យរួច នាងត្រូវបានក្រុមគ្រួសារនាំយកទៅមន្ទីរពេទ្យព្រះអង្គឌួងដើម្បីវះកាត់យកកែវភ្នែក និងដុំសាច់ដែលខូចចេញ។ បន្ទាប់ពីព្យាបាលភ្នែករួច គ្រូពេទ្យបានអនុញ្ញាតឱ្យនាងត្រឡប់ទៅផ្ទះវិញ ហើយបន្តផ្តល់ការថែទាំ និងព្យាបាលរហូតដល់ថ្ងៃណាត់ជួប។

គ្រូពេទ្យបានណាត់ឱ្យទៅពិនិត្យសុខភាព និងឆែកមើលមុខរបួសរបស់នាង។ បន្ទាប់ពីពិនិត្យ និងលាងមុខរបួសរួច គ្រូពេទ្យបានចេញវេជ្ជបញ្ជាឱ្យទិញបង់រុំរបួស និងបានណាត់ឱ្យនាងត្រឡប់មកជួបពេទ្យវិញនៅខែកុម្ភៈ ឆ្នាំ២០២៣។

បន្ទាប់ពីទទួលបានការពិគ្រោះ និងតាមដានយ៉ាងយកចិត្តទុកដាក់ និងការណាត់ជួបញឹកញាប់ជាមួយវេជ្ជបណ្ឌិត នាងបានទទួលការវះកាត់ដោយជោគជ័យ។ កុមារីងាយរងគ្រោះនេះទទួលបានការមើលថែទាំពីក្រុមគ្រួសារ។ សុខភាពភ្នែករបស់នាងមានភាពប្រសើរឡើងវិញ ប៉ុន្តែនាងនៅតែត្រូវបានត្រួតពិនិត្យដោយអ្នកឯកទេស។ គម្រោងក៏បានគាំទ្រដំណើរការព្យាបាលតាមរយៈការឧបត្ថម្ភជាអាហារ និងការធ្វើដំណើរ ក៏ដូចជាការប្រឹក្សាថែទាំកុមារផងដែរ។ តាមរយៈការទំនាក់ទំនងជាមួយក្រុមគ្រួសារ និងគ្រូបង្រៀនរបស់នាងមក ពេលនេះ សុភាពមានសុខភាពល្អជាធម្មតាឡើងវិញហើយ។ នាងបានមកសាលារៀនជាទៀងទាត់ដូចសិស្សដទៃៗទៀតដែរ ក្រោយពីគម្រោង BMZ បានផ្តល់ថវិកាសម្រាប់ដាក់ភ្នែកសិប្បនិម្មិត។ នាងសប្បាយរីករាយ។



# កម្មវិធីអប់រំបរិយាបន្ន (IEP)

*"កម្មវិធីអប់រំបរិយាបន្ន: លើកកម្ពស់សិទ្ធិអប់រំរវាងក្រុមជនជាតិ"*

ខេបបានបង្រួមគម្រោងតូចៗ និងមធ្យមមួយចំនួនដោយផ្តោតលើការអប់រំបរិយាប័ន្នស្ថិតក្រោមឆ័ត្រតែមួយដែលហៅថា **កម្មវិធីអប់រំបរិយាប័ន្ន**( IEP)។ កម្មវិធី IEP មានគោលដៅចម្បងបង្កើនការទទួលបានការអប់រំ ជាពិសេសក្មេងស្រីជនជាតិខ្មែរឥស្លាមនិងកុមារ/យុវជនដែលងាយរងគ្រោះ។ កម្មវិធី IEP ជួយដល់កុមារ និងយុវជនជាច្រើនចាប់ពីកម្រិតអនុវិទ្យាល័យដល់សាកលវិទ្យាល័យ វិជ្ជាជីវៈ និងកម្រិតបណ្តុះបណ្តាលជំនាញ។ កម្មវិធី IEP មានគម្រោងចំនួន២គឺៈ គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG) និងកម្មវិធីអាហារូបករណ៍របស់កម្មវិធីអភិវឌ្ឍន៍ជំនាញការងារឌីជីថល (DWD) ស្ថិតនៅក្រោមឆ័ត្រIEP តែមួយ។ ដោយសារកង្វះជំនួយហិរញ្ញប្បទាននាពេលបច្ចុប្បន្ននេះ គម្រោងទាំងអស់ក្នុងកម្មវិធី IEP បានថយចុះ។

| | **គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី** (LSLAG) | **កម្មវិធីអាហារូបករណ៍របស់កម្មវិធីអភិវឌ្ឍន៍ជំនាញការងារឌីជីថល** (DWD) |
|---|---|---|
| **ម្ចាស់ជំនួយ** | អង្គការ Gap Inc. | USAID តាមរយៈសាកលវិទ្យាល័យ UCB និងមូលនិធិអាស៊ី |
| **អ្នកទទួលផលផ្ទាល់** | ១៧ ១៨៦ (ស្រីទាំងអស់) | ១២ (ស្រីទាំងអស់) |
| **ថវិកាឆ្នាំសិក្សា២០២៣** | ២៣១.០៦៤.២០០រៀល | ១៤២.១៨៦.៦៤៤,៧២០រៀល |
| **តម្លៃឯកតាក្នុងនិស្សិតម្នាក់** | ៨.០៩៧រៀល | ១១.៨៤៨.៨៨៧,០៦រៀល |
| **ខេត្តគោលដៅ** | ២៥ រាជធានី-ខេត្ត | ៨ (ភ្នំពេញ កំពង់ចាម កណ្តាល ត្បូងឃ្មុំ ក្រចេះ បាត់ដំបង កំពង់ឆ្នាំង និងកំពង់ធំ) |
| **ស្រុកគោលដៅ** | ៤៩ | ១១ |
| **សាលាមធ្យមសិក្សាគោលដៅ** | ៧៥ | គ្មាន |
| **សាលាបណ្តុះបណ្តាលវិជ្ជាជីវៈគោលដៅ** | គ្មាន | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| **កាលបរិច្ឆេទចាប់ផ្តើម** | ខែធ្នូ ឆ្នាំ២០១៨ | ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ |
| **កាលបរិច្ឆេទបញ្ចប់** | ខែមិថុនា ឆ្នាំ២០២៥ | ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៦ |

*កម្មវិធីអប់រំបរិយាបន្នបានជួយអន្តរាគមន៍យុវជនកម្ពុជាដើម្បីទទួលបានឱកាសសម្រាប់សិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ និងកម្រិតអប់រំឧត្តមសិក្សា។ ឱកាសសិក្សានេះផ្តល់ឱ្យពួកគេនូវជំនាញដែលត្រូវឆ្លើយតបនឹងសតវត្សរ៍ទី២១។ កម្មវិធីអប់រំបរិយាបន្នបានជួយគាំទ្រទាំងក្មេងស្រីនិងក្មេងប្រុស ប៉ុន្តែផ្តល់ឱកាសជាអាទិភាពខ្ពស់ទៅលើក្មេងស្រីដែលងាយរងគ្រោះ។ រូបភាពខាងក្រោមជាគំរូសកម្មភាពមួយចំនួនដែលកម្មវិធីអប់រំបរិយាបន្នបានគាំទ្រនៅក្នុងឆ្នាំនេះ។*

***ពីឆ្វេងទៅស្តាំៈ*** *(១) សកម្មភាពសិស្សធ្វើការងារក្រុមស្តីពីយេនឌ័រ (២) សិស្សធ្វើបទបង្ហាញអំពីឥរិយាបទក្មេងប្រុស (៣) សកម្មភាពថ្នាក់រៀនអំពីយេនឌ័រ (៤) កញ្ញា ហ្វ្រិចសួគ៌សួគ៌ ចូលរួមក្នុងសិក្ខាសាលាកម្មវិធី DWD នៅភ្នំពេញ (៥) ការសិក្សាក្រុមរបស់និស្សិតអាហារូបករណ៍នៅអន្តេវាសិកដ្ឋាន (៦) និស្សិតអាហារូបករណ៍ធ្វើការឆ្លុះបញ្ចាំងលើការយល់ផ្នែកឌីជីថល (៧)និស្សិតអាហារូបករណ៍ទាំង១២នាក់ថតរូបនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមុនចូលរៀន (៨)និស្សិតអាហារូបករណ៍បានចូលរួមក្នុងវគ្គតម្រង់ទិសវិជ្ជាជីវៈ។*



# ២៦ គម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG)

*"ផ្តល់នូវសមត្ថភាពសម្រាប់ក្មេងស្រី គឺដើម្បីរស់នៅក្នុងសង្គមប្រកបដោយប្រសិទ្ធភាព"*

## បច្ចុប្បន្នភាពគម្រោង

គម្រោង LSLAG បានឆ្លងកាត់នូវដំណាក់កាលជាច្រើនចាប់តាំងពីឆ្នាំ២០១៨មក រួមមាន៖ បរិបទកម្មវិធីសិក្សា ការសាកល្បង ការផ្តល់អាជ្ញាបណ្ណ និងការអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា ហើយចុងក្រោយបានធ្វើមាត្រដ្ឋានទូទាំងប្រទេស។ នៅឆ្នាំ២០២៣ គម្រោង LSLAG បានបណ្តុះបណ្តាលគ្រូចំនួន១៤៤នាក់ (ស្ត្រី៦១នាក់) នាយកសាលា និងសមាជិកក្រុមការងារគម្រោងមកពីសាលារៀនចំនួន៣៨នៅគ្រប់ខេត្តទាំងអស់ទូទាំងប្រទេស។ សរុបមក មានកុមារីវ័យជំទង់ចំនួន ១១ ៤៨១នាក់ និងកុមារីពេញវ័យចំនួន ៥ ៧០៥នាក់ បានអនុវត្តតាមកម្មវិធីសិក្សាបំណិនជីវិត P.A.C.E នៅក្នុងសាលាគោលដៅមួយក្នុងចំណោមសាលាគោលដៅចំនួន៧៥។ នៅខែមិថុនា ឆ្នាំ២០២៣ ដើម្បីមើលវឌ្ឍនភាពការអនុវត្តកម្មវិធីសិក្សា តំណាងក្រុមហ៊ុន Gap Inc. (Mr. Elvis Francis & Mr. Imran Ahmed) បានទៅទស្សនាសាលាគោលដៅចំនួនពីរនៅអនុវិទ្យាល័យស្វាយរលំក្នុងខេត្តកណ្តាល និងវិទ្យាល័យចំរើនរ័ត្ន ក្នុងរាជធានីភ្នំពេញ។ ពួកគាត់ក៏មានឱកាសបានជួបជាមួយនាយកដ្ឋានមួយចំនួនរបស់ក្រសួងអប់រំ យុវជន និងកីឡាផងដែរ រួមមាន៖ នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ និងនាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា ព្រមទាំងសមាជិក ក្រុមការងារគម្រោងមកពីរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ដើម្បីចែករំលែកព័ត៌មាន និងមេរៀនបទពិសោធន៍។

ខេបបានផ្សព្វផ្សាយ និងធ្វើឱ្យកម្មវិធីបំណិនជីវិត P.A.C.E កាន់តែងាយស្រួលដល់គ្រូបង្រៀនតាមរយៈការកែសម្រួលវីដេអូស្តីពីការណែនាំការបណ្តុះបណ្តាល។ វីដេអូទាំងនេះត្រូវបានផលិតនៅតាមសាលាផ្សេងៗ ហើយត្រូវបានប្រើប្រាស់នៅក្នុងការបណ្តុះបណ្តាលគ្រូ។ ខេបក៏បានបង្កើតទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមហ្វេសប៊ុក និង Instagram ដើម្បីផ្សព្វផ្សាយអំពីសាច់រឿង និងសមិទ្ធផលរបស់សិស្ស។

ខេបបន្តតាមដានដំណើរការអនុវត្តកម្មវិធីសិក្សានៅក្នុងសាលារៀនដោយប្រើប្រាស់ទម្រង់ Goodera ដើម្បីតាមដានចំនួនសិស្សដែលបានចុះឈ្មោះក្នុងកម្មវិធី និងចែករំលែកសាច់រឿងផលជះពីគម្រោងជាមួយម្ចាស់ជំនួយ។

## សកម្មភាពសំខាន់ៗ

| សកម្មភាព | លក្ខណៈ |
|---|---|
| ១. រៀបចំការប្រជុំអំពីការសិក្សា និងចែករំលែកតាមពេលវេលាកំណត់ជាមួយគ្រូបង្គោល។ | បន្ត |
| ២. បណ្តុះបណ្តាលគ្រូបង្គោលដែលជ្រើសរើសចេញពីគ្រូឆ្នើមរយៈពេល៥ថ្ងៃ។ | បញ្ចប់ |
| ៣. ពង្រីកកម្មវិធីទៅសាលារៀនបន្ថែមចំនួន២៥ នៅខែកក្កដា ឆ្នាំ២០២៣ | បញ្ចប់ |
| ៤. បណ្តុះបណ្តាលគ្រូនៅក្នុងសាលាចំនួន១៥០ ដែលបានជ្រើសរើសដើម្បីប្រើប្រាស់កម្មវិធីសិក្សា P.A.C.E. | បន្ត |
| ៥. ការត្រួតពិនិត្យ និងការវាយតម្លៃត្រូវធ្វើឡើងដោយក្រុមការងារ និងបុគ្គលិកគម្រោង | បន្ត |
| . ការកែសម្រួលវីដេអូបណ្តុះបណ្តាលពេញលេញ ដែលនឹងជួយសម្រួលដល់ការណែនាំ និងការបណ្តុះបណ្តាលគ្រូក្នុងការប្រើប្រាស់កម្មវិធីសិក្សា P.A.C.E. | បញ្ចប់ |
| .ការអភិវឌ្ឍក្របខ័ណ្ឌវិញ្ញាបនបត្រសម្រាប់គ្រូបង្គោល ដោយសហការជាមួយមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យ/វិទ្យាស្ថានជាតិអប់រំ។ | បញ្ចប់ |

## គោលដៅ

កម្មវិធីកែសម្រួលឱ្យដំណើរផ្លាស់ប្តូរប្រកបទៅដោយសុខភាព និងវិជ្ជមានទៅជាមនុស្សពេញវ័យខណៈពេល ដែលទទួលស្គាល់និងដោះស្រាយភាពងាយរងគ្រោះផ្នែកយេនឌ័រ និងវិសមភាព។

**គោលបំណងសំខាន់ៗរបស់គម្រោង រួមមាន៖**

១. កសាងជំនាញ និងប្រសិទ្ធភាពរបស់ក្មេងស្រីជំទង់ឱ្យមានទំនុកចិត្ត ធនធាន និងចេះរៀបចំផែនការប្រកប ដោយប្រសិទ្ធភាពសម្រាប់អនាគតរបស់ពួកគេ។

២. កសាងប្រសិទ្ធភាពសម្រាប់ក្មេងស្រី ដើម្បីឱ្យពួកគេអាចចរចាអំពីការផ្លាស់ប្តូររូបរាងកាយ ផ្លូវចិត្ត និងសង្គមក្នុងវ័យជំទង់ ដែលមានផលប៉ះពាល់យ៉ាងសំខាន់ចំពោះលទ្ធផលនៅពេលពេញវ័យ។

## រូបថតសកម្មភាព



*រូបភាពសកម្មភាព (ពីឆ្វេងទៅស្តាំ)៖ ១. តំណាងក្រុមហ៊ុន Gap, Inc. ដែលមកទស្សនកិច្ចនៅនាយកដ្ឋានក្រសួង ២.ទស្សនកិច្ចនៅអនុវិទ្យាល័យស្វាយរលំ ៣.សកម្មភាពសិស្សធ្វើការជាក្រុមដែលមាននៅក្នុងមេរៀនបំណិនជីវិត Gap Inc. P.A.C.E. និង ៤. បុគ្គលិកគម្រោង LSLAG ជួបជាមួយសិស្ស និងអ្នកពាក់ព័ន្ធតាមសាលាគោលដៅដើម្បីចែករំលែកបទពិសោធន៍សិក្សាអំពីការអនុវត្តគម្រោង។*

## ករណីសិក្សា

**ហាប់ ប៊ុនណេង** ជាសិស្សថ្នាក់ទី៧ រៀននៅវិទ្យាល័យហ៊ុន សែន ក្រាំងកែប ខេត្តកែប។ កាលនាងនៅក្មេង នាងធ្លាប់ប្រាប់ឪពុកម្តាយថា នាងចង់ក្លាយជាទាហានពេលធំឡើង។ នាងបាននិយាយថា បងប្រុសរបស់នាងធ្លាប់ចំអកនាង ហើយប្រាប់នាងថា «*ឯងជាមនុស្សស្រី ឯងមិនអាចធ្វើជាទាហានបានទេ*»។ ឪពុកម្តាយ និងបងប្រុសរបស់នាងសើចចំអក ខណៈពេលដែលនាងអាក់អន់ចិត្ត និងខ្មាស់គេខ្លាំងណាស់នៅពេលនោះ។ ម្តាយរបស់នាងបានបន្ថែមថា "*ប្រសិនបើកូនក្លាយជាទាហាន កូនត្រូវនៅតែក្នុងបន្ទាយ។ វាមិនមានសុវត្ថិភាពសម្រាប់ក្មេងស្រីទេ។ ម៉ែមិនអនុញ្ញាតឱ្យកូនទៅនៅឆ្ងាយពីផ្ទះទេ*»។ ពីមួយថ្ងៃទៅមួយថ្ងៃ នាងក្លាយជាមនុស្សខ្មាស់អៀន ខ្វះភាពក្លាហាន មិនបញ្ចេញគំនិតរបស់ខ្លួនទៅកាន់នរណាទេ ហើយនាងងាយភិតភ័យ។

ប៊ុនណេងត្រូវបានណែនាំឱ្យស្គាល់ និងសិក្សាកម្មវិធីសិក្សាបំណិនជីវិត Gap Inc. P.A.C.E.ក្នុងឆ្នាំ២០២៣ រយៈពេល៨ខែដោយគ្រូរបស់នាង។ នាងបានកត់សម្គាល់ឃើញថា ក្នុងអំឡុងពេលសិក្សា នាងកាន់តែមានភាពក្លាហានក្នុងការបញ្ចេញមតិ ចូលរួមក្នុងសកម្មភាពក្នុងថ្នាក់ និងមិនសូវខ្មាស់អៀន។ នាងមានអារម្មណ៍ស្រួលក្នុងការសួរសំណួរគ្រូ និងឆ្លើយសំណួរនៅពេលសួរ។ នៅពេលគ្រូបង្រៀនមេរៀន "***តើតួនាទីយេនឌ័រជាអ្វី?***" នាងបានចងចាំពីសុបិនរបស់នាងក្នុងការធ្វើជាទាហាន ហើយបានដឹងថាការធ្វើជាទាហានមិនមែនសម្រាប់តែបុរសប៉ុណ្ណោះទេ ប៉ុន្តែស្ត្រីក៏អាចធ្វើវាបានផងដែរ។ មេរៀន "***ការចរចាអំពីតួនាទីយេនឌ័រ***" បានលើកទឹកចិត្តនាងឱ្យចាប់ផ្តើមនិយាយជាមួយឪពុកម្តាយរបស់នាងអំពីអាជីពនេះម្តងទៀត។ ឪពុកម្តាយ និងប្អូនប្រុសរបស់នាងបាននិយាយថា "*ការងារនេះប្រថុយប្រថានណាស់ កូនត្រូវហ្វឹកហាត់នៅក្រោមកំដៅព្រះអាទិត្យ ឬភ្លៀង ហើយកូនត្រូវមានសុខភាពរាងកាយល្អ។ វាស័ក្តិសមនឹងបុរសល្អជាងស្ត្រី*»។ នាងបានព្យាយាមបញ្ចុះបញ្ចូលពួកគេ ហើយចរចាជាមួយពួកគេជាច្រើនលើកច្រើនសារ «*ទាហានបុរស និងស្ត្រីនៅតែដាច់ដោយឡែក ហើយខ្ញុំមានកម្លាំងគ្រប់គ្រាន់ដើម្បីចូលរួមក្នុងការហ្វឹកហ្វឺនយោធា។ ខ្ញុំបានឃើញទាហានស្រីជាច្រើននៅក្នុងប្រទេសរបស់យើង។ ការងារនេះមិនរើសអើងដោយផ្អែកលើភេទទេ។ បើទោះជាខ្ញុំមិនមែនជាទាហានក៏ដោយ ថ្ងៃណាមួយខ្ញុំនឹងចាកចេញពីផ្ទះទៅរៀន ឬធ្វើការនៅកន្លែងផ្សេងឆ្ងាយពីផ្ទះ*»។ ទីបំផុត ឪពុកម្តាយរបស់នាងបានធូរស្រាល ហើយយល់ព្រមឱ្យនាងដើរតាមផ្លូវផ្ទាល់ខ្លួន។នាងសប្បាយចិត្តណាស់។ ថ្ងៃនេះ គ្រួសារនាងលើកទឹកចិត្តឱ្យនាងខិតខំសិក្សា ដើម្បីសម្រេចក្តីសុបិនរបស់នាង។ ប៊ុនណេង មានមោទនភាពចំពោះខ្លួនឯង និងក្រុមគ្រួសាររបស់នាង ដែលសមាជិកម្នាក់ៗលើកទឹកចិត្តគ្នាទៅវិញទៅមក និងយល់កាន់តែច្បាស់អំពីតួនាទីយេនឌ័រ។



# កម្មវិធីអាហារូបករណ៍របស់កម្មវិធីអភិវឌ្ឍន៍ជំនាញការងារឌីជីថល (DWD)

*"យើងអាចសម្រេចជោគជ័យបានក្នុងនាមជាស្ត្រី និងមិនមានដែនកំណត់ចំពោះស្ត្រីនោះទេ"*

## បច្ចុប្បន្នភាពគម្រោង

**ទិដ្ឋភាពទូទៅ៖** អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា បានទទួលការគាំទ្រហិរញ្ញប្បទានរយៈពេល៤ឆ្នាំ (២០២២-២០២៦) ពីអង្គការមូលនិធិអាស៊ី តាមរយៈសាកលវិទ្យាល័យ California at Berkeley (UCB) និងទីភ្នាក់ងារជំនួយសហរដ្ឋអាមេរិក (USAID) ដើម្បីគាំទ្រក្មេងស្រីក្នុងកម្មវិធីអភិវឌ្ឍជំនាញការងារឌីជីថល។ គោលដៅមួយរបស់គម្រោងគឺដើម្បីផ្សារភ្ជាប់ដៃគូវិស័យឯកជនដើម្បីជួយអភិវឌ្ឍនិងបង្កើតកម្មវិធីអាហារូបករណ៍គំរូមួយដែលបង្កើនការទទួលស្គាល់គុណភាពសិក្សាថ្នាក់បរិញ្ញាបត្រសម្រាប់មនុស្សគ្រប់គ្នា និងសិស្សដែលមានទេពកោសល្យ។

**ការជ្រើសរើសអ្នកទទួលផល៖** និស្សិតនារី១២នាក់ ត្រូវបានជ្រើសរើស និងទទួលបានអាហារូបករណ៍ពីគម្រោង។ ពួកគាត់បានប្រលងជាប់មធ្យមសិក្សាទុតិយភូមិ និងមាននិទ្ទេស(B=3, C=4, D=4, E=1)។ និស្សិតទាំងនោះត្រូវបានជ្រើសរើសចេញពីគ្រួសារដែលមានជីវភាពខ្វះខាត (៥៨% មកពីគ្រួសារដែលមានសមាជិកច្រើន ៩០% មកពីគ្រួសារដែលមានបំណុល និង ២៥% កំព្រា ឬមានតែម្ដាយ ឬឪពុក។

**វិទ្យាស្ថានសិក្សា និងមុខជំនាញ៖** សាកលវិទ្យាល័យភូមិន្ទភ្នំពេញត្រូវបានកំណត់ជាស្ថាប័នមួយក្នុងការផ្ដល់កន្លែងសិក្សាសម្រាប់និស្សិតអាហារូបករណ៍។ ពួកគាត់សិក្សាជំនាញ វិស្វកម្មបច្ចេកវិទ្យាព័ត៌មាន (ITE) និង វិស្វកម្មវិទ្យាសាស្ត្រកុំព្យូទ័រ (CSE) និងចាប់ផ្ដើមឆ្នាំទីមួយនៅខែមីនា ឆ្នាំ២០២៣។

**ការប្រឡង៖** និស្សិតអាហារូបករណ៍របស់កម្មវិធីអភិវឌ្ឍជំនាញការងារឌីជីថលទាំង១២នាក់បានប្រឡងជាប់ ១០០% នៅឆ្នាំទី១ក្នុងឆ្នាំសិក្សា ២០២២-២៣។ សមិទ្ធផលសិក្សារបស់ពួកគាត់គឺជាចំណុចមោទនភាពមួយ ហើយមិត្តភក្តិបានកោតសរសើរពីការខិតខំប្រឹងប្រែងរបស់ពួកគាត់។ និស្សិតអាហារូបករណ៍នឹងចាប់ផ្ដើមការសិក្សាឆ្នាំទី២នៅចុងខែធ្នូ ឆ្នាំ២០២៣។

## លទ្ធផលកម្មវិធី

- និស្សិតអាហារូបករណ៍ទាំង១២នាក់ បានចូលរួមសិក្សាពីការណែនាំពីគម្រោង បទវិន័យ និង តួនាទីជានិស្សិតអាហារូបករណ៍។
- និស្សិតអាហារូបករណ៍៤នាក់ត្រូវបានក្លាយជាអនុប្រធានថ្នាក់នៅសាកលវិទ្យាល័យ។
- និស្សិតទាំង១២នាក់បានប្រឡងជាប់ ១០០% ដោយជោគជ័យនៅឆ្នាំទី១។
- និស្សិតអាហារូបករណ៍ទាំង១២នាក់ បានចូលរួមប្រជុំប្រចាំខែយ៉ាងទៀងទាត់ ដែលពួកគាត់អាចលើកពីក្ដីបារម្ភ បញ្ហាប្រឈម និងបច្ចុប្បន្នភាពនៃការសិក្សា។
- ក្លឹបសិក្សាពីរត្រូវបានបង្កើតឡើងដោយក្រុមនិស្សិតនៅអន្តេវាសិកដ្ឋានបុរីនិស្សិត។
- វគ្គបណ្ដុះបណ្ដាលបីត្រូវបានរៀបចំឡើងដោយអង្គការខេប រួមមាន៖ ការរៀបចំកាលវិភាគផ្ទាល់ខ្លួន បញ្ជីត្រូវធ្វើ ការសរសេរអ៊ីម៉ែល និងអក្ខរកម្មឌីជីថល។
- និស្សិតទាំងអស់បានចូលរួមសិក្ខាសាលា វគ្គបណ្ដុះបណ្ដាល និងសកម្មភាពការងារស្ម័គ្រចិត្តមួយចំនួនជាប្រចាំក្នុងអំឡុងឆ្នាំនេះ។




*សិក្ខាសាលាណែនាំអំពី៖ កម្មវិធីអាហារូបករណ៍របស់គម្រោងអភិវឌ្ឍន៍ជំនាញការងារឌីជីថលនៅសាលា CADT ។*

## ការគាំទ្រលើកម្មវិធីអាហារូបករណ៍

- *តម្លៃសិក្សាថ្នាក់បរិញ្ញាបត្រ*
- *ការស្នាក់នៅ*
- *ទឹកភ្លើង*
- *កុំព្យូទ័រយួរដៃ*
- *ធានារ៉ាប់រងសុខភាព*
- *ប្រាក់ឧបត្ថម្ភថ្លៃអាហារ*
- *ថ្លៃសម្ភារសិក្សា*
- *ការប្រជុំអាណាព្យាបាល*
- *សកម្មភាពអភិវឌ្ឍអាជីព*

## ករណីសិក្សា

និស្សិត **ម៉ារីណា** មានអាយុ២០ឆ្នាំ គឺជាក្មេងស្រីជនជាតិម៉ូស្លីមមកពីខេត្តកំពង់ឆ្នាំង។ នាងមានបងប្អូន៥នាក់ និងជាកូនទី៣នៅក្នុងគ្រួសារ។ នាងរស់នៅក្នុងផ្ទះឈើដែលមានស្រះមួយនៅខាងមុខផ្ទះ។ នៅក្នុងគ្រួសារ ឪពុករបស់នាងគឺជាអ្នកដើរតួនាទីសំខាន់ក្នុងការរកចំណូល វាពិតជាមិនគ្រប់គ្រាន់នោះទេ ក្នុងការចិញ្ចឹមកូនច្រើននាក់ដែលត្រូវទៅសាលាទាំងអស់គ្នាក្នុងពេលតែមួយ។ ពេលដែលនាងនៅថ្នាក់វិទ្យាល័យ ម៉ារីណា តែងតែក្រោកនៅម៉ោង៥ព្រឹក ដើម្បីជួយម្ដាយរបស់នាងដែលលក់អាហារពេលព្រឹកនៅក្បែរសាលារៀន។ ពេលត្រលប់ពីសាលាមកផ្ទះ នាងក៏បានជួយម្ដាយរបស់នាងរៀបចំទុកដាក់ផ្ទះសម្បែង និងចំណាយពេលដែលនៅសល់ធ្វើកិច្ចការសាលាដល់យប់ជ្រៅម៉ោង១២អាធ្រាត្រ។

ម៉ារីណាបានប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅឆ្នាំ២០២២ ហើយបានទៅធ្វើការនៅរោងចក្រអស់រយៈពេល១ឆ្នាំ ដោយសារតែនាងមិនមានថវិកាក្នុងការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ។ ក្នុងពេលជាមួយគ្នានោះ មិត្តភក្តិរបស់នាងជាច្រើនបានប្ដូរទៅទីក្រុងដើម្បីបន្តការសិក្សានៅសាកលវិទ្យាល័យ។ នាងបានតាំងចិត្តថាខំប្រឹងរកលុយដើម្បីជួយដល់ម្ដាយ និងសន្សំថវិកាមួយចំនួនដើម្បីបន្តការសិក្សានៅឆ្នាំបន្ទាប់។

អ្វីដែលគួរឱ្យភ្ញាក់ផ្អើល នាងបានឃើញការប្រកាសជ្រើសរើសអាហារូបករណ៍នៅថ្នាក់មហាវិទ្យាល័យរបស់អង្គការ ខេប។ នាងបានស្វែងរកព័ត៌មានលម្អិតភ្លាមៗអំពីឱកាសនេះ ហើយនាងបានឃើញថា វាជាអាហារូបករណ៍គាំទ្រពេញលេញ ដែលនាងបានកំពុងស្វែងរកពីព្រោះនាងត្រូវការផ្ដោតទៅលើការសិក្សាពេញម៉ោង ដោយមិនបារម្ភពីការរកចំណូលដើម្បីផ្គត់ផ្គង់ខ្លួនឯង។ អ្វីដែលកាន់តែចាប់អារម្មណ៍នោះ ការអប់រំបែបឌីជីថលដែលផ្ដោតនៅក្នុងសេចក្ដីប្រកាស គឺជាជំនាញមួយដែលនាងពេញចិត្តផងដែរ។

ម៉ារីណាបានចែករំលែកគំនិតដូចខាងក្រោម៖

*"បើមិនមានការគាំទ្រពីកម្មវិធីអាហារូបករណ៍ ខ្ញុំត្រូវផ្លាស់ទៅរស់នៅឆ្ងាយផ្ទះ ដើម្បីធ្វើការដែលមានជំនាញទាប ហើយខ្ញុំមិនដឹងថាពេលណាខ្ញុំអាចចាប់ផ្ដើមក្ដីស្រមៃក្នុងការចូលរៀននៅមហាវិទ្យាល័យបានទេ។ ឥឡូវនេះខ្ញុំគឺជានិស្សិតឆ្នាំទី១ ឯកទេស វិស្វកម្មបច្ចេកវិទ្យាព័ត៌មាន នៅឯសាកលវិទ្យាល័យ។ ខ្ញុំពិតជារំភើបណាស់ដែលបានក្លាយជានិស្សិតម្នាក់នៅក្នុងកម្មវិធីអភិវឌ្ឍន៍ជំនាញការងារឌីជីថល"* ។

នាងបានបន្ថែមថា *"ខ្ញុំបានចូលរួមសកម្មភាពជាច្រើន ដូចជា វគ្គបណ្ដុះបណ្ដាល UNI TWIN Start-Up ក្លឹបសិក្សា ទិវាវិស្វកម្ម។ ខ្ញុំបានរៀនសូត្រជាច្រើន រួមទាំងការបង្កើតបណ្ដាញបទពិសោធថ្មី ចំណេះដឹង និងទំនុកចិត្ត។ ខ្ញុំចង់ក្លាយជាអ្នកវិភាគទិន្នន័យ ដែលអាចជួយដល់គ្រួសាររបស់ខ្ញុំ និងជាផ្នែកមួយនៃសង្គម។ ខ្ញុំចង់មើលថែគ្រួសាររបស់ខ្ញុំ និងចែករំលែកចំណេះដឹងដល់សហគមន៍។ ខ្ញុំចង់ឱ្យមនុស្សនៅក្នុងសហគមន៍របស់ខ្ញុំបានស្គាល់ និងមានគំនិតសុទិដ្ឋិនិយមចំពោះការអប់រំបែបឌីជីថលនេះ"*។



# ២៨ គម្រោង សៀវភៅសម្រាប់កម្ពុជា (BFC)

*“បង្កើនការលូតលាស់របស់កុមារ និងយុវជនតាមរយៈសៀវភៅសិក្សា និងប្រព័ន្ធផ្សព្វផ្សាយ”*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការមូលនិធិអាស៊ី និងក្រសួងអប់រំ យុវជន និងកីឡា |
| **អ្នកទទួលផលផ្ទាល់** | ៣៨ ៦៥៤ |
| **ថវិកាបដិភាគឆ្នាំសិក្សា២០២៣** | ៦១.៧៥៧.៥៦៦,២២រៀល (ជំនួយបដិភាគ) |
| **តម្លៃឯកតាក្នុងសិស្សម្នាក់** | ១.៥៩៧,៧០រៀល |
| **ខេត្តគោលដៅ** | ១៥ |
| **ស្រុកគោលដៅ** | ៥៦ |
| **វិទ្យាស្ថានរដ្ឋាភិបាល និងសាកលវិទ្យាល័យគោលដៅ** | ១២ |
| **មធ្យមសិក្សាគោលដៅ** | ២៦ |
| **សាលាបឋមសិក្សាគោលដៅ** | ២៣ |
| **កាលបរិច្ឆេទចាប់ផ្តើម** | ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៤ |
| **កាលបរិច្ឆេទបញ្ចប់** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ |

## បច្ចុប្បន្នភាពគម្រោង

កម្មវិធីសៀវភៅសម្រាប់កម្ពុជាបានបញ្ចប់ឆ្នាំទី៩នៃប្រតិបត្តិការរបស់ខ្លួន (២០១៤-២០២៣) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ នៅខែមិថុនា ឆ្នាំ២០២៣ គម្រោងនេះត្រូវបានបន្តរយៈពេលប្រាំមួយខែទៀត (រហូតដល់ចុងឆ្នាំ២០២៣)។ ចាប់តាំងពីគម្រោងបានចាប់ផ្តើមប្រតិបត្តិការកាលពី៩ឆ្នាំមុន គម្រោងបានចែកចាយសៀវភៅជាភាសាអង់គ្លេស និងខ្មែរជាង ១២១ ៦៦៤ក្បាល ដល់សាលារៀន ៧២៤ ក្នុងនោះរាប់បញ្ចូលទាំងសាលាបណ្តាញ និងសាលាធនធាន។ ក្នុងអំឡុងពេលនេះ គម្រោងនេះបានផ្តល់សៀវភៅ និងសម្ភារៈផ្សេងៗទៀតទៅសាលាមកពីស្រុកចំនួន៥៦ ដែលស្ថិតនៅក្នុងខេត្តចំនួន១៥។ នៅចុងឆ្នាំ២០២២ BFC បានទទួលសៀវភៅបន្ថែមចំនួន៣ទូកុងតឺណឺសម្រាប់ការបរិច្ចាគបន្ត។ នៅឆ្នាំ២០២៣ សាលារៀនគោលដៅបានបន្តស្នើសុំសៀវភៅ ក្នុងនោះមានសាលាបណ្តាញ សាលាធនធាន (ដែលគាំទ្រដោយគម្រោង ADB) និងជាពិសេសសាលារៀនជំនាន់ថ្មី។ BFC បានបន្តតាមដានការប្រើប្រាស់ធនធានសៀវភៅតាមរយៈប្រព័ន្ធតេឡេក្រាម។ សកម្មភាពមួយចំនួនត្រូវទទួលបានមូលនិធិដោយផ្ទាល់ពីខេបក្នុងអំឡុងពេលបន្ត ដើម្បីនាំគម្រោងនេះឱ្យឈានដល់ការសន្និដ្ឋានសមស្របមួយ។

## ផលជះរបស់គម្រោង

**បង្កើតវប្បធម៌សិក្សា៖** គម្រោង BFC បានបន្តផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់បណ្ណារក្សទូទាំងប្រទេស ដើម្បីជួយសម្រួលដល់សិស្សានុសិស្សក្នុងការទទួលបាននូវសៀវភៅ ដែលត្រូវនឹងចំណាប់អារម្មណ៍របស់ពួកគេ។ ក្នុងអំឡុងឆ្នាំសិក្សានេះ គម្រោងនេះបានរៀបចំ និងផ្តល់សិក្ខាសាលាតាមរយៈ Webinars ចំនួនពីរដងជាមួយអ្នកជំនាញផ្នែកវិទ្យាសាស្ត្របណ្ណាល័យ (អ្នកជំនាញទី១មកពីប្រទេសសិង្ហបុរី និងអ្នកជំនាញទី២មកពីប្រទេសហូឡង់) ដើម្បីចែករំលែកទម្លាប់អាន និងសកម្មភាពសិក្សាជាមួយសាលារដ្ឋ។

**ការលើកកម្ពស់បណ្ណាល័យ និងការចែកចាយសៀវភៅ៖** គម្រោង BFC បានផ្តល់សៀវភៅអានយ៉ាងច្រើនដល់បណ្ណាល័យសាលារៀនជាច្រើននៅទូទាំងប្រទេស។ ក្នុងឆ្នាំសិក្សានេះ BFC បានចែកចាយសៀវភៅភាសាអង់គ្លេស និងសៀវភៅវេជ្ជសាស្ត្រទូទៅចំនួន ២៩ ៥៩២ក្បាល ដល់សាលារៀន និងបណ្ណាល័យសាធារណៈចំនួន ៥៦ នៅទូទាំងប្រទេសកម្ពុជា (២០២២-២០២៣)។ សៀវភៅវេជ្ជសាស្ត្រត្រូវបានបរិច្ចាគជាចម្បងទៅសាលាពេទ្យ។

**ពង្រឹងលើការត្រួតពិនិត្យ៖** ក្នុងឆ្នាំនេះ គម្រោងបានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការបង្កើនការប្រើប្រាស់សៀវភៅភាសាអង់គ្លេសតាមរយៈការត្រួតពិនិត្យសាលារៀនញឹកញាប់ជាងមុន។ គម្រោងក៏បានបន្តគាំទ្រការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា Telegram និង Facebook ដើម្បីចែករំលែក និងតាមដានសកម្មភាពអាន។ បុគ្គលិកគម្រោងបានចុះតាមសាលារៀនជាច្រើនក្នុងអំឡុងឆ្នាំសិក្សា ក្នុងនោះមានសាលារៀនជំនាន់ថ្មី វិទ្យាល័យសាលាធនធាន និងសាលាបណ្តាញមួយចំនួន។ ដំណើរទស្សនកិច្ចទាំងនេះបានធ្វើឱ្យគម្រោងមើលឃើញពីវឌ្ឍនភាព បញ្ហាប្រឈម និងបញ្ហាដែលត្រូវប្រឈមក្នុងការអនុវត្តប្រចាំថ្ងៃ។

**ទិសដៅទៅអនាគត៖** ឆ្នាំបច្ចុប្បន្ននាំមកនូវគម្រោងអាចសន្និដ្ឋានបានបន្ទាប់ពីបានប្រតិបត្តិការរយៈពេល៩ឆ្នាំមក។ ទៅថ្ងៃអនាគត គម្រោងនឹងបន្តដំណើរការមានបន្ទប់តាំងបង្ហាញសៀវភៅ ដើម្បីចែកចាយសៀវភៅដែលនៅសល់។ លើសពីនេះទៅទៀត គម្រោងនេះបានសម្រេចចិត្តថាខ្លួននឹងចាប់ដៃគូជាមួយក្រុមហ៊ុន TTO ដើម្បីចាប់ផ្តើមបោះពុម្ពសៀវភៅគំរូដែលសរសេរដោយសិស្សនៅក្នុងកម្មវិធីសាលាជំនាន់ថ្មី បន្ទាប់មកអាចត្រូវបានផ្សព្វផ្សាយ/លក់ទៅកាន់បណ្ណាល័យសាលារៀនទូទាំងប្រទេស។ គម្រោងនេះនឹងក្លាយភាពជាដៃគូសាធារណៈ និងឯកជន ដែលសង្ឃឹមថានឹងអាចផ្តល់មូលនិធិដោយខ្លួនឯងបាន។

## គោលបំណង

ការចុះអនុស្សរណៈរបស់គម្រោងជាមួយក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់អាទិភាពដល់ការបរិច្ចាគសៀវភៅដល់សាលាបឋម និងមធ្យម ដោយផ្តោតលើខេត្តថ្មីចំនួន៥ជារៀងរាល់ឆ្នាំ ដើម្បីគ្របដណ្តប់ទាំង២៥រាជធានី/ខេត្តក្នុងរយៈពេល៥ឆ្នាំ។ គម្រោងនេះបានស្វែងរកលើកការកម្ពស់ការអានភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ កម្រិតបឋមសិក្សាក៏នឹងត្រូវបានពិចារណាផងដែរសម្រាប់ការផ្តល់ជូនសៀវភៅ ប្រសិនបើពួកគេអាចបង្ហាញពីស្តង់ដាខ្ពស់នៃការគ្រប់គ្រងបណ្ណាល័យ។ ការគ្រប់គ្រងផ្តើមគឺសំដៅលើការចូលរួមយ៉ាងខ្លាំងក្លាពីអ្នកគ្រប់គ្រងសាលា គ្រូបង្រៀន សិស្សានុសិស្ស និងគណៈកម្មការគ្រប់គ្រងសាលារៀន។

## សកម្មភាពសំខាន់ៗ

- សៀវភៅសម្រាប់កម្ពុជាបានបន្តដំណើរការទទួលសំណើសុំសៀវភៅពីសាលារៀន ហើយបានចែកចាយសៀវភៅជាភាសាអង់គ្លេស និងសៀវភៅវេជ្ជសាស្ត្រចំនួន ២៩.៥៩២ក្បាល ពីដើមឆ្នាំរហូតដល់ចុងខែមិថុនាឆ្នាំ២០២៣។ សៀវភៅទាំងនេះគឺជាសៀវភៅដែលមានគុណភាពខ្ពស់ដែលផ្តល់ដោយក្រុមហ៊ុនបោះពុម្ពផ្សាយនៅសហរដ្ឋអាមេរិក និងនៅកម្ពុជា។
- ខេបក៏បានធ្វើការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំលើការប្រើប្រាស់សៀវភៅ ដោយប្រើប្រាស់វេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម ដូចជា Telegram និង Facebook ក៏ដូចជាការចុះទៅមើលផ្ទាល់។
- BFC គ្រប់គ្រងការស្ទង់មតិសាលាតាមពេលវេលាជាក់ស្តែងដោយប្រើ KoBoToolBox និង Google Survey ដើម្បីតាមដានការចូលប្រើសៀវភៅដែលបានផ្តល់តាមសាលា។
- បានផ្តល់ការបណ្តុះបណ្តាលស្តួលដល់បណ្ណារក្សក្នុងមួយឆ្នាំម្តង ដើម្បីបង្កើនជំនាញរបស់បណ្ណារក្សក្នុងការគ្រប់គ្រងបណ្ណាល័យ ដោយប្រើប្រាស់សៀវភៅណែនាំប្រតិបត្តិបណ្ណាល័យសតវត្សរ៍ទី២១ ដែលទើបបង្កើតថ្មីជាឯកសារយោងសំខាន់។

## រូបភាពសកម្មភាព

***ការបរិច្ចាគសៀវភៅ៖*** *បណ្ណារក្សតាមសាលាគោលដៅមកបន្ទប់តាំងបង្ហាញសៀវភៅរបស់គម្រោងដែលមានទីតាំងស្ថិតនៅក្នុងខេត្តកំពង់ចាម ដើម្បីជ្រើសរើស និងទទួលសៀវភៅ (មើលរូបភាព)។ ចំនួនសរុបមានសាលាចំនួន៥៦ បានមកទស្សនាបន្ទប់តាំងបង្ហាញសៀវភៅរបស់គម្រោងក្នុងការទទួលសៀវភៅអំណោយដែលពួកគេបានដាក់ពាក្យស្នើសុំក្នុងអំឡុងឆ្នាំសិក្សា ២០២៣។➔*





***សកម្មភាពបណ្តុះបណ្តាល៖*** *ក្នុងអំឡុងពេលនៃការបន្តរយៈពេល៦ខែ គម្រោងមិនបានផ្តល់ការបណ្តុះបណ្តាលគ្រូបង្គោលដល់សាលារៀនដូចសព្វមួយដងឡើយ ដោយសារតែកង្វះថវិកា។ ជំនួសឱ្យសកម្មភាពទាំងនេះ គម្រោងបានរៀបចំ Webinars ជាច្រើនតាមរយៈ Zoom ក្នុងខែតុលា និងខែធ្នូ ឆ្នាំ២០២៣។ Webinars បាននិយាយអំពី "កំណប់ទ្រព្យដែលលាក់៖ ការបង្ហាញពីតួនាទីសំខាន់របស់បណ្ណាល័យសាលា" និង "របៀបដែលអ្នកប្រឹក្សាការអានបណ្ណាល័យសាធារណៈ (RC) បន្ថែមគុណតម្លៃដល់ បណ្ណាល័យនៅសាលានៅប្រទេសហូឡង់"។*

# គម្រោង ងាយស្រួលរៀន (E2L) - ខេត្តព្រៃវែង

*"ការរៀបចំគម្រោងដោយប្រើសកម្មភាពចម្រុះដើម្បីធានានូវផលជះរយៈពេលយូរក្នុងការអប់រំ"*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| ម្ចាស់ជំនួយ | អង្គការឆាលហ្វានកម្ពុជា |
| អ្នកទទួលផលផ្ទាល់ | ៥ ៨៤២ |
| ថវិកាឆ្នាំសិក្សា២០២៣ | ២៨២.៧៤៦.៥០៨,៨០រៀល |
| តម្លៃឯកតាក្នុងសិស្សម្នាក់ | ៤៨.៣៩៨,៩២រៀល |
| ខេត្តគោលដៅ | ព្រៃវែង |
| ស្រុកគោលដៅ | ១ (កំពង់ត្របែក) |
| សាលាបឋមសិក្សាគោលដៅ | ១១ សាលា |
| សាលាគោលដៅមធ្យម | មិនមាន |
| កាលបរិច្ឆេទចាប់ផ្តើម | ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ |
| កាលបរិច្ឆេទបញ្ចប់ | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ |

## គោលបំណង

គោលដៅ និងគោលបំណងនៃគម្រោង E2L បន្តមានភាពស៊ីសង្វាក់គ្នាយ៉ាងខ្លាំងជាមួយនឹងក្របខ័ណ្ឌគោលនយោបាយសាលាមិត្តភាពកុមាររបស់ក្រសួង។ ក្នុងន័យនេះ សាលារៀនបង្កើតផែនការលើទិដ្ឋភាពទាំងប្រាំមួយនៃគោលនយោបាយ និងធាតុចូលបច្ចេកទេស ផ្តោតលើលទ្ធភាពទទួលបានការអប់រំ គុណភាព និងការគ្រប់គ្រង។ ក្របខ័ណ្ឌគោលដៅផ្លូវការនៃគម្រោងត្រូវបានសង្ខេបដូចខាងក្រោម៖

**គោលបំណងគម្រោង៖** គោលដៅកម្រិតគោលបំណងរបស់កម្មវិធីគឺដើម្បីអភិវឌ្ឍគំរូសាលារៀនដែលងាយស្រួលសម្រាប់កុមារ ដែលពិតជាល្អឥតខ្ចោះនៅក្នុងសមាសភាគជាច្រើន រួមទាំងគុណភាពអប់រំ បរិយាប័ន្ន និងការចូលរួមពីភាគីពាក់ព័ន្ធក្នុងតំបន់។ គម្រោងនេះជួយដល់សាលាបឋមសិក្សាគោលដៅចំនួន 11 ដើម្បីឱ្យលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពពេញលេញ។

**គោលបំណងទី១៖** ធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបាន និងការរក្សាបាននូវកុមារី និងក្មេងប្រុសដែលមានអាយុចូលសាលាបឋមសិក្សាដែលមាន និងគ្មានពិការភាពនៅក្នុងសាលាបឋមសិក្សាគោលដៅ។

**គោលបំណងទី២៖** ការកែលម្អបរិយាកាសសាលារៀន និងការបង្រៀន និងការរៀនស្របតាមគោលនយោបាយសាលាដែលងាយស្រួលសម្រាប់កុមារនៅក្នុងសាលាគោលដៅ។

**គោលបំណងទី៣៖** ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់សាលាត្រូវបានពង្រឹង ដើម្បីធានាបាននូវការបង្កើនគណនេយ្យភាព ភាពជាម្ចាស់ និងការឆ្លើយតបយេនឌ័រ។

**គោលបំណងទី៤៖** សមត្ថភាពបច្ចេកទេសរបស់ក្រុមគម្រោងក្នុងកម្មវិធីអប់រំត្រូវបានពង្រឹងតាមរយៈឱកាសបណ្តុះបណ្តាលផ្សេងៗគ្នា។

## បច្ចុប្បន្នភាពគម្រោង

**សារតាទូទៅ៖** គម្រោងងាយស្រួលរៀន( E2L) នៅខេត្តព្រៃវែង បានបញ្ចប់នៅចុងខែមិថុនា ឆ្នាំ២០២៣ បន្ទាប់ពីដំណើរការអស់រយៈពេល៣ឆ្នាំក្រោមវដ្តនៃមូលនិធិបច្ចុប្បន្ន។ ក្នុងអំឡុងពេលប្រតិបត្តិការរបស់ខ្លួន គម្រោងបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងសម្ភារៈយ៉ាងយកចិត្តទុកដាក់ដល់សាលាបឋមសិក្សាជនបទចំនួន១១សាលា ក្នុងខេត្តក្រីក្រខ្លាំងមួយ។ កុមារជិត ៦០០០នាក់បានទទួលអត្ថប្រយោជន៍ពីប្រតិបត្តិការរបស់គម្រោងនេះ។ គម្រោង E2L ប្រើប្រាស់ការរចនារួមបញ្ចូលគ្នាយ៉ាងទូលំទូលាយ ដែលចូលរួមក្នុងបរិយាកាសសិក្សារបស់កុមារជាច្រើន រួមទាំងឧបសគ្គនានាក្នុងការចូលសាលារៀន បរិយាកាសក្នុងថ្នាក់ និងការបង្រៀន សន្តិសុខ ការចូលរួមពីមាតាបិតា និងសហគមន៍ ការគ្រប់គ្រងសាលារៀនផងដែរ។ វិធីសាស្ត្រក្នុងការអភិវឌ្ឍសាលារៀននេះគឺជាលក្ខណៈពិសេសមួយក្នុងការកំណត់វិធីសាស្ត្ររបស់ខេបចំពោះការអភិវឌ្ឍការអប់រំ។

**សមិទ្ធផល៖** នៅពេលដែលគម្រោងបានបញ្ចប់ វាអាចមើលទៅលើសមិទ្ធផលមួយចំនួនធំ រួមទាំងកំណត់ត្រានាំការចុះឈ្មោះខ្ពស់ជាង៩៥%។ ការដាក់ប្រព័ន្ធព្រមានជាមុន ដើម្បីការពារនៃការបោះបង់ការសិក្សា។ ការពង្រឹងលើពិន្ទុសម្រាប់ជំនាញអាន និងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងជាមួយនឹងគណៈកម្មការគ្រប់គ្រងសាលារៀន និងក្រុមប្រឹក្សាកុមារដែលបានពង្រឹង។ គម្រោងនេះក៏បានដាក់ឲ្យប្រើប្រាស់នូវបរិក្ខាបណ្ណាល័យរបស់សាលាកម្រិតខ្ពស់ ដែលបានបង្ហាញពីការពេញនិយមយ៉ាងខ្លាំងទាំងកុមារ និងសហគមន៍។

**និរន្តរភាព៖** នៅពេលគម្រោងបិទបញ្ចប់ ខេបបានរៀបចំសិក្ខាសាលាស្តីពីនិរន្តរភាពជាបន្តបន្ទាប់នៅដើមឆ្នាំ២០២៣ ដើម្បីបង្កើតផែនការនិរន្តរភាពដែលកំណត់ធនធានហិរញ្ញវត្ថុក្នុងស្រុក ដើម្បីគាំទ្រសកម្មភាពគម្រោងសំខាន់ៗដែលសាលារៀន និងសហគមន៍យល់ថា ជាសកម្មភាពអាទិភាព (ឧ. សកម្មភាពបំណិនជីវិត ក្រុមប្រឹក្សាកុមារ សកម្មភាពបណ្ណាល័យជាដើម។ល។ សាលារៀនបានរាយការណ៍ថាពួកគេទទួលបានជោគជ័យយ៉ាងខ្លាំងក្នុងការកំណត់អត្តសញ្ញាណធនធានក្នុងស្រុកបែបនេះ ដើម្បីធានាបាននូវការកែលម្អប្រកបដោយនិរន្តរភាព។ ខេបក៏បានធ្វើការប្តេជ្ញាចិត្តក្នុងការប្រើប្រាស់ធនធានផ្ទៃក្នុងរបស់ខ្លួន ដើម្បីបន្តទំនាក់ទំនងជាមួយសាលារៀន និងសហគមន៍ និងស្វែងរកមូលនិធិពីខាងក្រៅបន្ថែមទៀតសម្រាប់ការកែលម្អបន្ថែមនៅក្នុងសាលារៀន។

## ភាពសកម្មភាព



*បណ្ណាល័យសតវត្សរ៍ទី២១ ក្នុងសាលា E2L ខេត្តព្រៃវែង។ ការរចនា និងបច្ចេកវិជ្ជាទំនើបជួយពង្រឹងបរិយាកាសសិក្សានៅជនបទយ៉ាងខ្លាំង។*





*ការសិក្សា M-learning និងការណែនាំអំពីបច្ចេកវិទ្យា ICT នៅក្នុងសាលា E2L ភាគច្រើនបានធ្វើការយ៉ាងច្រើនក្នុងការបង្កើនជំនាញអានក៏ដូចជាការរៀនមុខវិជ្ជាផ្សេងៗទៀត។ សាលារៀនកំពុងប្រើប្រាស់បណ្ណាល័យជាប្រចាំ និងមានប្រេកង់ច្រើនជាងការពិតកាលពីអតីតកាល។*

## សកម្មភាពសំខាន់ៗ

- **ធ្វើឱ្យប្រសើរឡើងនូវការចូលប្រើប្រាស់ និងការរក្សាទុកកុមារី និងកុមារាដែលមានអាយុចូលសាលាបឋមសិក្សាដែលមាន និងគ្មានពិការភាពនៅក្នុងសាលាបឋមសិក្សាគោលដៅ។**
  - ការគូសផែនទីសាលារៀន និងយុទ្ធនាការចុះឈ្មោះចូលរៀនបានធ្វើឡើងនៅក្នុងសាលាគោលដៅទាំងអស់ ដើម្បីកំណត់អាយុចូលរៀន និងកុមារងាយរងគ្រោះ។
  - ការឧបត្ថម្ភផ្នែកលើតម្រូវការដែលបានផ្តល់ដល់កុមារដែលងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងពិការ។
- **ការកែលម្អបរិស្ថានសាលារៀន និងការបង្រៀន និងការរៀនស្របតាមគោលនយោ បាយសាលាកុមារមេត្រីនៅក្នុងសាលាគោលដៅ។**
  - បរិយាកាសសិក្សាក្នុងថ្នាក់ត្រូវបានពង្រឹង និងផ្តល់សម្ភារបង្រៀននិងរៀន។
  - គ្រូបឋមសិក្សា និងនាយកសាលាក្នុងសាលាគោលដៅ ដែលបានទទួលការបណ្តុះបណ្តាលលើវិធីសាស្ត្របង្រៀនអំពីសាលាកុមារមេត្រី។
  - បណ្ណាល័យសាលាត្រូវបានបង្កើតឡើងជាកន្លែងសិក្សាដែលអាចបត់បែនបាន ដើម្បីជួយលើកកម្ពស់ទម្លាប់អាន។
  - ការបណ្តុះបណ្តាល ICT ក្នុងវិស័យអប់រំ និងជំនួយបច្ចេកទេស ផ្តល់ជូនលោកគ្រូអ្នកគ្រូនាយកសាលា និងបុគ្គលិកពាក់ព័ន្ធ ដើម្បីប្រើប្រាស់ ICT ក្នុងដំណើរការសិក្សា។
- **បណ្តុះបណ្តាលគ្រូ និងអ្នកគ្រប់គ្រងសាលាក្នុងវិធីលើកកម្ពស់ការសិក្សាអក្ខរកម្ម និងលេខនពន្ធនៅថ្នាក់ដំបូង**
  - ពង្រឹងប្រព័ន្ធក្នុងសាលា ដើម្បីដោះស្រាយការរៀនយឺត។
  - ការធ្វើទ្រង់ទ្រាយ (ឧ. ការធ្វើតេស្តដំណាក់) និងការវាយតម្លៃសរុបជាប្រចាំ។

# គម្រោង ងាយស្រួលរៀន (E2L) - ខេត្តក្រចេះ

*"ការរៀបចំគម្រោងដោយប្រើសកម្មភាពចម្រុះដើម្បីធានានូវផលជះរយៈពេលយូរក្នុងការអប់រំ"*

## ប្រវត្តិកម្មវិធី

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការឆាលហ្វានកម្ពុជា (និងឆាលហ្វានកូរ៉េ) |
| **អ្នកទទួលផលផ្ទាល់** | ៦១៥ (ស្រី៣១៤នាក់) |
| **ថវិកាឆ្នាំសិក្សា២០២៣** | ៥១០.៥៧០.៣៥៨,៨២រៀល |
| **តម្លៃឯកតាក្នុងសិស្សម្នាក់** | ៨៣០.១៩៥,៧១រៀល |
| **ខេត្តគោលដៅ** | ក្រចេះ |
| **ស្រុកគោលដៅ** | ២ (សំបូរ និងអូរគ្រៀងសែនជ័យ) |
| **សាលាបឋមសិក្សាគោលដៅ** | បឋម ៧ និងសាលាឧប.២ |
| **សាលាមធ្យមគោលដៅ** | មិនមាន |
| **កាលបរិច្ឆេទចាប់ផ្តើម** | ០១ ធ្នូ ២០២១ |
| **កាលបរិច្ឆេទបញ្ចប់** | ៣០ វិច្ឆិកា ២០២៤ |

## គោលបំណង

**គោលបំណង៖** ការលើកកម្ពស់គុណភាពនៃការអប់រំបឋមសិក្សាសម្រាប់កុមារទាំងអស់នៅស្រុកសំបូរ ខេត្តក្រចេះ។

**លទ្ធផលទី១៖** យុទ្ធនាការប្រមូលកុមារា កុមារីគ្រប់អាយុចូលរៀនបានចូលរៀនទាំងអស់គ្នាទាំងពិការភាព និងគ្មានពិការភាពនៅក្នុងតំបន់គោលដៅត្រូវបានកើនឡើង។

**លទ្ធផលទី២៖** លទ្ធផលសិក្សារបស់កុមារត្រូវបានកើនឡើង។

**លទ្ធផលទី៣៖** ការគ្រប់គ្រង និងអភិបាលកិច្ចដែលមានមូលដ្ឋានលើសាលារៀនត្រូវបានពង្រឹង និងក្លាយជាការចូលរួមកាន់តែខ្លាំងឡើង យល់ដឹងពីយេនឌ័រ ពិការភាព និងគណនេយ្យភាពនៅក្នុងសហគមន៍ដែលបម្រើសេវា។

## បច្ចុប្បន្នភាពគម្រោង

គម្រោង E2L បានចាប់ផ្តើមដំបូងជាកម្មវិធីសាកល្បងនៅក្នុងឆ្នាំ២០១៥ នៅក្នុងខេត្តស្វាយរៀង និងបានឆ្លងកាត់បទពិសោធន៍ជាច្រើនទៅខេត្តផ្សេងទៀត។ E2L ប្រើការរចនាគម្រោងរួមបញ្ចូលគ្នាដែល បណ្តាលឱ្យមានវិធីសាស្ត្រពហុវិមាត្រក្នុងការអភិវឌ្ឍ។ ឥឡូវនេះ ខេបបានកំពុងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសសម្រាប់ការធ្វើម្តងទៀតនៃគម្រោង E2L នៅក្នុងខេត្តក្រចេះ ដែលបានចាប់ផ្តើមនៅឆ្នាំ២០២១ ស្របតាមសំណើរបស់អង្គការឆាលហ្វាន។ គម្រោងបានរចនាផែនការរបស់គម្រោងជាបន្តបន្ទាប់ទទួលបានការសរសើរ និងការគាំទ្រជាគម្រោងដ៏ល្អបំផុតមួយរបស់ខេប។ គម្រោងបច្ចុប្បន្ននៅខេត្តក្រចេះ រួមបញ្ចូលធាតុជាច្រើនក្នុងការសាកល្បងដំបូងឈរលើបទពិសោធន៍គ្រឹះ ៥ឆ្នាំ។ យន្តការណ៍ពង្រឹង និងចុះសម្រុងគ្នាយ៉ាងល្អជាមួយនឹងគោលនយោបាយសាលាកុមារមេត្រីរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើការតស៊ូមតិសម្រាប់វិធីសាស្ត្រពហុវិមាត្រក្នុងការអភិវឌ្ឍ។

ទោះយ៉ាងណាក៏ដោយ គម្រោង E2L នាពេលបច្ចុប្បន្ននេះ ខុសពីបរិបទដើមលើវិធីសាស្ត្រសំខាន់ៗ។ ទី១: នេះគឺជាគម្រោងអនុវត្តដោយខ្លួនឯង ដោយមានការគាំទ្រសហការពីនាយកដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា (ឧ. នាយកដ្ឋានបឋមសិក្សា) ។ ទី២: គម្រោងនេះរួមបញ្ចូលធាតុជាច្រើននៃការអប់រំពីចម្ងាយ ដើម្បីដោះស្រាយការបាត់បង់ការសិក្សាដែលបណ្តាលមកពីជំងឺរាតត្បាត Covid19 ដែលមិនមែនជាបញ្ហានៅក្នុងការសាកល្បងដំបូងឡើយ។

គម្រោង E2L ក្នុងខេត្តក្រចេះ ថ្មីៗនេះត្រូវបានរៀបចំឡើងវិញរហូតមកដល់ពេលនេះ រួមមាន៖ សាលាបឋមសិក្សាចំនួន៧ (កើនឡើងពី៦ពីមុន) ព្រមទាំងសាលាឧបសម្ព័ន្ធចំនួន២។ រចនាសម្ព័ន្ធគ្រប់គ្រងរបស់គម្រោងក៏ត្រូវបានផ្លាស់ប្តូរទៅពីដៃគូក្នុងស្រុកផ្សេងទៀតមកឱ្យខេប ដើម្បីជួយពង្រឹងការគាំទ្រផ្នែកបច្ចេកទេសអប់រំ។

សកម្មភាពសំខាន់ៗនៅឆ្នាំនេះបានអនុវត្តតាមដំណើរការធ្វើឱ្យប្រក្រតីភាពឡើងវិញ នៅពេលដែលជំងឺរាតត្បាត Covid19 ថយចុះក្នុងការរងចាំមួយរយៈពេល។ ដូច្នេះ ការអនុវត្តឆ្នាំទី៣បានត្រឡប់ទៅសកម្មភាពដែលផ្តោតលើការកសាងសមត្ថភាពរយៈពេលវែង និងការកែលម្អប្រកបដោយនិរន្តរភាពនៅក្នុងលទ្ធផលសិក្សា។ សកម្មភាពជាធម្មតានៃប្រភេទនេះលើកកម្ពស់គុណភាពអប់រំឱ្យប្រសើរឡើង ការណែនាំ ការបង្វឹកតាមសាលារៀន និងការគ្រប់គ្រងតាមសាលារៀន ដើម្បីលើកកម្ពស់គណនេយ្យភាព និងស្វ័យភាពរបស់សាលារៀន។

## សកម្មភាពសំខាន់ៗ

- **ការធ្វើឱ្យប្រសើរឡើងនូវការចូលប្រើប្រាស់ និងការរក្សាទុកកុមារី និងក្មេងប្រុសដែលមានអាយុចូលសាលាបឋមសិក្សាដែលមាន និងគ្មានពិការភាពនៅក្នុងសាលាបឋមសិក្សាគោលដៅ។**
  - យុទ្ធនាការគូសផែនទីសាលារៀន និងចុះឈ្មោះចូលរៀនដែលធ្វើឡើងនៅគ្រប់សាលាគោលដៅដើម្បីកំណត់អាយុចូលរៀន និងកុមារងាយរងគ្រោះ។
  - ជំនួយផ្អែកលើតម្រូវការផ្តល់ដល់កុមារដែលងាយរងគ្រោះផ្នែកសេដ្ឋកិច្ច និងពិការ។
  - សេវាអប់រំតាមសហគមន៍ ផ្តល់ជូនកុមារនៅតាមសាលាភូមិឃុំ ក្នុងអំឡុងកូវីដ១៩។
- **ការកែលម្អបរិយាកាសសាលារៀន ការបង្រៀន និងការរៀនស្របតាមគោលនយោបាយសាលាកុមារមេត្រីនៅក្នុងសាលាគោលដៅ។**
  - បរិយាកាសសិក្សាក្នុងថ្នាក់ត្រូវបានពង្រឹង និងផ្តល់សម្ភារៈបង្រៀន និងរៀន។
  - គ្រូបឋមសិក្សា និងនាយកសាលាក្នុងសាលាគោលដៅ ដែលបានទទួលការបណ្តុះបណ្តាលអំពីវិធីសាស្ត្របង្រៀនរបស់សាលាកុមារមេត្រី។
  - បណ្ណាល័យសាលាត្រូវបានបង្កើតឡើងជាកន្លែងសិក្សាដែលអាចបត់បែនបាន ដើម្បីជួយលើកកម្ពស់ទម្លាប់នៃការអាន។
- **ការកសាងសមត្ថភាពទូទៅ**
  - វគ្គបណ្តុះបណ្តាលស្តីពី ICT ក្នុងវិស័យអប់រំ និងជំនួយបច្ចេកទេសផ្តល់ដល់លោកគ្រូ អ្នកគ្រូ នាយកសាលា និងបុគ្គលិកពាក់ព័ន្ធ ដើម្បីប្រើប្រាស់ ICT ក្នុងដំណើរការសិក្សា។
  - ការបណ្តុះបណ្តាលគ្រូ និងអ្នកគ្រប់គ្រងសាលាក្នុងវិធីលើកកម្ពស់អក្ខរកម្ម និងលេខនៅថ្នាក់ដំបូង។
  - ពង្រឹងប្រព័ន្ធក្នុងសាលារៀន ដើម្បីដោះស្រាយការបោះបង់ការសិក្សា។
  - ការធ្វើតេស្តវាយតម្លៃ (ឧទាហរណ៍ ការធ្វើតេស្តដំណាក់) និងការវាយតម្លៃសរុបជាទៀងទាត់
- **ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងរបស់សាលាត្រូវបានពង្រឹង ដើម្បីធានាបាននូវការបង្កើនគណនេយ្យភាព ភាពជាម្ចាស់ និងការឆ្លើយតបយេនឌ័រ។**
  - សិក្ខាសាលាបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន
  - ការធ្វើផែនការកែលម្អសាលារៀនដោយគណៈកម្មការគ្រប់គ្រងសាលាជាមួយការគាំទ្របណ្តុះបណ្តាល។

## រូបភាពសកម្មភាព



*សកម្មភាពពង្រឹងការអានរឿងនៅក្នុងបណ្ណាល័យដែលបង្កើតឡើងដោយគម្រោង E2L។*



*កុមារសិក្សាកម្មអប់រំបំណិនជីវិតនៅក្នុងសួនជីវៈចម្រុះរបស់សាលារៀនដែលបានបង្កើតឡើងដោយគម្រោង E2L។*



*កុមារនៅមូលដ្ឋានបានដឹកនាំធ្វើយុទ្ធនាការប្រមូលកុមារក្រៅសាលាចុះឈ្មោះចូលរៀន។*

## បញ្ហាប្រឈមសំខាន់ៗ

សាលារៀននៅឆ្ងាយ កុមារជនជាតិភាគតិចមួយចំនួនមិននិយាយភាសាខ្មែរ ការបាត់បង់ការសិក្សាគឺធ្ងន់ធ្ងរដោយសារការបិទសាលា កង្វះគ្រូគឺធ្ងន់ធ្ងរ ចម្ងាយទៅសាលារៀនគឺល្អណាស់សម្រាប់កុមារជាច្រើន។

# គម្រោង សហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំ នៅបឹងទន្លេសាបភាគខាងលិច តំបន់១ (FOSTER)

*“ចូលរួមទាំងអស់គ្នាដើម្បីអប់រំកុមារកម្ពុជា”*



## ប្រវត្តិគម្រោង

| | |
|---|---|
| **ម្ចាស់ជំនួយ** | សហភាពអឺរ៉ុប និង អេដ អេ អាក់ស្យុង |
| **អ្នកទទួលផលផ្ទាល់** | ៦ ១៧១នាក់ (ស្រី ៣ ០៨៥នាក់) |
| **ថវិកាឆ្នាំសិក្សា២០២៣** | ៧០៩.៥៤៧.៦២១,២២រៀល |
| **តម្លៃឯកតាក្នុងសិស្សម្នាក់** | ១១៤.៩៨០,៩៨រៀល |
| **ខេត្តគោលដៅ** | ៣ (សៀមរាប បន្ទាយមានជ័យ និងបាត់ដំបង) |
| **ស្រុកគោលដៅ** | ៩ (សូទ្រនិគមន៍ បាគង ក្រុងសៀមរាប ពួក មង្គលបូរី ថ្មគោល ឯកភ្នំ សង្កែ និងមោងឫស្សី) |
| **បឋមសិក្សាគោលដៅ** | ៣១ សាលា |
| **អនុវិទ្យាល័យគោលដៅ** | ១៤ សាលា |
| **កាលបរិច្ឆេទចាប់ផ្តើម** | ថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ |
| **កាលបរិច្ឆេទបញ្ចប់** | ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤ |

## បច្ចុប្បន្នភាពគម្រោង

**ព័ត៌មានបច្ចុប្បន្នភាពគម្រោង៖** នៅឆ្នាំនេះ គម្រោងសហគមន៍នេសាទបង្កើតការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបខាងលិចតំបន់១ ហៅកាត់ថា (FOSTER) បានផ្តោតយ៉ាងខ្លាំងលើការវិនិយោគក្នុងការគាំទ្រផ្នែកការប្រើកញ្ចប់បំប៉នសិស្សរៀនយឺត (RAL) ដែលបង្កើតឡើងដោយសហការរវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយនាយកដ្ឋានបឋមសិក្សា។ កញ្ចប់នេះត្រូវបានអនុវត្តដោយភ្ជាប់ជាមួយនឹងការសម្រេចចិត្តដើម្បីបង្កើនម៉ោងសិក្សាសរុបក្នុងមួយថ្ងៃនៅក្នុងសាលាបឋមសិក្សាមួយចំនួន។ ដោយផ្អែកលើការធ្វើតេស្តដោយប្រើលើឧបករណ៍ស្តង់ដាររបស់ក្រសួងអប់រំ យុវជន និងកីឡា អត្រាធ្លាក់ចុះនៃការសិក្សាបានថយចុះប្រហែល៦៥% នៅទូទាំងប្រទេស។ ប្រធានបទសំខាន់មួយទៀតក្នុងការអនុវត្តនៅឆ្នាំនេះក្នុងចំណោមសកម្មភាពផ្សេងទៀត គឺផ្តោតលើការពង្រីកការអប់រំបំណិនជីវិតនៅកម្រិតមធ្យមសិក្សា។ ក្នុងន័យនេះ គម្រោងបានណែនាំកម្មវិធីសិក្សា P.A.C.E. (បង្កើតឡើងដោយក្រុមហ៊ុន Gap និងបានធ្វើបរិបទដោយអង្គការ ខេប) ឱ្យស្របនឹងបរិបទប្រទេសកម្ពុជា ទៅកាន់សាលាមធ្យមសិក្សាជាច្រើននៅក្នុងគោលដៅរបស់គម្រោង។ កម្មវិធីសិក្សាថ្មីនេះមានភាពជឿនលឿន ហើយផ្តោតលើការអភិវឌ្ឍសមត្ថភាពរបស់សិស្ស ការគិតពិចារណា ចេះកំណត់បញ្ហា ចេះដោះស្រាយបញ្ហា មានសហគ្រិនភាព ការងារក្រុម និងការបង្កើនជម្រើសអាជីពដល់សិស្ស។ ដូច្នេះហើយ កិច្ចខិតខំប្រឹងប្រែងធំៗត្រូវបានបញ្ចប់នៅឆ្នាំនេះ ដើម្បីបង្កើនគុណភាពអប់រំនៅគ្រប់សាលាទាំងអស់របស់គម្រោង។

**ការប្រើប្រាស់ការរចនាគម្រោងបែបពហុវិស័យ៖** គម្រោង FOSTER គឺជាគម្រោងរបស់ខេបថ្មីមួយទៀតដែលទើបតែចាប់ផ្តើមនៅដើមឆ្នាំ២០២២។ គម្រោងនេះមានភាពខុសប្លែកពីគម្រោងខេបផ្សេងៗទៀត ព្រោះវាមានការរចនាពហុវិស័យដែលមិនមែនផ្តោតលើការអប់រំតែមួយមុខប៉ុណ្ណោះទេ គម្រោងរួមបញ្ចូលវិស័យការចិញ្ចឹមជីវិត បញ្ហាប្រែប្រួលអាកាសធាតុ និងសុខភាពអនាម័យផងដែរ។ ខេបទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពដែលផ្តោតលើការអប់រំ ខណៈពេលដែលដៃគូអភិវឌ្ឍន៍ផ្សេងទៀតដោះស្រាយបញ្ហានៅក្នុងវិស័យផ្សេងទៀត។ FOSTER គឺជាគម្រោងតែមួយគត់របស់ខេបដែលមានការរចនាពហុវិស័យ ហើយត្រូវបានដឹកនាំដោយអុកស្វាម-កម្ពុជា (Oxfam-GB)។

**ហេតុអ្វីបានជាធ្វើការនៅក្នុងបឹងទន្លេសាប៖** ខណៈពេលដែលបឹងទន្លេសាប (TS) គឺជាតំបន់ផលិតជលផលកំពូលមួយក្នុងចំណោមតំបន់ផលិតជលផលកំពូលទាំងបួននៅលើពិភពលោក និងរួមចំណែកដល់ផលិតកម្មទឹកសាបភាគច្រើនរបស់កម្ពុជា បឹង និងអាងរបស់វាស្ថិតនៅក្រោមសម្ពាធកាន់តែខ្លាំងឡើងពីការគំរាមកំហែងជាច្រើនរូបភាព រួមមានការប្រែប្រួលអាកាសធាតុ (CC) ការធ្វើអាជីវកម្មខុសច្បាប់លើជលផល និងសត្វព្រៃ ការទន្ទ្រានព្រៃលិចទឹក និងការសាងសង់ទំនប់ទឹកខាងលើនៃផ្ទៃអាងដោយមិនមានការសិក្សាច្បាស់លាស់ពីផលប៉ះពាល់ដល់ផ្ទៃអាងទាំងមូល។ ដោយសារសហគមន៍ដែលរស់នៅក្នុងភូមិបណ្តែតទឹកនៅភាគខាងលិចបឹង ពឹងផ្អែកយ៉ាងខ្លាំងលើទឹកបឹង និងធនធានពាក់ព័ន្ធ ការគំរាមកំហែងទាំងនេះបាននឹងកំពុងរួមចំណែកដល់ការកម្រិតភាពក្រីក្រខ្ពស់ អសន្តិសុខស្បៀង និងការដួលរលំបរិស្ថាននៅក្នុងតំបន់។

## គោលដៅ

១. **វត្ថុបំណងរួម៖** រួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងភាពធន់របស់សហគមន៍នេសាទនៅតំបន់បម្រុងអាងទន្លេសាប។

២. **វត្ថុបំណងជាក់លាក់៖** ការកែលម្អជីវភាពរស់នៅប្រកបដោយនិរន្តរភាព និងការបង្កើនលទ្ធភាពទទួលបានសេវាសំខាន់ៗសម្រាប់សហគមន៍នេសាទនៅភាគខាងលិចតំបន់១នៃបឹងទន្លេសាប និងកាត់បន្ថយសម្ពាធបរិស្ថានលើតំបន់ក្នុងរយៈពេលវែង។

## រូបថតសកម្មភាព



*គម្រោងបានធ្វើការជាមួយម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន ដើម្បីរៀបចំព្រឹត្តិការណ៍ទិវាគ្រូបង្រៀននៅសាលាបឋមសិក្សាប្រាសាទ ស្រុកពួក។ ព្រឹត្តិការណ៍នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកទឹកចិត្តដល់គ្រូបង្រៀនឱ្យបានគិតពីតួនាទីរបស់ពួកគាត់ពិតជាមានសារៈសំខាន់ក្នុងការផ្តល់ចំណេះដឹង និងកសាងទំនាក់ទំនងដ៏រឹងមាំជាមួយសិស្ស។*

**បញ្ហាប្រឈមសម្រាប់ការអប់រំរបស់កុមារ៖** កុមាររស់នៅក្នុងតំបន់បឹងទន្លេសាបប្រឈមមុខនឹងបញ្ហាជាច្រើនជាងតំបន់ផ្សេងទៀត។ ជិតមួយភាគបីនៃកុមារដែលមានអាយុចាប់ពី ៥ ទៅ ១៧ ឆ្នាំនៅតំបន់បឹងទន្លេសាបមិនបានចុះឈ្មោះចូលរៀនទេ ខណៈដែល ៣២% នៃអ្នកដែលបានចុះឈ្មោះមានហានិភ័យខ្ពស់នៃការបោះបង់ការសិក្សា។ លទ្ធភាពទទួលបានការអប់រំរបស់កុមារតូចក៏មានកម្រិតផងដែរ ដែលរួមចំណែកដល់ការត្រៀមខ្លួនចូលរៀននៅបឋមសិក្សាមានកម្រិតទាបសម្រាប់កុមារដែលបានចុះឈ្មោះចូលរៀន។ មត្តេយ្យសិក្សាសហគមន៍ដើរតួយ៉ាងសំខាន់ដើម្បីបំពេញបន្ថែមនូវចំនួនសាលារដ្ឋាភិបាលដែលមិនគ្រប់គ្រាន់ ប៉ុន្តែគុណវុឌ្ឍិរបស់អ្នកស្ម័គ្រចិត្តដែលដំណើរការសាលាទាំងនេះមានកម្រិតទាបណាស់នៅឡើយ។ បឹងទន្លេសាបមានសក្តានុពលទេសចរណ៍ធម្មជាតិដ៏ធំសម្បើម ប៉ុន្តែវិស័យនេះនៅមិនទាន់មានការអភិវឌ្ឍដែលមាន ដូចជា កង្វះហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងសេវាកម្មបដិសណ្ឋារកិច្ច ហើយមិនមានលក្ខណៈពិសេសខ្លាំងនៅក្នុងគោលនយោបាយសាធារណៈជាតិ ឬអាទិភាពហិរញ្ញវត្ថុនោះទេ។ កសិកម្ម អនុផលព្រៃឈើ និងការកែច្នៃត្រី គឺជាផ្លូវបង្កើតប្រាក់ចំណូលផ្សេងទៀតនៅក្នុងតំបន់គោលដៅ ប៉ុន្តែសហគមន៍ខ្វះជំនាញដើម្បីដឹងពីសក្តានុពលសេដ្ឋកិច្ចក្នុងតំបន់ ដោយបង្ហាញពីតម្រូវការសម្រាប់ការអប់រំបំណិនជីវិតសម្រាប់យុវជន។ ទាំងនេះគ្រាន់តែជាបញ្ហាប្រឈមមួយចំនួនដែលសហគមន៍ក្នុងបឹងទន្លេសាបជួបប្រទះ។



*តាមរយៈមូលនិធិជំនួយរបស់គម្រោង និងការរៃអង្គាសថវិកាសហគមន៍សាលាបានរៀបចំកន្លែងបរិភោគអាហារដែលប្រសើរឡើង ដែលសិស្សអាចប្រើសម្រាប់អាហារសម្រន់ និងអាហារថ្ងៃត្រង់ពេលពួកគេនៅសាលា។*

# សកម្មភាពសំខាន់ៗ

> **ការវាយតម្លៃមូលដ្ឋាននៃលក្ខខណ្ឌអប់រំ និងការធ្វើផែនទីសិក្សា។**

- ធ្វើការវាយតម្លៃការអប់រំ និងការគូសផែនទីសិក្សានៅសាលារៀននៅក្នុងតំបន់គោលដៅ។
- ធ្វើការពិនិត្យតម្រូវការពិសេសនៅក្នុងសាលាគោលដៅដើម្បីកំណត់អត្តសញ្ញាណកុមារ ដែលមានតម្រូវការសិក្សាផ្នែករាងកាយ និងផ្លូវចិត្ត។

> **កុមារ និងយុវជនត្រូវបានគាំទ្រជាមួយនឹងការអប់រំប្រកបដោយបរិយាបន្ន ដើម្បីចូលរៀន និងរៀន។**

- អនុវត្តកម្មវិធីផ្តល់អាហារពេលព្រឹកដល់សាលារៀននៅតាមសាលាគោលដៅក្នុងកម្រិតមត្តេយ្យសហគមន៍។
- ផ្តល់ជំណោះស្រាយដឹកជញ្ជូនប្រកបដោយនិរន្តរភាព ដើម្បីកែលម្អលទ្ធភាពចូលរៀនរបស់កុមារ។
- ផ្តល់ជំនួយអាហារូបករណ៍ដល់កុមារី និងកុមារាដែលខ្វះខាតនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។
- អនុវត្តកម្មវិធីសិក្សាពហុភាសានៅក្នុងសាលា ដែលសមស្របនឹងវប្បធម៌ និងតម្រូវការរបស់កុមារ។
- បង្កើតសេវាកម្មការចូលរៀនឡើងវិញ/ថ្នាក់បំប៉នសម្រាប់កុមារក្រៅសាលា/សិស្សរៀនយឺត។
- អនុវត្តកម្មវិធីសិក្សាពន្លឿនសម្រាប់កុមារដែលមានអាយុលើស។
- អនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធសម្រាប់សិស្សដែលមានតម្រូវការពិសេស។
- អនុវត្តកម្មវិធីបំណិនជីវិតនៅក្នុងសាលារៀនរួមទាំងបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។

> **សាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា និងអនុវិទ្យាល័យ ដែលមានមូលដ្ឋានតាមសហគមន៍ បំពេញតាមស្តង់ដាជាតិ និងបង្កើនសមត្ថភាពរបស់ពួកគេ ក្នុងការលើកកម្ពស់ការអប់រំថ្នាក់ដំបូង ការពារការបោះបង់ការសិក្សា និងធ្វើឱ្យមានការផ្លាស់ប្តូរនៃអត្រាឆ្លងភូមិសិក្សា។**

- ជួសជុល/សាងសង់សាលាបឋមសិក្សា និងសាលាមត្តេយ្យសហគមន៍ ដែលបំពេញតាមស្តង់ដាសាលាកុមារមេត្រីសម្រាប់កុមារ ដោយផ្តល់ជំនួយដល់សាលា ដែលរៀបចំឡើងដោយភាគីពាក់ព័ន្ធក្នុងសហគមន៍។
- ជ្រើសរើសគ្រូមត្តេយ្យសហគមន៍ដោយផ្តល់ការបណ្តុះបណ្តាលត្រៀមលក្ខណៈរួចជាស្រេចសម្រាប់មត្តេយ្យស្តង់ដា។
- ផ្តល់ការកសាងសមត្ថភាពដល់គ្រូមត្តេយ្យសហគមន៍តាមរយៈវគ្គបណ្តុះបណ្តាល។
- គាំទ្រសាលាមត្តេយ្យសហគមន៍ដើម្បីបំពេញតាមស្តង់ដាគុណវុឌ្ឍិជាតិ។
- ផ្តល់វគ្គបណ្តុះបណ្តាល និងជំនួយបច្ចេកទេសលើវិធីសាស្ត្របង្រៀនពីចម្ងាយ និងយុទ្ធសាស្ត្រអប់រំក្រៅប្រព័ន្ធ។
- ផ្តល់វគ្គបណ្តុះបណ្តាលដល់អាណាព្យាបាល យុវជន និង CBO លើការថែទាំ និងការឆ្លើយតបប្រកបដោយវិជ្ជមាន។
- កសាងសមត្ថភាពដល់ភាគីពាក់ព័ន្ធក្នុងការរៀបចំផែនសាលារៀនប្រចាំឆ្នាំសម្រាប់ការទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្ស។
- ធ្វើសវនកម្មទំនួលខុសត្រូវរបស់សាលា និងបង្កើតផែនការគាំទ្រសាលា ដើម្បីទប់ស្កាត់ការប្រែប្រួលអាកាសធាតុ។
- អនុវត្តប្រព័ន្ធព្រមានទុកជាមុន (EWS) នៅក្នុងសាលារៀនគោលដៅ ដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា។





មូលនិធិជំនួយសាលាដែលផ្តល់ដោយគម្រោងត្រូវបានរួមបញ្ចូលជាមួយមូលនិធិពីសហគមន៍មូលដ្ឋានដើម្បីធ្វើការអភិវឌ្ឍសាលាដែលធ្វើឱ្យប្រសើរឡើងយ៉ាងខ្លាំងដល់បរិយាកាសសិក្សា។ នេះអាចរួមបញ្ចូលការបង្កើតគ្រឿងបរិក្ខាអនាម័យទឹកស្អាតសម្រាប់សិស្សានុសិស្ស ធ្វើឱ្យប្រសើរឡើងនៅអគារ ថ្នាក់រៀនសម្រាប់សិស្ស ការតុបតែងសម្រាប់ថ្នាក់រៀន និងការវិនិយោគតូចៗជាច្រើនទៀតដែលអាចធ្វើឱ្យមានភាពខុសគ្នាយ៉ាងសំខាន់ក្នុងការបង្កើតបរិយាកាសដែលជាទីមេត្រីសម្រាប់កុមារ និងតម្រូវការរបស់កុមារនៅក្នុងសាលា។

# ការងារ និងសមិទ្ធផលសំខាន់ៗ

**ក្នុងអំឡុងឆ្នាំ២០២៣ ការផ្លាស់ប្តូរខាងក្រោមនៃសេវាកម្មអប់រំត្រូវបានសម្រេចដូចតទៅ៖**

- សាលាបឋមសិក្សាចំនួន២០បានទទួលមូលនិធិជំនួយដើម្បីវិនិយោគក្នុងការអភិវឌ្ឍសាលារៀនក្នុងបរិបទសាលាកុមារមេត្រី។
- បានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការវាយតម្លៃសាលាកុមារមេត្រី (CFS) ដល់ប្រតិបត្តិអប់រំ រួមទាំងសមភាគីនៅថ្នាក់ខេត្ត និងស្រុក។
- បានធ្វើការវាយតម្លៃសាលាកុមារមេត្រី (CFS) នៅក្នុងសាលាបឋមសិក្សាចំនួន២០ ដោយប្រើឧបករណ៍ផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- បានធ្វើបទបង្ហាញពីលទ្ធផលនៃការវាយតម្លៃសាលាកុមារមេត្រី (CFS) ដល់ដៃគូដើម្បីពិនិត្យ និងធ្វើសកម្មភាពដើម្បីជួយគាំទ្របន្ថែម។
- ផ្តល់វគ្គបណ្តុះបណ្តាលរំឭកពីការវាស់គំហើញ ដោយមានជំនួយពីគ្រូបង្គោល។ ជាលទ្ធផលនៃសកម្ម ភាពនេះ កុមារចំនួន ៨ ០៨៦នាក់ (ស្រី ៣ ៨៤៥នាក់) ត្រូវបានវាស់នៅកម្រិតសាលារៀន ហើយមួយចំនួនត្រូវបានកំណត់អត្តសញ្ញាណដើម្បីបញ្ជូនទៅកាន់មន្ទីរពេទ្យជំនាញសម្រាប់សកម្មភាពបន្ថែមទៀត។
- បញ្ជូនកុមារចំនួន២៥នាក់ (ស្រី៩នាក់) ដែលកំពុងប្រឈមមុខនឹងគំហើញ ទៅកាន់មន្ទីរពេទ្យកុមារអង្គរ ដើម្បីជួបជាមួយវិជ្ជបណ្ឌិត និងធ្វើការពិនិត្យម្តងទៀតជាមួយម៉ាស៊ីន។ គម្រោងនេះបានគាំទ្របង់ថ្លៃសេវាកម្មដល់មន្ទីរពេទ្យ ការសម្របសម្រួល និងថ្លៃធ្វើដំណើររបស់កុមារ និងគ្រួសារ។
- បានផ្តល់ទូកចំនួនពីរដល់កុមារដែលកំពុងរស់នៅលើទឹក ជាដំណោះស្រាយធ្វើដំណើរពីផ្ទះទៅសាលា ដើម្បីបង្កើនលទ្ធភាពចូលរៀនរបស់កុមារនៅតំបន់ដែលងាយរងគ្រោះពីបឹងទន្លេសាប។ រហូតមកដល់ពេលនេះ កុមារប្រហែល១០នាក់កំពុងទទួលបានអត្ថប្រយោជន៍ពីអន្តរាគមន៍នេះ។
- បានផ្តល់អាហារូបករណ៍កង់ចំនួន៥៧២ (ស្រី ៣២៦នាក់) ដើម្បីគាំទ្រដល់ក្មេងស្រី និងក្មេងប្រុសដែលមកពីគ្រួសារខ្វះខាត ហើយខ្វះមធ្យោបាយធ្វើដំណើរពីផ្ទះមកសាលាបឋមសិក្សា និងអនុវិទ្យាល័យ។
- ផ្តល់កញ្ចប់សម្ភារៈសិក្សាជូនកុមារដែលងាយរងគ្រោះមកពីគ្រួសារដែលមានជីវភាពខ្វះខាតចំនួន១៩៩៩នាក់ (ស្រី៨៦០នាក់) នៅក្នុងកម្រិតបឋមសិក្សាចំនួន៣១ និងអនុវិទ្យាល័យចំនួន១៤។
- ផ្គត់ផ្គង់សម្ភារៈសិក្សាដល់កុមារី និងកុមារាដែលរងគ្រោះចំនួន ១ ២០៤នាក់។
- បានគាំទ្រកុមាររៀនយឺតចំនួន ១៦៤១ (ស្រី៥៩២នាក់) ដោយផ្តល់ការគាំទ្រកម្មវិធីបំប៉នសិស្សរៀនយឺត ៧៨ថ្នាក់។
- បានជួយសិស្សរៀនយឺតចំនួន៤៩០នាក់ (ស្រី១៩៤នាក់) នៅ ថ្នាក់ទី៦ ដោយផ្តល់កញ្ចប់បំប៉ន ហើយបានគាំទ្រដល់ថ្នាក់ចំនួន១៦ថ្នាក់។

- អនុវត្តកម្មវិធីបំណិនជីវិតលើប្រធានបទផ្សេងៗនៅក្នុងសាលាបឋមសិក្សាចំនួន៣១ និងអនុវិទ្យាល័យចំនួន១៤។
- បានរៀបចំសេវាកម្មប្រឹក្សាតាមអេឡិចត្រូនិកដោយប្រើកម្មវិធីត្រីវិស័យរបស់ក្រសួងអប់រំនៅក្នុងសាលាមធ្យមសិក្សាបឋមភូមិចំនួន១៤។
- អនុវត្តការអប់រំពហុភាសាពីរថ្នាក់ដែលមានកុមារចូលរៀនចំនួន ៣៤នាក់ (ស្រី២០នាក់) ដល់កុមាររៀនតាមណាមដែលទទួលបានអត្ថប្រយោជន៍ពីកម្មវិធី។
- បានរៀបចំព្រឹត្តិការណ៍លើកកម្ពស់ការយល់ដឹងអំពីការអប់រំ ដូចជា ទិវាកុមារអន្តរជាតិ យុទ្ធនាការទិវាគ្រូបង្រៀន យុទ្ធនាការចុះឈ្មោះ និងយុទ្ធនាការតាមខ្នងផ្ទះ។
- បានផ្តល់ការវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនបំណិនជីវិតនៅគ្រប់សាលាទាំងអស់។
- បានជួយគ្រូបំណិនជីវិត ប្រតិបត្តិករអប់រំ និងដៃគូចំនួន១៨០នាក់ (ស្រី៩៥នាក់) ឱ្យបានចូលរៀនដោយខ្លួនឯង និងបញ្ចប់ការរៀនតាមប្រព័ន្ធអេឡិចត្រូនិកនៅលើវេបសាយសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់ក្រសួងអប់រំ យុវជន និងកីឡា។



មូលនិធិជំនួយរបស់គម្រោង និងការអេង្គាសថវិកាសហគមន៍បានជួយសាលានេះក្នុងការបង្កើតផ្លូវដើរដែលរួមចំណែកដល់បរិយាកាសដែលមានសណ្តាប់ធ្នាប់ជាងមុនសម្រាប់កុមារ។

# គម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេង ដើម្បីសមធម៌សង្គម ( ខូសេវ/CO-SAVED)

*'គំនិតថ្មីសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងវិស័យអប់រំ។'*



## ប្រវត្តិគម្រោង

| | |
|---|---|
| ម្ចាស់ជំនួយ | សហភាពអឺរ៉ុប/អង្គការ AeA |
| អ្នកទទួលផលផ្ទាល់ | ២០,២៤១ |
| ថវិកាឆ្នាំសិក្សា២០២៣ | ៧៨០.៣៧១.៦១៥,០២រៀល |
| តម្លៃឯកតាក្នុងសិស្សម្នាក់ | ៣៨.៥៥៤រៀល |
| ខេត្តគ្របដណ្តប់ | ៤(កែប កំពត ព្រះសីហនុ និងកោះ កុង) |
| ស្រុកគ្របដណ្តប់ | ១០ |
| សាលាមត្តេយ្យសិក្សាគោលដៅ | ១០ |
| សាលាបឋមសិក្សាគោលដៅ | ៣៥ |
| សាលាមធ្យមសិក្សាគោលដៅ | ៤៣ |
| កាលបរិច្ឆេទចាប់ផ្តើម | ថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ |
| កាលបរិច្ឆេទបញ្ចប់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ |

## គោលបំណង

សហគមន៍នេសាទនៅតំបន់ឆ្នេរប្រែក្លាយមានជីវភាពរស់រវើកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋានប្រកបដោយចីរភាព ពង្រឹងការផ្តល់សេវាកម្មនិងអភិវឌ្ឍបៃតងសំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ និងសមភាព៖

- អភិវឌ្ឍសមត្ថភាព និងពង្រឹងដៃគូ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន។
- ពង្រឹងនូវការផ្តល់សេវាកម្មអប់រំ និងទទួលបានសេវាទឹកស្អាត និងអនាម័យ។ពង្រឹងការផ្តល់ឱកាសសម្រាប់ការប្រកបមុខរបបចិញ្ចឹមជីវិត និងអភិរក្សបរិស្ថាន ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។

## រូបភាពសកម្មភាព



*គ្រូប្រឹក្សាអាជីពបានប្រឹក្សាសិស្សតាមរយៈកម្មវិធីត្រីវិស័យនៅអនសាមគ្គី ខេត្តព្រះសីហនុ។*



*គ្រូបង្គោលបានពិភាក្សាពីការកត់ត្រាសិស្សរងហានិភ័យដោយប្រព័ន្ធរំឭកជាមុន អំឡុងពេលបណ្តុះបណ្តាលស្រុកស្រែអំបិល ខេត្តកោះកុង។*

## បច្ចុប្បន្នភាពគម្រោង

**សាវតាគម្រោង៖** គម្រោងសម្ពន្ធភាពដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសម្លេងសមធម៌សង្គម (ខូសេវ) មានរយៈអនុវត្ត៤ឆ្នាំ ចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៤ និងឆ្នាំ២០២៤ ជាឆ្នាំចុងក្រោយ។ គម្រោងទទួលថវិកាពីសហភាពអឺរ៉ុប និងមូលនិធិកាតាសម្រាប់អប់រំកុមារ។ គម្រោងធ្វើការងារជាសម្ពន្ធភាពជាមួយដៃគូអប់រំ ដូចជា សមាគមន៍បណ្តុះកុមារ អង្គការសកម្មភាពពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម និងអេអាត់ស្បូង។ អង្គការខេបបានប្រតិបត្តិការគម្រោងចំនួន ៤ខេត្តជាប់មាត់សមុទ្រ ដោយគាំទ្រការងារដៃគូ កៀរគរធនធានគាំទ្រនានា ជាពិសេសការងារបច្ចេកទេស និងជំនួយដៃគូសម្រាប់ផលជះមួយដែលមានសារៈសំខាន់ក្នុងការអនុវត្តគម្រោង។

**ការងារអប់រំបរិយាបន្ន៖** គម្រោងធ្វើផ្តោតសំខាន់ខ្លាំងលើការគាំទ្រកុមារបរិយាបន្ន ដើម្បីរក្សាគុណភាពកុមារនៅសាលាគោលដៅ។ ឱ. គម្រោងបានធ្វើការបណ្តុះបណ្តាល គណៈកម្មការគ្រប់គ្រងអាហារូបករណ៍តាមមូលដ្ឋានដែលអ្នកទទួលខុសត្រូវបែងចែកសម្ភារអាហារូបករណ៍ដល់សិស្សងាយរងគ្រោះនៅបឋមសិក្សា និងមធ្យមសិក្សា ក្នុងអំឡុងខែធ្នូឆ្នាំ ២០២៣ ដែលកុមារងាយរងគ្រោះចំនួន ៦២២៧នាក់បានទទួល។ គម្រោងក៏បានកត់ត្រាប្រពន្ធ័រំឭកទុកជាមុនសម្រាប់តាមដានកុមារងាយរងគ្រោះ និងកំណត់អត្តសញ្ញាណផ្សេងៗ។

**សកម្មភាពពង្រឹងសមត្ថភាព៖** អនុវត្តសកម្មភាពផ្តោតលើការកសាងសមត្ថភាពអ្នកពាក់ព័ន្ធដោយប្រើប្រាស់ឧបករណ៍ ដូចជា ប្រព័ន្ធរំឭកទុកជាមុន និងការប្រឹក្សាអាជីពតាមរយៈកម្មវិធីត្រីវិស័យ ប្រើប្រាស់កញ្ចប់បំប៉នសិស្សរៀនយឺត និងកម្មវិធីបំណិនជីវិត។ ការកំណត់ការអភិវឌ្ឍកម្មវិធីអប់រំកុមារតូច និងនៅកម្រិតបឋមសិក្សាគឺមានសារៈសំខាន់។

**ទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធ៖** គម្រោងសង់អាគារមត្តេយ្យសិក្សាសហគមន៍ចំនួន៣ ជួសជុលបន្ទប់រៀនបឋមសិក្សាចំនួន ០៩បន្ទប់នៃពីរសាលាគោលដៅ ជួសជុលបន្ទប់មត្តេយ្យរដ្ឋចំនួន៧បន្ទប់នៃ៧សាលាគោលដៅ ជួសជុលបង្គន់អនាម័យចំនួន២ដែលមាន៦បន្ទប់សម្រាប់គាំទ្រកម្មវិធីកុមារតូច បឋមសិក្សា មធ្យមសិក្សា និងវិនិយោគការងារទឹកស្អាត និងអនាម័យ។

**ផែនការសាលារៀន៖** ជួយគាំទ្រការងារអភិវឌ្ឍន៍ផែនការសាលារៀន តាមកម្មវិធីសាលាកុមារមេត្រី។ ក្នុងឆ្នាំ២០២២ គម្រោងបានគាំទ្រថវិកាអំណោយសាលារៀនចំនួន១៤ នឹងបន្ថែមចំនួន១១សាលាគោលទៀតក្នុងឆ្នាំ២០២៣ ស្មើនឹង២៥សាលា។ ការអនុវត្តផែនការអភិវឌ្ឍន៍សាលាបានបដិភាគជាមួយថវិកាសាលាមានស្រាប់ជាមួយនឹងធនធានផ្សេងៗ។ ការប្រើប្រាស់ថវិកានេះធានាមានប្រសិទ្ធភាពការងារហិរញ្ញវត្ថុរបស់សាលា។ សាលាទទួលបានការបណ្តុះបណ្តាលពីការស្វែងរកមតិគាំទ្របច្ចេកទេសជាច្រើន មានការចូលរួមពីអ្នកពាក់ព័ន្ធក្រុមប្រឹក្សាឃុំ សហគ្រិន និងដៃគូអភិវឌ្ឍន៍ដើម្បីមាននិរន្តរភាពតទៅថ្ងៃអនាគត។

## សកម្មភាពសំខាន់ៗ

**សម្របសម្រួលការបង្កើតបែបបទក្នុងការទំនាក់ទំនង និងធ្វើការជាមួយដៃគូ LAs, LCs, PSRs, CSOs, & SEAs៖**

- គាំទ្រការរកមូលនិធិបដិភាគពីសហវិនិយោគ និងការចែករំលែកកិច្ចការព្រមព្រៀងក្នុងចំណោមដៃគូLAs, LCs, PSRs, CSOs, & SEAs និងសមាជិកសហគមន៍។

**ការអភិវឌ្ឍសមត្ថភាព**

- សង់មត្តេយ្យសិក្សាសហគមន៍ថ្មី តាមស្តង់ដាថ្នាក់ជាតិក្នុងតំបន់គោលដៅ។
- គាំទ្រការប្រជុំផ្លះប់ច្ចេកទេសប្រចាំត្រីមាសរបស់មត្តេយ្យសិក្សា។
- កសាងសមត្ថភាព ក្រុមប្រឹក្សាឃុំស្របក្របខណ្ឌច្បាប់ការគាំពារ និងអភិវឌ្ឍកុមារតូច។

**កម្មវិធីអប់រំកុមារតូចផ្តល់ឱកាសកុមារទទួល**

- គាំទ្រការប្រជុំក្រុមឪពុកម្តាយឬក្រុមផ្សារភ្ជាប់ដើម្បីជួយគាំទ្រការរៀនរបស់កុមារ។
- ផ្តល់និងសម្ភារៈគាំទ្រសាលារៀន ដើម្បីផលិតសម្ភារៈសិក្សាសម្រាប់ការគាំពារ និងអភិវឌ្ឍកុមារតូច។
- ផ្តល់អាហារពេលព្រឹកដល់សាលាមត្តេយ្យសិក្សាសហគមន៍គោលដៅចំនួន៥។
- គាំទ្រការងារវាយតម្លៃមត្តេយ្យស្តង់ដាតាមគុណភាពថ្នាក់ជាតិ។
- គាំទ្រជួសជុលបន្ទប់រៀនតាមរដ្ឋនិងមត្តេយ្យសហគមន៍តាមអប្បរមាស្តង់ដាថ្នាក់ជាតិ។

**លើកកម្ពស់គុណភាពអប់រំ សម្រាប់សិស្សជាកូនអ្នកនេសាទក្នុងគោលដៅគម្រោងខូសេវ៖**

- រៀបចំបណ្តុះបណ្តាលប្រព័ន្ធតាមដានកុមារមានហានិភ័យ។
- ផ្តល់អាហារូបករណ៍ និងកញ្ចប់សម្ភារៈ ដល់សិស្សងាយរងគ្រោះ។
- គាំទ្រការងារនីតិសម្បទាជួសជុល បន្ទប់រៀន មិនទាន់ពេញលេញ។
- ពង្រឹងកម្មវិធីសាលាកុមារមេត្រី និងគាំទ្រផែនការអភិវឌ្ឍសាលារៀន។
- គាំទ្រការងារអប់រំក្រៅប្រព័ន្ធ សម្រាប់កម្រិតសិស្សនៅបឋមសិក្សា។
- គាំទ្រការងារបំប៉នសិស្សក្រៅប្រព័ន្ធឡើងវិញ។
- គាំទ្រថ្នាក់ពន្លឿនសម្រាប់សិស្សលើសអាយុ ក្នុងសាលាគោលដៅ។

**បង្កើនសិស្សចូលរៀន និងជម្រុញគុណភាពសម្រាប់សិស្សមធ្យមសិក្សាក្នុងតំបន់គោលដៅគម្រោងខូសេវ:**

- រៀបចំប្រព័ន្ធឆ្លើយតបរហ័ស ឬប្រព័ន្ធរំឭកជាមុន ការពារសិស្សបោះបង់ការសិក្សា។
- ផ្តល់អាហារូបករណ៍ និងកញ្ចប់សម្ភារៈដល់សិស្សងាយរងគ្រោះ។
- គាំទ្រថ្នាក់បំប៉នសិស្សរៀនយឺតឆ្លងភូមិសិក្សា។
- ផ្តល់ការគាំទ្រកម្មវិធីបំណិនជីវិតមានចំណងជើងចំនួន៣០ ដែលអភិវឌ្ឍឡើងដោយអង្គការសង្គមស៊ីវិល និងក្រសួងអប់រំ ពីថ្នាក់ទី៥ដល់ទី៩។
- គាំទ្រកម្មវិធីត្រីវិស័យតាមរយៈការប្រឹក្សាអាជីព។
- គាំទ្រការងារទឹកស្អាតនិងអនាម័យ ដូចជាសង់បង្គន់ ផ្តល់កន្លែងលាងដៃ និងអភិវឌ្ឍកម្មវិធីក្នុងសាលាគោលដៅគម្រោងខូសេវ។

# គម្រោង អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USE-SDP2)

*“លើកកម្ពស់នវានុវត្តន៍នៅក្នុងគម្រោងរបស់ដៃគូអភិវឌ្ឍ”*

## ប្រវត្តិគម្រោង

| | |
|---|---|
| **ម្ចាស់ជំនួយ** | ក្រសួងអប់រំ យុវជន និងកីឡា-ធនាគារ ADB |
| **អ្នកទទួលផលផ្ទាល់** | វិទ្យាស្ថានជាតិអប់រំ/សាលាធនធានមធ្យមសិក្សាចំនួន៥០ |
| **ថវិកាឆ្នាំសិក្សា២០២៣** | ៦២១.៥២០.០០៥,១៨រៀល |
| **ខេត្តគោលដៅ** | ២៥ខេត្តទូទាំងប្រទេស |
| **សាលាមធ្យមសិក្សាគោលដៅ** | ៥០សាលា |
| **កាលបរិច្ឆេទចាប់ផ្តើម** | ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ |
| **កាលបរិច្ឆេទបញ្ចប់** | ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៣ |

## គោលបំណង

គោលបំណងចូលរួមរបស់អង្គការ ខេប នៅក្នុងគម្រោងUSE-SDP2 នេះគឺដើម្បីគាំទ្រក្រ.អយក ក្នុងការលើកកម្ពស់នវានុវត្តន៍ផ្នែកអប់រំនៅក្នុងគម្រោងរបស់ដៃគូអភិវឌ្ឍន៍នៅថ្នាក់ជាតិ ដែលជាផ្នែកនៃការផ្តល់ហិរញ្ញប្បទានដោយស្ថានប័នផ្តល់ជំនួយធំៗ ដូចជា ធនាគារអភិវឌ្ឍអន្តរជាតិ។ ក្រ.អយក មានចំណាប់អារម្មណ៍ជាពិសេសក្នុងការរុញច្រាននវានុវត្តន៍អប់រំ និងគោលគំនិតដូចជាកម្មវិធីសាលារៀនជំនាន់ថ្មីចូលក្នុងគម្រោងថ្នាក់ជាតិធំៗ ដូចជាគម្រោង USE-SDP2។

## បច្ចុប្បន្នភាពគម្រោង

គម្រោងអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សាទុតិយភូមិដំណាក់កាលទី២ គឺជាគម្រោងថ្នាក់ជាតិដ៏ធំមួយដែលផ្តោតលើការកែលម្អផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងផ្នែកគុណភាពនៅវិទ្យាស្ថានជាតិអប់រំ **(សមាសភាព ក)** និងវិទ្យាល័យធនធាន **(សមាសភាព ខ)** នៅក្នុងទីតាំងទាំង៥០។ កិច្ចសន្យារយៈពេល៣ឆ្នាំរវាងអង្គការ ខេប និងក្រសួងអប់រំ យុវជន និងកីឡា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សម្រាប់ការអនុវត្តគម្រោងបានបញ្ចប់នៅខែកញ្ញា ឆ្នាំ២០២៣ ប៉ុន្តែបានបន្តនៅពេលបច្ចុប្បន្នស្ថិតនៅក្រោមការត្រួតពិនិត្យដោយ ADB និងជំនួយការបច្ចេកទេសរបស់អង្គការ ខេប នឹងត្រូវគេរំពឹងថានឹងបញ្ចប់នៅចុងឆ្នាំ២០២៤។ ជាផ្នែកមួយនៃការរៀបចំគម្រោង ADB និង ក្រ.អយក បានព្រមព្រៀងគ្នាបញ្ចូលដៃគូមិនមែនរដ្ឋាភិបាលពីរស្ថាប័នជាការធ្វើលទ្ធកម្មឯកប្រភព ដើម្បីអនុញ្ញាតឱ្យគម្រោងអាចប្រើប្រាស់បាននូវឧត្តមានុវត្តន៍របស់គម្រោងផ្សេងៗ ដូចជាកម្មវិធីសាលារៀនជំនាន់ថ្មី។ ការធ្វើលទ្ធកម្មឯកប្រភពគឺមិនមែនជារឿងធម្មតានៅក្នុងកិច្ចសន្យារបស់ ADB នោះទេ ហេតុដូច្នោះហើយ រចនាសម្ព័ន្ធគម្រោងគឺមានលក្ខណៈឯកត្តភាពសម្រាប់គម្រោងដែលផ្តល់ហិរញ្ញប្បទានដោយ ADB។ តួនាទីភារកិច្ចរបស់អង្គការ ខេប នៅក្នុងគម្រោងនេះសំខាន់គឺផ្តល់ជំនួយបច្ចេកទេសរយៈពេលជាង៣ឆ្នាំជាមួយនឹងថវិកាសរុប ៤៦៥.000ដុល្លារអាមេរិក។

នៅក្រោមកិច្ចសន្យារបស់អង្គការ ខេប និងក្រ.អយក-ADB អង្គការខេបត្រូវបានស្នើឱ្យទទួលខុសត្រូវលើលទ្ធផលសមិទ្ធិកម្មចំនួន១៥ ដែលលទ្ធផលទាំងនេះដើម្បីគាំទ្រសាលាធនធាន និងលទ្ធផលសមិទ្ធិកម្ម៧គាំទ្រវិទ្យាស្ថានជាតិអប់រំ (NIE) ឬលទ្ធផលសមិទ្ធិកម្មចំនួន២២ ប្រសិនបើសរុបទាំងអស់ (សូមមើលតារាងខាងក្រោម)។ លទ្ធផលទាំងនេះត្រូវបានបញ្ចប់នៅពេលបញ្ចប់កិច្ចសន្យាការងារនៅក្នុងខែកញ្ញា ឆ្នាំ២០២៣។

## រូបភាពសកម្មភាព







*← **ការអភិវឌ្ឍការបោះពុម្ពដោយទីប្រឹក្សាខេប៖** ទីប្រឹក្សាខេបបានអភិវឌ្ឍឯកសារបណ្តុះបណ្តាលជាច្រើន ឯកសារក្របខណ្ឌកម្មវិធីសិក្សារបស់ NIE និងធ្វើរបាយការណ៍កំឡុងពេល៣ឆ្នាំនៃការងារផ្តល់ការពិគ្រោះយោបល់នេះ។ ឯកសារទាំងអស់ត្រូវបានទទួលយកដោយក្រ.អយក និងបានបោះពុម្ពដោយដាក់ឡូហ្គូក្រសួង។*






***ការរៀបចំការអប់រំបែបថ្មី៖*** *ដោយប្រើប្រាស់ការរៀបចំការអប់រំដែលអភិវឌ្ឍឡើងដោយ NGS អង្គការខេបបានធ្វើឱ្យមានឥទ្ធិពលដ៏សំខាន់ទៅលើការរៀបចំបណ្ណាល័យ និងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រថ្មីៗនៅក្នុងសាលាធនធាន។*

## ការងារសំខាន់ៗ

| ការកែលម្អវិទ្យាស្ថានជាតិអប់រំ (សមាសភាព ក) | កែលម្អសាលាធនធាន (សមាសភាព ខ) | |
|---|---|---|
| ១. ផ្តល់ការគាំទ្របច្ចេកទេសដល់បុគ្គលិក NIE ក្នុងការអនុវត្តកម្មវិធីសិក្សាដែលមានស្រាប់សម្រាប់ថ្នាក់បរិញ្ញាបត្រ+១ និងបរិញ្ញាបត្រ+២ ជាមួយខ្លឹមសារដែលពាក់ព័ន្ធព្រមទាំងផ្តល់អនុសាសន៍លើការអភិវឌ្ឍកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកអប់រំ (NIE-D1)។<br>២. *ការបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនថ្មី* ((ឧ. ការសិក្សាបែបស្ថាបនានិយម ការសិក្សាបែបចម្រុះ) ដែលនឹងជាប់ពាក់ព័ន្ធទៅនឹង D1 (NIE) ខាងលើ។ (NIE-D2)<br>៣. ការបញ្ចូល*គោលការណ៍នៃការវាយតម្លៃសិស្ស និងគ្រូ*នៅក្នុងកម្មវិធីសិក្សារបស់ NIE (NIE-D3)។<br>៤. គាំទ្រការដាក់បណ្ណាល័យថ្មីនៅ NIE (NIE-D4)<br>៥. គាំទ្រការរៀបចំឯកសារ*សហគមន៍សិក្សាវិជ្ជាជីវៈគ្រូនៅ* NIE. (NIE-D5)<br>៦. កែលម្អសមត្ថភាពរបស់វិទ្យាស្ថានជាតិអប់រំ ដើម្បីធ្វើ*ការស្រាវជ្រាវវិជ្ជាជីវៈ*។ (NIE D6)<br>៧. ការបង្កើត*ថ្នាក់រៀនឆ្លាតវៃ*នៅសាលាបឋមសិក្សាអនុវត្តនៃវិទ្យាស្ថានជាតិអប់រំ។ (NIE-D7) | ១. អភិវឌ្ឍ*ក្របខណ្ឌរៀបចំការអប់រំថ្មី*សម្រាប់ថ្នាក់រៀន (SRS-D1)<br>២. អភិវឌ្ឍ*ឯកសារបណ្តុះបណ្តាលបណ្ណាល័យទំនើប* (SRS-D2)<br>៣. អភិវឌ្ឍ*ឯកសារការសិក្សាចល័ត* សម្រាប់បណ្ណាល័យ (SRS-D3)<br>៤. អភិវឌ្ឍ*ឯកសារមគ្គុទេសន៍ប្រឹក្សាអាជីព* (SRS-D4)<br>៥. អភិវឌ្ឍ*ក្របខណ្ឌថ្នាក់រៀនបំណិនជីវិតពហុបំណង* (SRS-D5)<br>៦. អភិវឌ្ឍ*គោលការណ៍ណែនាំប្រតិបត្តិសម្រាប់ថ្នាក់រៀនបំណិនជីវិតពហុបំណង* (SRS-D6)<br>៧. អភវិឌ្ឍ*ឯកសារការសិក្សាបែបស្ថាបនានិយម និងការគិតបែបគណនា* (SRS-D7)<br>៨. អភិវឌ្ឍ*របាយការណ៍វាយតម្លៃ* និងអនុសាសន៍សម្រាប់ផ្ញើជូន DIT ដើម្បីកែលម្អគេហទំព័រ ក្រ.អយក និងគោលនយោបាយបោះពុម្ព (SRS-D8)។ | ៩. អភិវឌ្ឍ*ឯកសារក្លឹបសិក្សាតាមមុខវិជ្ជា* យ៉ាងតិច៨ប្រធានបទ។ (SRS-D9)<br>១០.អភិវឌ្ឍ*ក្របខណ្ឌប្រឹក្សាគរុកោសល្យ* នៅតាមសាលារៀនដែលធ្វើសុខដុមនីយកម្មជាមួយនឹងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (TPAP)។ (SRS-D10)<br>១១.ផ្តល់*របាយការណ៍តាមត្រីមាស* ដល់ ក្រ.អយក ទាក់ទិននឹងការតាមដាន និងវាយតម្លៃ (SRS-D11)<br>១២.សហការជាមួយ DIT សាកល្បងការណែនាំការវាយតម្លៃតាមកុំព្យូទ័រផ្អែកលើឯកសារដែលបានរៀបចំនៃការធ្វើអនុសាសន៍ និងគោលការណ៍ណែនាំ។ (SRS-D12)<br>១៣.អភិវឌ្ឍ*ឯកសារប្រតិបត្តិការគ្រប់គ្រងតាមសាលារៀន* (SRS-D13)<br>១៤.ជួលប្រធានដឹកនាំក្រុមដែលនឹងធានាការសម្របសម្រួលផ្ទៃក្នុង។ (SRS-D14)<br>១៥.អនុវត្ត*ការវាយតម្លៃទូលំទូលាយ*នៃសាលាធនធាន (SRS-D15) |

# គម្រោង ពង្រឹងគុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា ( EQUAL )

*"កុមារទាំងអស់ ជាពិសេសកុមារក្រៅសាលា និងកុមារជនជាតិដើមភាគតិចទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាបន្ន"*

## ប្រវត្តិគម្រោង

| | |
|---|---|
| **ម្ចាស់ជំនួយ** | ភ្លែនអន្តរជាតិកម្ពុជា |
| **អ្នកទទួលផលផ្ទាល់** | កុមារ ៤ ៥៥១ (ស្រី ២ ១៦៨នាក់) |
| **ថវិកាឆ្នាំសិក្សា២០២៣** | ៥៤៥.៦៣៥.៤២៣,១៦រៀល |
| **តម្លៃឯកតាក្នុងសិស្សម្នាក់** | ១១៩.៨៩៣,៥២រៀល |
| **ខេត្តគោលដៅ** | រតនគិរី |
| **ស្រុកគោលដៅ** | ២ (ស្រុកបរកែវ និងអណ្តូងមាស) |
| **សាលាបឋមសិក្សាគោលដៅ** | ១៣ |
| **សាលាអនុវិទ្យាល័យគោលដៅ** | ២ |
| **កាលបរិច្ឆេទចាប់ផ្តើម** | ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ |
| **កាលបរិច្ឆេទបញ្ចប់** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ |

## បច្ចុប្បន្នភាពគម្រោង

EQUAL គឺគម្រោងថ្មីមួយក្នុងអង្គការ ខេប ដែលបានចាប់ផ្តើមប្រតិបត្តិការតាំងពីឆ្នាំទៅមិញ។ គម្រោងនេះបានបញ្ចប់ការដំណើរការរយៈពេលពីរឆ្នាំហើយក្នុងសាលាគោលដៅចំនួន១៥ ក្នុងនោះមានអនុវិទ្យាល័យចំនួន២ក្នុងខេត្តរតនគិរី។ អន្តរាគមន៍របស់គម្រោង EQUAL ស្វែងរកការលើកកម្ពស់គុណភាពសិក្សា និងបង្កើនការចុះឈ្មោះចូលរៀនក្នុងចំណោមកុមារក្រៅសាលា (OOSC) ជាពិសេសកុមារមកពីក្រុមជនជាតិភាគតិច ដូចជា ជនជាតិគ្រឹង ទំពួន។ល។

## អន្តរាគមន៍សំខាន់ៗ

១. ប្រព័ន្ធរំឭកទុកជាមុន (EWS) ត្រូវបានរចនាឡើងដើម្បីតាមដានសិស្សដែលងាយរងគ្រោះបំផុតដើម្បីជៀសវាងការបោះបង់ការសិក្សា។
២. បានបង្កើត និងរៀបចំថ្នាក់បំប៉នបន្ថែមដើម្បីបង្កើនជំនាញរបស់កុមារក្នុងអាន និងគិតលេខ។
៣. សកម្មភាពប្រព័ន្ធឆ្លើយតបរហ័ស (RRS) ត្រូវបានសម្របសម្រួលដោយគ្រូបង្វឹកអក្ខរកម្មដែលមានមូលដ្ឋាននៅសាលា ដើម្បីលើកកម្ពស់ការអាននៅថ្នាក់ដំបូង។ RRS កំណត់អត្តសញ្ញាណអ្នកអានដែលជួបការលំបាក និងផ្តល់ការគាំទ្រផ្នែកដោះស្រាយ។
៤. ពន្លឿនកម្មវិធីសិក្សាដើម្បីគាំទ្រកុមារលើសអាយុ។
៥. កម្មវិធីបំណិនជីវិតដែលផ្តោតលើក្មេងស្រីជំទង់។
៦. បានបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀន។
៧. គាំទ្រព្រឹត្តិការណ៍ផ្សព្វផ្សាយសហគមន៍ដែលបង្កើនការយល់ដឹងពីភាគីពាក់ព័ន្ធអំពីសិទ្ធិរបស់កុមារក្នុងការអប់រំ។

## គោលបំណង

គុណភាព និងការចូលរួមផ្នែកអប់រំនៅកម្រិតអប់រំមូលដ្ឋានមានការកើនឡើងច្រើនក្នុងចំណោមក្រុមងាយរងគ្រោះ ដូចជា កុមារី ក្រុមជនជាតិដើមភាគតិច កុមារដែលមានពិការភាព និងកុមារក្រីក្រ។

**គោលបំណងជាក់លាក់៖** កុមារនៅក្រៅសាលា និងកុមារជនជាតិភាគតិចក្នុងខេត្តរតនគិរីមានឱកាសបំពេញសិទ្ធិក្នុងការអប់រំនៅបឋមសិក្សា និងបន្តទៅអនុវិទ្យាល័យដោយរលូន តាមរយៈការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងការផ្លាស់ប្តូរយេនឌ័រ។

## រូបភាពសកម្មភាព



*សកម្មភាពសិក្សាបំប៉នបន្ថែមនៅថ្នាក់រៀនជួយពង្រឹងប្រសិទ្ធភាពអំណាន។*



*ជ្រុងអំណានក្នុងថ្នាក់រៀនដើម្បីបណ្តុះទម្លាប់អានសៀវភៅ។*



*សិស្សានុសិស្សបានចូលរួមយុទ្ធនាការប្រមូលកុមារចូលរៀន ដើម្បីបង្កើនការចូលរៀន ជាពិសេសកុមារក្រៅសាលា។*

## ការងារ និងផលជះគម្រោង

១. គម្រោងបានបង្កើនចំនួនចំណុចដៅការចូលរៀននៃកុមាក្រៅសាលា។ ចំណុចដៅទាំងនោះគឺបានសម្រេចដោយអន្តរាគមន៍ចំនួនពី៖
- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រចំនួន១៥០នាក់ (ស្រី៨៥នាក់) ដែលកំណត់ដោយសហការជាមួយសហគមន៍មូលដ្ឋាន។ អ្នកទទួលអាហារូបករណ៍ក៏រួមមានកុមារជនជាតិដើមភាគតិច ១០៦នាក់ (៧១%) និងស្រី៧១នាក់។
- ខេបបានបង្កើតប្រព័ន្ធរំឭកទុកជាមុន ជាមួយនឹងអ្នកអភិវឌ្ឍន៍កម្មវិធីថ្នាក់ជាតិ។ តាមរយៈប្រព័ន្ធនេះ សាលាកំណត់ចំនួនសិស្សដែលប្រថុយនឹងកាបោះបង់។

២. នៅឆ្នាំ២០២៣ គម្រោងកំណត់បានកុមារដែលប្រថុយនឹងការបោះបង់ចំនួន១០១នាក់ (ស្រី៥៤នាក់) ក្នុងនោះរួមទាំងកុមារជនជាតិដើមភាគតិច៧៤នាក់ត្រូវជា ៧១%។
៣. គម្រោងនេះគ្រប់គ្រងការវាយតម្លៃការអានថ្នាក់ដំបូងជាទៀងទាត់ ដែលបង្ហាញពីការបង្កើនជំនាញក្នុងការអានអក្សរ និងការអានពាក្យ។
៤. សាលារៀនគោលដៅបឋមទាំងអស់ (១៣សាលា) បានធ្វើសកម្មភាពគូសផែនទីសាលារៀនដើម្បីកំណត់អត្តសញ្ញាណ កុមារក្រៅសាលា និងសិស្សដែលងាយរងគ្រោះផ្សេងទៀត។
៥. បណ្ណាល័យសតវត្សរ៍ទី២១ចំនួនពីរត្រូវបានបង្កើតឡើងនៅសាលាបឋមសិក្សាបរកែវ និងសាលាបឋមសិក្សាអណ្តូងមាស។ ទាំងនេះគឺជាគ្រឿងបរិក្ខារទំនើបៗដែលផ្តល់សេវាកម្ម m-learning ដើម្បីគាំទ្រដល់ការសិក្សាដោយខ្លួនឯងផងដែរ។
៦. សិស្សានុសិស្សសរុបចំនួន៧៧៨នាក់ (ស្រី៣៨៨នាក់) ពីថ្នាក់ទី១ ដល់ទី៦ ត្រូវបានចូលរួមនៅក្នុងថ្នាក់បំប៉នបន្ថែមដែលពង្រឹងភាសាខ្មែរ និងគណិតវិទ្យា។ ក្នុងចំណោមកុមារទាំងនោះ មាន ៥១៦នាក់ជាកុមារជនជាតិដើមភាគតិច និង២៧១នាក់ជាកុមារី។
៧. សាលាគោលដៅទាំង១៥បានរៀបចំបន្ទប់អនាម័យពេលមករដូវ ឬជ្រុងក្នុងសាលា និងផ្តល់សម្ភារអនាម័យដល់កុមារីអំឡុងពេលមករដូវ រួមទាំងការប្រើប្រាស់សំឡីចំនួន១៦៩២ដុំក្នុងឆ្នាំសិក្សាកន្លងទៅ។
៨. សកម្មភាពបណ្តុះបណ្តាលបំណិនជីវិតត្រូវបានផ្តល់ជូនសិស្សអនុវិទ្យាល័យចំនួន៨៨២នាក់ (ស្រី៤៩៧នាក់) នៅថ្នាក់ទី៧-៩។ កម្មវិធីនេះផ្តោតលើការលើកកម្ពស់ការយល់ដឹងអំពីយេនឌ័រជាមូលដ្ឋាន ជំនាញទន់ដូចជាការសម្រេចចិត្ត និងផែនការអាជីព។ ខេបផ្តល់នូវសម្ភារៈធនធានដែលត្រូវបានអភិវឌ្ឍយ៉ាងពិសេស ដើម្បីលើកកម្ពស់ការអនុវត្តការរៀនជំនាញជីវិត។
៩. នាយកសរុបចំនួន២២នាក់ (ស្រី៤នាក់) រួមទាំង DoEs បានទទួលការបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលា ដោយប្រើសម្ភារៈបណ្តុះបណ្តាលដែលបានស្រាវជ្រាវយ៉ាងល្អដែលត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីផ្សេងទៀត។
១០.គ្រូបង្រៀនចំនួន៦៦នាក់ (ស្រី៣៨នាក់) បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលដែលផ្តោតលើការបង្កើនជំនាញលើផ្នែកជាច្រើន រួមទាំងការលើកកម្ពស់ការអាននៅថ្នាក់ដំបូង ការអប់រំបំណិនជីវិត ការអប់រំសិស្ស ការពន្លឿនការសិក្សា និងការប្រើប្រាស់ប្រព័ន្ធរំឭកទុកជាមុនរបស់សាលា។

# កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំដល់មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់ភាពជាអ្នកដឹកនាំ និងសមភាពយេនឌ័រ (MoEYS LPD)

*"ភាពជាអ្នកដឹកនាំដែលមានប្រសិទ្ធភាពគឺពិតជាសំខាន់ក្នុងការកសាងសមត្ថភាពដល់ថ្នាក់គ្រប់គ្រងក្រសួងជាស្ត្រី និងបុរសនៅថ្ងៃអនាគត"*

## ប្រវត្តិគម្រោង

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការមូលនិធិអាស៊ី/អង្គការយូនីសេហ្វ – CDPF |
| **អ្នកទទួលផលផ្ទាល់** | បុគ្គលិកគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា កម្រិតថ្នាក់ជាតិ និងក្រោមជាតិ |
| **ថវិកាឆ្នាំសិក្សា២០២៣** | ២៣០.៩៦៣.៧០១រៀល |
| **ខេត្តគោលដៅ** | ភ្នំពេញ សៀមរាប កោះកុង ព្រះសីហនុ និងតាកែវ |
| **ស្រុកគោលដៅ** | ទូទាំងប្រទេស |
| **កាលបរិច្ឆេទចាប់ផ្តើម** | ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ |
| **កាលបរិច្ឆេទបញ្ចប់** | ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ |

## វត្ថុបំណង

- **សមាសភាគទី១៖** ការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈដល់តម្រូវការថ្នាក់គ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា (ប្រុសនិងស្រី) នៅថ្នាក់កណ្តាល។ សមាសភាគនេះនឹងដឹកនាំលើកកម្ពស់សមត្ថភាពក្នុងចំណោមអ្នកដឹកនាំកម្រិតថ្នាក់កណ្តាលរបស់ក្រសួងអប់រំ យុវជននិងកីឡា (បុគ្គលិកមានចំនួនរហូតដល់៧៥០នាក់) ផ្តល់ការលើកកម្ពស់សមត្ថភាពឱ្យត្រូវតម្រូវការនៅក្នុងមុខតំណែងវិជ្ជាជីវៈរបស់ពួកគេ។
- **សមាសភាគទី២៖** ការផ្តល់ការអភិវឌ្ឍសមត្ថភាពជាក់លាក់ ដើម្បីបំពេញសេចក្តីត្រូវការរបស់ស្ត្រីក្នុងតួនាទីដឹកនាំនៅការិយាល័យខេត្តគោលដៅ។ យើងរំពឹងទុកថា មេដឹកនាំជាស្ត្រីគោលដៅប្រមាណ៤០នាក់នៅកម្រិតថ្នាក់ក្រោមជាតិរបស់ក្រសួងអប់រំ យុវជន និងកីឡា នឹងបង្ហាញពីការពង្រឹងសមត្ថភាពបច្ចេកទេស និងវិជ្ជាជីវៈ (ដោយបានប្រតិបត្តិសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈស្របតាមតម្រូវការ)។

## បច្ចុប្បន្នភាពគម្រោង

គម្រោងអភិវឌ្ឍន៍វិជ្ជាជីវៈភាពជាអ្នកដឹកនាំបានយកទម្រង់កិច្ចសន្យារវាងទីប្រឹក្សា និងអង្គការ ខេប និងមូលនិធិអាស៊ី។ ក្រោមជំនួយហិរញ្ញប្បទានពីអង្គការយូនីសេហ្វ កម្មវិធីនេះបានស្វែងរកការកសាងជំនាញភាពជាអ្នកដឹកនាំក្នុងចំណោមបុគ្គលិកជាន់ខ្ពស់របស់ក្រសួង ជាពិសេសអ្នកដែលជាស្ត្រី។ គម្រោងនេះត្រូវបានបញ្ចប់ដោយជោគជ័យក្នុងខែមិថុនា ឆ្នាំ២០២៣ រួមទាំងមានជាសិក្ខាសាលាបណ្តុះបណ្តាលជាច្រើន និងការបង្កើតសៀវភៅបណ្តុះបណ្តាលសំខាន់ៗ (សូមមើលរូបភាពនៅខាងស្តាំ)។ ក្នុងអំឡុងពេលអនុវត្តគម្រោង មានសកម្មភាពត្រូវបានបញ្ចប់ដូចខាងក្រោម៖

- ជ្រើសរើស និងបណ្តុះបណ្តាលគ្រូពេញសមត្ថភាពចំនួន៦នាក់ (ជាន់ខ្ពស់៣នាក់បន្ថែមទៀត) ដើម្បីបង្កើតកម្មវិធីបណ្តុះបណ្តាលអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំនាពេលអនាគតសម្រាប់កម្រិត ១, ២ និង៣។
- បានបញ្ចប់សៀវភៅស្តីពីការអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំ ដែលស្មើនឹងក្រេឌីត ១CPD នាពេលអនាគត (CPD= ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ)។
- បានដាក់បញ្ចូល និងធ្វើការសាកល្បងសៀវភៅស្តីពីការអភិវឌ្ឍភាពជាអ្នកដឹកនាំនៅក្នុងកម្មវិធី u-learning/ទម្រង់ Moodle របស់ក្រសួងអប់រំ យុវជន និងកីឡា។
- បានបញ្ចប់ដំណាក់កាលទី១ នៃវគ្គបណ្តុះបណ្តាលនេះលើម៉ូឌុលអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំសម្រាប់សិក្ខាកាមចំនួន២២នាក់ (ស្ត្រី៨នាក់) នៅជួរថ្នាក់ដឹកនាំក្រសួងកម្រិត១ សិក្ខាកាមចំនួន៥០នាក់ (ស្រី២៣នាក់) នៅជួរថ្នាក់គ្រប់គ្រងក្រសួងកម្រិត៣ និងសិក្ខាកាមចំនួន២៥នាក់ (ស្រី២៤នាក់) គឺជាបុគ្គលិកមកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ក្នុងមុខតំណែងជាអ្នកដឹកនាំ។

## រូបភាពសកម្មភាព




*រូបភាពកម្របឯកសារបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍភាពជាអ្នកដឹកនាំ។*




*ឯកឧត្តម ណាត ប៊ុនរឿន រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលជាមួយមន្ត្រីជាន់ខ្ពស់ក្រសួងក្នុងខេត្តកំពង់ចាម សម្រាប់ការដាក់ឱ្យប្រើប្រាស់សៀវភៅបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ដែលត្រូវបានបង្កើតឡើងជាផ្នែកមួយនៃការអនុវត្តគម្រោង។ វគ្គបណ្តុះបណ្តាលនេះទទួលបានការយកចិត្តទុកដាក់ពីបុគ្គលិកជាន់ខ្ពស់ប្រកបដោយភាពវិជ្ជមាន ហើយនឹងបង្កើតជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់កសាងសមត្ថភាពនាពេលអនាគត។*

## ផលជះគម្រោង

ក្នុងអំឡុងឆ្នាំ២០២៣ ខេបបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការមូលនិធិអាស៊ីដើម្បីបញ្ចប់ និងធ្វើបច្ចុប្បន្នភាពកម្មវិធីបណ្តុះបណ្តាល ដោយប្រើប្រាស់សៀវភៅបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍភាពជាអ្នកដឹកនាំមូលដ្ឋានទម្រង់សិក្សា U-learning និងការអភិវឌ្ឍកម្មវិធីសិក្សាបែបជ្រើសរើស និងអនុម័តវិញ្ញាបនបត្រ។ គម្រោងនេះក៏បានរៀបចំកម្មវិធីបិទវគ្គស្តីពីភាពជាអ្នកដឹកនាំរបស់ក្រ.អយក និងអង្គការយូនីសេហ្វ (ដំណាក់កាលទី១)។

ខេបបានដឹកនាំការបើកវគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំជុំទី១នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ វគ្គបណ្តុះបណ្តាលនេះមានរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ដោយមានសិក្ខាកាមសរុបចំនួន២៣នាក់ (ស្រី៨នាក់) ដែលជាបុគ្គលិកជាន់ខ្ពស់របស់ក្រសួងអប់រំ យុវជន និងកីឡា (ពោលគឺបុគ្គលិកក្រសួងអប់រំកម្រិតទី១ និងកម្រិតទី២)។ អ្នកចូលរួមទាំងអស់បានបញ្ចប់វគ្គបណ្តុះបណ្តាល។ វគ្គបណ្តុះបណ្តាលលើកទី១នេះបានបន្តជុំទី២ នៅរាជធានីភ្នំពេញ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន៥០នាក់ (ស្រី២៣នាក់) មកពីគណៈគ្រប់គ្រងក្រសួងអប់រំ យុវជន និងកីឡា។ សិក្ខាសាលានេះបានធ្វើឡើងនៅចន្លោះថ្ងៃទី២៧ ខែមីនា ដល់ថ្ងៃទី២ ខែឧសភា ដោយប្រើទម្រង់សិក្សាបញ្ចូលគ្នា (សិក្សាផ្ទាល់ និងតាម U-learning ដោយឯករាជ្យ និងនៅកន្លែងធ្វើការងារ)។

ក្នុងអំឡុងពេលដាក់ឱ្យដំណើរការដំណាក់កាលទី១នៅថ្នាក់ជាតិ ក្រុមការងារគម្រោងបានធ្វើការកែលម្អ និងបញ្ចប់ទម្រង់សិក្សា U-learning ផ្អែកលើមតិរបស់សិក្ខាកាម ដោយសហការជាមួយនាយកដ្ឋាន IT របស់ក្រសួងអប់រំ។ ក្នុងចំណោមសិក្ខាកាមចំនួន៥០នាក់ មាន៣៨នាក់ (ស្ត្រី១៨នាក់) ត្រូវបានអនុម័តឱ្យបន្តវគ្គសិក្សាទាំងមូល ហើយបច្ចុប្បន្ននេះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានវិញ្ញាបនបត្របញ្ចប់ការសិក្សា និងក្រេឌីត ១CPD។ សិក្ខាកាម១២នាក់ផ្សេងទៀតក៏បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាលដែរ ប៉ុន្តែមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យដើម្បីប្រឡងជាប់ និងទទួលបានការវាយតម្លៃគុណភាពចុងក្រោយ។ ចំនួន ៨៩% នៃសិក្ខាកាមបានវាយតម្លៃខ្លឹមសារការបណ្តុះបណ្តាលជាវិជ្ជមាន ហើយ ៨៦% គិតថា គោលបំណងវគ្គបណ្តុះបណ្តាលសម្រេចបានទាំងស្រុង។ នៅថ្នាក់ក្រោមជាតិ វគ្គបណ្តុះបណ្តាលផ្ទាល់មុខគ្នាបានចាប់ផ្តើមនៅថ្ងៃទី៣០ ខែមីនា និងមានរយៈពេលរហូតដល់ថ្ងៃទី៩ ខែឧសភា ដោយមានសិក្ខាកាមចូលរួមសរុប២៥នាក់ (ស្រី២៤នាក់)។ សិក្ខាកាមទាំងអស់បានបញ្ចប់វគ្គសិក្សាដោយជោគជ័យបន្ទាប់ពីការបញ្ចប់ការងារគម្រោងលើការប្រឹក្សានៅកន្លែងធ្វើការរបស់ពួកគេ។ សម្ភារៈបណ្តុះបណ្តាលទាំងអស់សម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានកែសម្រួលដោយផ្អែកលើមតិរបស់សិក្ខាកាមក្នុងអំឡុងពេលចាប់ផ្តើមដំណាក់កាលទី១ ហើយឥឡូវនេះត្រៀមខ្លួនរួចជាស្រេចដើម្បីប្រើប្រាស់សម្រាប់ការបណ្តុះបណ្តាលនាពេលអនាគតរបស់ក្រសួងអប់រំ យុវជន និងកីឡា។

# គម្រោង អប់រំបំណិនជីវិតមូលដ្ឋាន (LLSE)

*"គាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រីកការអប់រំបំណិនជីវិតតាមមូលដ្ឋាន"*

## ប្រវត្តិគម្រោង

| | |
|---|---|
| **ម្ចាស់ជំនួយ** | អង្គការយូនីសេហ្វ |
| **ថវិកាឆ្នាំសិក្សា២០២៣** | ២៧៦.៣០២.៦២៧,១០រៀល |
| **ខេត្តគោលដៅ** | ៨ |
| **ស្រុកគោលដៅ** | ២២ |
| **បឋមសិក្សាគោលដៅ** | ៣៤ |
| **មធ្យមសិក្សាគោលដៅ** | ២៨ |
| **កាលបរិច្ឆេទចាប់ផ្តើម** | ខែសីហា ឆ្នាំ២០២៣ |
| **កាលបរិច្ឆេទបញ្ចប់** | ខែកុម្ភៈ ឆ្នាំ២០២៤ |

## បច្ចុប្បន្នភាពគម្រោង

អង្គការយូនីសេហ្វគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការអនុវត្តកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន (LLSE) ដើម្បីអភិវឌ្ឍជំនាញទន់ដូចមានចែងក្នុងគន្លឹះសាលាសម្រាប់ថ្នាក់ទី៤-៦ (បឋមសិក្សា) និងសម្រាប់ថ្នាក់ទី៧-៩ (អនុវិទ្យាល័យ)។ LLSE ផ្តល់ឱកាសសម្រាប់សិស្សានុសិស្ស ដើម្បីអនុវត្តនូវអ្វីដែលពួកគេបានរៀនពីគ្រប់មុខវិជ្ជា និងប្រភពព័ត៌មានចម្រុះផ្សេងៗទៀត (រួមទាំងការរៀនតាមអ៊ីនធឺណិត) ទៅនឹងការអនុវត្តជីវិតប្រចាំថ្ងៃ និងការចូលរួមរបស់ពួកគេតាមរយៈដំណើរការសិក្សា៦ជំហានដោយផ្អែកលើបញ្ហាដែលមានក្នុងមូលដ្ឋាន។

នៅខែសីហា ឆ្នាំ២០២៣ អង្គការ ខេប បានចុះកិច្ចសន្យាជាមួយអង្គការយូនីសេហ្វធ្វើជាភ្នាក់ងារប្រឹក្សាគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការសម្របសម្រួលកម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋានដោយមានការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល/ម្ចាស់ជំនួយផ្សេងៗ ហើយដូច្នេះត្រូវសម្របសម្រួលកម្មវិធី LLSE ទូទាំងប្រទេស ដែលដឹកនាំដោយក្រុមការងារក្រសួងអប់រំ។ ស្ថិតជាផ្នែកមួយនៃជំនួយបច្ចេកទេស (TA) អង្គការ ខេប ទទួលខុសត្រូវលើកិច្ចការជាច្រើនក្រោមការចាត់តាំងទាំងនេះ រួមមាន៖ (១) ការអភិវឌ្ឍ និងការគ្រប់គ្រងការវាយតម្លៃបំណិនជីវិតមូលដ្ឋាន ដែលនឹងប្រៀបធៀបសាលារៀន៣ប្រភេទ (សាលា LLSE សាលារៀនជំនាន់ថ្មី និងសាលាអនុវត្ត។ (២) ការអភិវឌ្ឍសៀវភៅណែនាំបណ្តុះបណ្តាលបំណិនជីវិតដែលផ្តោតលើការរៀនផ្អែកលើបញ្ហា។ (៣) ការអភិវឌ្ឍឯកសារយោងដែលសង្ខេបធនធានមានប្រយោជន៍សម្រាប់ការបង្រៀនបំណិនជីវិត។ និង (៤) ការអភិវឌ្ឍឯកសារផែនទីបង្ហាញផ្លូវដែលជួយដល់ក្រសួងអប់រំ និងអង្គការយូនីសេហ្វ សម្រាប់រៀបចំផែនការពង្រីកសកម្មភាព LLSE ទៅកាន់សាលារៀនបន្ថែមទៀតនៅក្នុងខេត្តជាច្រើនទៀត។

## សកម្មភាពសំខាន់ៗ

### *ក្រសួងអប់រំ យុវជន និងកីឡា*

- ធានាឱ្យមានការសម្របសម្រួលដោយរលូនរវាងនាយកដ្ឋានពាក់ព័ន្ធទាំងអស់ និងអ្នកពាក់ព័ន្ធក្នុងការបង្កើនការបណ្តុះបណ្តាល និងការអនុវត្ត LLSE នៅទូទាំងប្រទេស។
- រចនាសៀវភៅណែនាំបណ្តុះបណ្តាល ដើម្បីពង្រឹងការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀនដោយយោងទៅលើវិធីសាស្រ្តបង្រៀន និងការអភិវឌ្ឍជំនាញសតវត្សរ៍ទី២១។
- ពង្រឹងអភិបាលកិច្ចល្អនៅក្នុងសាលារៀន ដែលជាលក្ខខណ្ឌដំបូងសម្រាប់ការអនុវត្ត LLSE ប្រកបដោយប្រសិទ្ធភាព។
- គាំទ្រគ្រូបង្រៀនឱ្យក្លាយជា **"គ្រូបង្រៀនបំណិនជីវិត"** ដែលលើកកម្ពស់ឱកាសសម្រាប់សិស្សក្នុងការអនុវត្តការសិក្សារបស់ពួកគេពីគ្រប់មុខវិជ្ជានៅក្នុងជីវិតប្រចាំថ្ងៃ។
- បង្កើនប្រសិទ្ធភាពការប្រើប្រាស់ធនធាន LLSE ដែលមានស្រាប់ និងធ្វើឱ្យធនធានទាំងនោះមានសម្រាប់សាលារៀន (ឧ. តាមរយៈទម្រង់សិក្សាតាមប្រព័ន្ធអេឡិចត្រូនិក DIT)
- កំណត់យន្តការដើម្បីគាំទ្រគ្រូបន្ទាប់ពីការបណ្តុះបណ្តាល(ឧ.ការណែនាំតាមសាលា) ដោយ ប្រើរចនាសម្ព័ន្ធរដ្ឋាភិបាលដែលមានស្រាប់ក្នុងការបញ្ជូនការគាំទ្របែបនេះ។
- រួមបញ្ចូលកត្តាដែលទាក់ទងនឹង ICT នៅក្នុងសៀវភៅណែនាំបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ការអប់រំឌីជីថលនៅក្នុងសាលារៀន និងការរួមបញ្ចូល ICT ក្នុងការបង្រៀន និងរៀនរបស់ LLSE ។
- ពិនិត្យឡើងវិញនូវការអនុវត្តការវាយតម្លៃដែលមានស្រាប់លើការអភិវឌ្ឍជំនាញទន់ (ឧ.ការវាយតម្លៃទម្រង់) និងពិចារណាណែនាំការវាយតម្លៃសិស្សដោយផ្អែកលើសមត្ថភាព។
- ជួយរួមបញ្ចូលលក្ខណៈសំខាន់ៗការងារគម្រោងក្នុងដំណើរការ LLSE ៦ ជំហាន។

### *សាលារៀន*

- គាំទ្រការអនុវត្ត LLSEប្រកបដោយប្រសិទ្ធភាព ដែលភ្ជាប់នឹងអភិបាលកិច្ចល្អ និងភាពជាអ្នកដឹកនាំដ៏រឹងមាំ។
- ពង្រឹងការយល់ដឹងរបស់គ្រូអំពីជំនាញទន់។
- កំណត់ធនធានបន្ថែមដើម្បីគាំទ្រដល់ការអនុវត្ត LLSE សម្រាប់ប្រធានបទមួយចំនួន (ឧ. ការប្រែប្រួលអាកាសធាតុ)។
- កំណត់អត្តសញ្ញាណធនធានមូលដ្ឋានដែលសាលាអាចខ្វះសម្រាប់ការអនុវត្ត LLSE (ឧ. អេក្រង់ LCD កុំព្យូទ័រមិនមាន)។
- ស្ទាបស្ទង់ពីកង្វះគ្រូបង្រៀនដែលជាឧបសគ្គអនុវត្ត LLSE (ជាពិសេសនៅកម្រិតមធ្យមសិក្សាបឋមភូមិ)។
- គូសបញ្ជាក់ពីសារៈសំខាន់នៃការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្ត LLSE រួមទាំងសិស្ស និងសហគមន៍។
- គូសបញ្ជាក់ពីរបៀបដែលសាលារៀនអាចលើកកម្ពស់ការផ្លាស់ប្តូរអាកប្បកិរិយានៅក្នុងសហគមន៍ តាមរយៈការអនុវត្ត LLSE ។
- គូសបញ្ជាក់ថា LLSE ធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងសាលារៀន និងសហគមន៍។
- តស៊ូមតិជាមួយអាជ្ញាធរមូលដ្ឋាន (ឃុំ ស្រុក និងខេត្ត) ដើម្បីចាត់វិធានការបន្ថែមទៀតដើម្បីគាំទ្រដល់ការអនុវត្តបំណិនជីវិតតាមមូលដ្ឋាន និងដោះស្រាយបញ្ហាប្រឈមនាពេលបច្ចុប្បន្ន។

## វត្ថុបំណង

គោលបំណងការងារនេះដើម្បីគាំទ្រដល់ក្រុមការងារបំណិនជីវិតរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រីកការអនុវត្ត LLSE ជាបណ្តើរៗនៅតាមស្រុក និងខេត្តថ្មីៗ។ ការចាត់តាំងនឹងត្រូវបានរៀបចំឡើងជុំវិញកិច្ចការស្នូលចំនួន៣ដូចខាងក្រោម៖

- ធ្វើការវាយតម្លៃដែលនឹងបង្កើតកម្រិតមូលដ្ឋាននៃកម្រិតជំនាញទន់របស់សិស្សក្នុងពេលជាមួយគ្នាកំណត់បញ្ហាប្រឈមបច្ចុប្បន្នក្នុងការអនុវត្ត ព្រមទាំងកត្តាដែលជួយសម្រួលដល់ការអនុវត្តប្រកបដោយជោគជ័យនៅកម្រិតសាលា។ ការវាយតម្លៃនឹងរួមបញ្ចូលការកំណត់អត្តសញ្ញាណក្រុមប្រៀបធៀបជាច្រើន រួមទាំងសាលាអនុវត្ត (ទាំងបច្ចុប្បន្ន និងដែលបានស្នើឡើងថ្មី) ប្រៀបធៀប និងសាលាជំនាន់ថ្មី (NGS) ជាគំរូបន្ថែមសម្រាប់ការប្រៀបធៀប។
- បង្កើតសៀវភៅបណ្តុះបណ្តាលស្តីពីការអនុវត្ត LLSE ដែលរួមបញ្ចូលលទ្ធផលវាយតម្លៃ និងការផ្តល់យោបល់ពីក្រុមការងាររបស់ក្រសួងអប់រំ យុវជន និងកីឡា រួមនឹងការរៀបចំសម្ភារៈធនធានបន្ថែមលើប្រធានបទអាទិភាព (ឧ. ការប្រែប្រួលអាកាសធាតុ សមភាពយេនឌ័រ សុខភាពផ្លូវចិត្ត។ល។)។
- បង្កើតគោលការណ៍ណែនាំសម្រាប់ការពង្រីកកម្មវិធី ស្នើវិធីសាស្រ្តសមស្របដោយប្រើប្រាស់ការអនុវត្តទូទាំងស្រុក និងខេត្ត រួមនឹងការចង្អុលបង្ហាញលើការចំណាយ (ពិចារណាលើការបណ្តុះបណ្តាលនាយកសាលាម្នាក់ និងគ្រូពីរនាក់ពីសាលានីមួយៗ) ដែលណែនាំដោយអង្គការយូនីសេហ្វ រួមទាំងព័ត៌មានលម្អិតអំពីនីតិវិធីតាមដាន និងការវាយតម្លៃដែលត្រូវអនុវត្ត។

## រូបភាពសកម្មភាព



*ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ លើការស្នើសុំបង្កើតសៀវភៅបណ្តុះបណ្តាល។*



*សិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ និងការបង្ហាញសៀវភៅបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធ។*

# កម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន (ADLP)

*"ធ្វើការកាត់បន្ថយគម្លាតរវាងអ្នកប្រើប្រាស់ឌីជីថលនៅប្រទេសកម្ពុជា"*

## ប្រវត្តិគម្រោង

| | |
|---|---|
| **ម្ចាស់ជំនួយ** | មូលនិធិអាស៊ាន |
| **អ្នកទទួលផលផ្ទាល់** | ៧ ២៥៤នាក់ (ស្រី៤១៣២នាក់) |
| **ថវិកាឆ្នាំសិក្សា២០២៣** | ៦០.៤៧១.៧២០រៀល |
| **តម្លៃឯកតាក្នុងសិស្សម្នាក់** | ៨.៣៣៦,៣៣រៀល |
| **ខេត្តគោលដៅ** | ១៥ |
| **ស្រុកគោលដៅ** | ៣០ |
| **សាលាបឋមសិក្សាគោលដៅ** | ១៥ |
| **សាលាមធ្យមសិក្សាគោលដៅ** | ២៥ |
| **កាលបរិច្ឆេទចាប់ផ្តើម** | ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២២ |
| **កាលបរិច្ឆេទបញ្ចប់** | ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ |

## គោលបំណង

កម្មវិធី ADLP ត្រូវបានអភិវឌ្ឍឡើងដោយមូលនិធិអាស៊ានក្រោមជំនួយហិរញ្ញប្បទានពីក្រុមហ៊ុន Google.org។ នេះគឺជាកម្មវិធីថ្នាក់តំបន់ដែលកំពុងត្រូវបានអនុវត្តដោយប្រទេសជាសមាជិកអាស៊ាន (AMS) ចំនួន១០។ កម្មវិធីនេះមានគោលបំណងប្រយុទ្ធប្រឆាំងនឹងព័ត៌មានខុស និងព័ត៌មានមិនពិត ដោយធ្វើការបណ្តុះបណ្តាលអក្ខរកម្មឌីជីថលសម្រាប់យុវជន គ្រូបង្រៀន ឪពុកម្តាយ អ្នកដឹកនាំសហគមន៍ និងមន្រ្តីរដ្ឋាភិបាល។ម្យ៉ាងវិញទៀត ក៏មានការបញ្ចូលយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងដ៏ច្រើនដើម្បីធានាថា សារៈសំខាន់ប្រព័ន្ធផ្សព្វផ្សាយ និងអក្ខរកម្មព័ត៌មានគឺមានការយល់ដឹងកាន់តែច្បាស់ និងដល់អ្នកអានកាន់តែច្រើន និងជំរុញមនុស្សឱ្យក្លាយជាភ្នាក់ងារផ្លាស់ប្តូរព័ត៌មានគ្នា ដែលអាចជួយរកឱ្យឃើញ និងការពារការបោកបញ្ឆោត និងព័ត៌មានក្លែងក្លាយពីការផ្សព្វផ្សាយ។

យុទ្ធសាស្រ្តសំខាន់ដែលគម្រោងនេះប្រើប្រាស់គឺបណ្តុះបណ្តាលគ្រូបង្គោលចំនួន៨៥នាក់នៅគ្រប់កម្រិតក្នុងសង្គម ហើយឱ្យពួកគេជួយចែករំលែកកម្មវិធីសិក្សាអាស៊ានដែលរៀបចំឡើងដើម្បីលើកកម្ពស់សុវត្ថិភាពតាមអនឡាញទៅដល់ប្រជាជនកម្ពុជាជាច្រើននាក់ទៀត នៅពេលពួកគេត្រឡប់ទៅសហគមន៍ពួកគេវិញ។

## បច្ចុប្បន្នភាពគម្រោង

នៅពេលកម្មវិធី ADLP ឈានដល់ពេលបិទបញ្ចប់នៅចុងឆ្នាំ ខេប ត្រូវបានអញ្ជើញឱ្យចូលរួមក្នុងវេទិកាស្តីពីផលប៉ះពាល់អក្ខរកម្មឌីជីថលអាស៊ាននៅកោះបាលី ប្រទេសឥណ្ឌូនេស៊ី ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តំណាងឱ្យប្រទេសកម្ពុជា និងបង្ហាញពីផលជះគម្រោង និងឧត្តមានុវត្តន៍នៅក្នុងតំបន់។ ខេបត្រូវបានជ្រើសរើសជាដៃគូអនុវត្តដោយប្តេជ្ញាចិត្តក្នុងចំណោមរដ្ឋសមាជិកអាស៊ានទាំង១០ និងទទួលបានពានរង្វាន់ពិសេសពីមូលនិធិអាស៊ាន។ ធនធានកម្មវិធីអក្ខរកម្មឌីជីថលអាស៊ានទាំងអស់ត្រូវបានធ្វើមូលដ្ឋានីយកម្ម និងដាក់បង្ហោះនៅលើ digital class ASEAN platform (https://digitalclassasean.org/)។

សូមចុចតំណភ្ជាប់ខាងក្រោមដើម្បីស្វែងយល់បន្ថែមអំពីវេទិកាស្តីពីផលជះកម្មវិធី ADLP: https://www.phnompenhpost.com/business/asean-foundation-with-support-from-google-org-holds-asean-digital-literacy-programme-impact-forum-and-launches-digital-literacy-e-learning-platform




*អង្គការ ខេប ទទួលបានប័ណ្ណសរសើរនៅក្នុងអំឡុងពិធីពិព័រណ៍កម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន។*

## សកម្មភាពសំខាន់ៗ

- បានផ្តល់ការបណ្តុះបណ្តាលគ្រូបង្គោល (ToT) រយៈពេល២០ម៉ោងសម្រាប់គ្រូបង្គោលចំនួន៨៥នាក់ ស្តីពីអក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងឌីជីថល (MIDL)។
- គ្រូបង្គោលបានផ្តល់ការបណ្តុះបណ្តាលដំបូងស្តីពី MIDL ដល់អ្នកទទួលផលចុងក្រោយនៅក្នុងសហគមន៍ ឬស្ថាប័នគោលដៅរបស់ពួកគេ ដែលរួមមាន៖ យុវជន ចាស់ជរា គ្រូបង្រៀន ឪពុកម្តាយ និងក្រុមជនងាយរងគ្រោះផ្សេងទៀត។ រយៈពេលបណ្តុះបណ្តាលបន្តគឺប្រហែល៣ខែ។
- ការរៀបចំកម្មវិធីជួបជុំគ្រូបង្គោល។ នៅក្នុងផ្នែកមួយនៃកម្មវិធីនេះ គ្រូបង្គោលបានចែករំលែកអំពីឧត្តមានុវត្តន៍ បញ្ហាប្រឈម មេរៀនពិសោធន៍ក្នុងអំឡុងពេលសកម្មភាពបណ្តុះបណ្តាលបន្ត និងបានពិភាក្សាអំពីផែនការនឹងដំណោះស្រាយសម្រាប់ការអនុវត្តនាពេលអនាគត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីព័ត៌មានខុស និងព័ត៌មានមិនពិត និងវិធីសាស្រ្តដែលមានប្រយោជន៍សម្រាប់ការពារ។

## រូបភាពសកម្មភាព



*គ្រូបង្គោលដែលមកពីសាលារៀនរដ្ឋផ្សេងៗ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានចូលរួមសិក្ខាសាលាកម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន ដោយបង្ហាញជាលទ្ធផលឱ្យឃើញថាអក្ខរកម្មឌីជីថលគឺពិតជាមានភាពអស្ចារ្យណាស់សម្រាប់ពួកគាត់ ដើម្បីយកទៅបង្រៀនសិស្សបន្តអំពីរបៀបកំណត់ព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយ។*

## ផលជះគម្រោង

យ៉ាងហោចណាស់ មានគ្រូបង្គោលចំនួន៧៦នាក់ (៩០%) បានបើកការបណ្តុះបណ្តាលបន្តស្តីពី អក្ខរកម្មប្រព័ន្ធផ្សព្វផ្សាយ ព័ត៌មាន និងឌីជីថលដល់អ្នកទទួលផលក្នុងសហគមន៍ និងស្ថាប័នខ្លួននៅចន្លោះខែមករា ដល់ខែឧសភា ឆ្នាំ២០២៣។ គ្រូបង្គោលបានប្រើប្រាស់ធនធានកម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន (ឧ. ស្លាយធ្វើបទបង្ហាញ សៀវភៅណែនាំការបណ្តុះបណ្តាល ការធ្វើតេស្តដើមគ្រានិងចុងគ្រា ទម្រង់របាយការណ៍ បណ្តុះបណ្តាល។ល។) ដែលត្រូវបានរៀបចំយ៉ាងពេញលេញ និងបកប្រែជាភាសាខ្មែរ។ សកម្មភាពបណ្តុះបណ្តាលបានរៀបចំធ្វើឡើងដោយផ្ទាល់ និងតាមអនឡាញ ដើម្បីសម្រួលដល់ពេលវេលា ឬកាលវិភាគរបស់អ្នកទទួលផល ឬលទ្ធភាពរួមពួកគេ។ យ៉ាងហោចណាស់ សកម្មភាពបណ្តុះបណ្តាលនីមួយៗផ្តោតលើប្រធានបទ២ ដែលបានជ្រើសរើសចេញពីម៉ូឌុលសំខាន់ៗទាំង៤ ហើយមានរយៈពេលពី២ទៅ៤ម៉ោងក្នុងមួយវគ្គ។ ផ្អែកលើទម្រង់របាយការណ៍បណ្តុះបណ្តាលដែលគ្រូបង្គោលបានផ្តល់មក ការបណ្តុះបណ្តាលគ្រូបង្គោលនៅចុងគ្រាទាំងអស់ទទួលបានជោគជ័យដោយមានការចូលរួមប្រកបដោយប្រសិទ្ធផល មេរៀនបទពិសោធន៍ និងបានបង្ហាញការពេញចិត្តពីអ្នកចូលរួមការបណ្តុះបណ្តាលចុងក្រោយមានកម្រិតខ្ពស់។ ភាគច្រើននៃអ្នកទទួលផលផ្ទាល់គឺជាយុវជន ដែលមានចំនួ៩០% ក្នុងចំណោមសិក្ខាកាម ខណៈដែលចំនួន១០%ទៀត គឺជាគ្រូបង្រៀន ឪពុកម្តាយ ជនពិការ មនុស្សចាស់ និងក្រុមជនងាយរងគ្រោះ។

សកម្មភាពវិលជុំកម្មវិធីអក្ខរកម្មឌីជីថលអាស៊ាន គឺជាសកម្មភាពស្រាវជ្រាវដ៏សំខាន់មួយ ដែលស្វែងរកផែនការលម្អិតនៃគម្លាតអ្នកប្រើប្រាស់ឌីជីថលនៅក្នុងប្រទេសកម្ពុជា និងធ្វើអនុសាសន៍សម្រាប់វិនិយោគនាពេលអនាគត ដើម្បីផ្សារភ្ជាប់រវាងអ្នកប្រើនិងមិនប្រើឌីជីថល។

# កម្មវិធីអក្ខរកម្មឌីជីថលខ្មែរ (KDLP)



*'ធ្វើការលើកកម្ពស់ការអប់រំជំនាញឌីជីថលមូលដ្ឋាននៅមធ្យមសិក្សា''*

## ប្រវត្តិគម្រោង

| | |
|---|---|
| **ម្ចាស់ជំនួយ** | ក្រុមហ៊ុនមេតា |
| **អ្នកទទួលផលផ្ទាល់** | ៣ ០០០នាក់ |
| **ថវិកាឆ្នាំសិក្សា២០២៣** | ១២២.៨២០.០០០រៀល |
| **តម្លៃឯកតាក្នុងសិស្សម្នាក់** | ៤០.៩៤០រៀល |
| **ខេត្តគោលដៅ** | ៤ |
| **ស្រុកគោលដៅ** | ៤ |
| **សាលាមធ្យមសិក្សាគោលដៅ** | ៦ (សាលារៀនជំនាន់ថ្មី) |
| **កាលបរិច្ឆេទចាប់ផ្តើម** | ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ |
| **កាលបរិច្ឆេទបញ្ចប់** | ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ |

## គោលបំណង

KDLP គឺកម្មវិធីដែលមានការចូលរួមពីអង្គការ ខេប ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមហ៊ុនមេតា។ កម្មវិធីនេះមានគោលបំណងប្រើប្រាស់កម្មវិធីសិក្សា WeThinkDigital ឱ្យបានទូលំទូលាយ និងប្រើប្រាស់កញ្ចប់ធនធានរៀបចំដោយក្រុមហ៊ុនមេតាក្នុងឆ្នាំ២០១៩ និងធ្វើឱ្យត្រូវនឹងបរិបទប្រព័ន្ធអប់រំប្រទេសកម្ពុជា។ កម្មវិធីនេះបង្កើតឡើងដើម្បីជួយអភិវឌ្ឍជំនាញដែលចាំបាច់ក្នុងការបង្កើតបាននូវប្រជាជនឌីជីថលមានទំនួលខុសត្រូវលើជំនាញការគិតបែបស៊ីជម្រៅ ការយល់ដឹង និងការសន្ទនាតាមឌីជីថល។ KDLP ជាកម្មវិធីដែលមានរយៈ ពេល១ឆ្នាំ មានគោលបំណងលើកកម្ពស់ និងបង្កើនការយល់ដឹងពីកម្មវិធីសិក្សាស្តីពីព័ត៌មាន ការទំនាក់ទំនង និងបច្ចេកវិទ្យាសម្រាប់សិស្សកម្រិតមធ្យមសិក្សាបឋមភូមិនៅក្នុងសាលារៀនជំនាន់ថ្មី និងពង្រីកឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។ កម្មវិធីនេះនឹងផ្តល់ឱ្យសិស្សនូវជំនាញមូលដ្ឋានដែលពាក់ព័ន្ធអក្ខរកម្មឌីជីថលតាមរយៈវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាដោយប្រើប្រាស់កម្មវិធីសិក្សា WeThinkDigital។ កម្មវិធីនេះបានចាប់ផ្តើមកាលពីខែតុលា ឆ្នាំ២០២២មក និងត្រូវបិទបញ្ចប់នៅក្នុងខែមិថុនា ឆ្នាំ២០២៤ខាងមុខ។

## បច្ចុប្បន្នភាពគម្រោង

ក្នុងឆ្នាំ២០២៣ អង្គការ ខេប និងក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការជិតស្និតក្នុងការរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរ។ ពិធីសម្ពោធនេះទទួលបានការគាំទ្រហិរញ្ញវត្ថុពីក្រុមហ៊ុនមេតានៅសណ្ឋាគារ Hyatt Regency ភ្នំពេញ។ វត្ថុបំណងសំខាន់ៗក្នុងពិធីនេះរួមមាន៖ ១) ធ្វើការផ្សព្វផ្សាយជាផ្លូវការអំពីការប្រើប្រាស់ឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរក្នុងសាលារៀនជំនានថ្មី និងសាលារៀនគំរូ។ ២) បន្តពង្រឹងកិច្ចសហការដ៏រឹងមាំរវាងក្រុមហ៊ុនមេតា ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ ខេប ក្នុងការលើកកម្ពស់អក្ខរកម្មឌីជីថលដល់សិស្សក្នុងសាលារៀនជំនាន់ថ្មី។ ៣) លើកកម្ពស់ការអភិវឌ្ឍជំនាញឌីជីថលនៅសាលាមធ្យមសិក្សានានាក្នុងពេលអនាគតដ៏ឆាប់។ ដើម្បីសម្រេចបានគោលដៅខាងលើ ក្រុមហ៊ុនមេតាបានយល់ព្រមគាំទ្រដល់អង្គការ ខេប រហូតដល់ចុងឆ្នាំ២០២៤។ ការកែសម្រួលឯកសារបណ្តុះបណ្តាលបានបញ្ចប់រួចរាល់ក្នុងឆ្នាំ២០២៣ និងបានសាកល្បងដាក់ឱ្យប្រើប្រាស់នៅក្នុងសាលារៀនជំនាន់ថ្មីចំនួន៦ ដោយមានផែនការពង្រីកទៅកាន់សាលារៀនផ្សេងៗទៀតក្នុងឆ្នាំ២០២៤។




*(រូបពីឆ្វេងទៅស្តាំ)៖ លោក ហេង ភក្តី (តំណាងក្រុមហ៊ុនមេតាប្រចាំប្រទេស) លោកជំទាវ គឹម សេដ្ឋានី (រដ្ឋលេខាធិការក្រសួងអប់រំ) និងលោក សៅ វណ្ណា (នាយកប្រតិបត្តិអង្គការ ខេប) បានជួបប្រជុំបើកពិធីសម្ពោធកម្មវិធីអក្ខរកម្មឌីជីថលខ្មែរនៅសណ្ឋាគារ Hyatt Regency ភ្នំពេញ។*

## សកម្មភាពសំខាន់ៗ

- **ការវិភាគមាតិកា៖** ការវិភាគមាតិកាអក្ខរកម្មឌីជីថលដែលមានស្រាប់នៅក្នុងកម្មវិធីសិក្សា ICT នៃសាលារៀនជំនាន់ថ្មីធៀបនឹងកម្មវិធីសិក្សា WeThinkDigital។
- **ការបង្កើតក្រុមការងារបច្ចេកទេស៖** ក្រុមការងារបច្ចេកទេសត្រូវបានបង្កើតឡើងដើម្បីរៀបចំវគ្គសិក្ខាសាលាពិគ្រោះយោបល់ជាមួយនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានដើម្បីកែសម្រួលការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល។
- **ការត្រួតពិនិត្យ និងកែសម្រួលឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីល៖** គម្រោងបានជ្រើសរើសគ្រូផ្នែក ICT ចំនួន១២នាក់ និងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ចំនួន៤លើក និងការបណ្តុះបណ្តាលគ្រូបង្គោលចំនួនពីរលើកស្តីពីឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរដែលនឹងត្រូវបានប្រើប្រាស់សម្រាប់សិស្សថ្នាក់ទី៧-៩។
- **ការអនុវត្តសាកល្បងឯកសារបណ្តុះបណ្តាលឌីជីថល៖** ការអនុវត្តសាកល្បងឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរនៅសាលារៀនជំនាន់ថ្មីដែលបានជ្រើសរើសនៅក្នុងខេត្តចំនួន៤ផ្សេងៗគ្នា។
- **កិច្ចប្រជុំឆ្លុះបញ្ចាំង៖** គម្រោងបានរៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំងជាមួយគ្រូផ្នែក ICT សមាជិកក្រុមការងារបច្ចេកទេស និងអ្នកពាក់ព័ន្ធដើម្បីវិភាគអំពីអត្ថប្រយោជន៍ និងគម្លាតដែលមាននឹងត្រូវដោះស្រាយ។

## រូបភាពសកម្មភាព



*សិក្ខាកាមសំខាន់ៗនៅក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការកម្មវិធីអក្ខរកម្មឌីជីថលខ្មែរ ឈរជាមួយមន្ត្រីរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្រុមហ៊ុនមេតា និងអង្គការ ខេប នៅសណ្ឋាគារ Hyattt Regency ក្នុងរាជធានីភ្នំពេញ។*

## ផលជះគម្រោង

នៅខែធ្នូ ឆ្នាំ២០២៣ គ្រូ ICT សរុបចំនួន១២នាក់មកពីសាលារៀនជំនាន់ថ្មីចំនួន៦ ក្នុងខេត្តចំនួន៤ផ្សេងគ្នាបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ចំនួន៤លើក និងការបណ្តុះបណ្តាលគ្រូបង្គោលចំនួន២លើកស្តីពី ឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរ។ ក្នុងចំណោមម៉ូឌុលចំនួន៦នៃកម្មវិធីសិក្សា WTD មាន៤ម៉ូឌុល និង២៣មេរៀនបានកែសម្រួលខ្លឹមសារឱ្យសមស្របនឹងបរិបទប្រទេសកម្ពុជា ជាពិសេសនៅក្នុងសាលារៀនជំនាន់ថ្មី។ ឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរគ្របដណ្តប់លើទិដ្ឋភាពជាច្រើននៃការអប់រំបែបឌីជីថល ដូចជា ការណែនាំបែបទាក់ទាញពីការសិក្សាឌីជីថលក្នុងសតវត្សរ៍ទី២១ ជំនាញឌីជីថលមូលដ្ឋាន ការលើកកម្ពស់ការយល់ដឹងពីសុខមាលភាពឌីជីថល និងការចូលរួមបែបឌីជីថល។ ការជ្រើសរើសគ្រូ ICT នឹងប្រើប្រាស់ឯកសារបណ្តុះបណ្តាលជាចំបាច់ ឬក៏វគ្គបណ្តុះបណ្តាលកម្មវិធីសិក្សាបន្ថែមដើម្បីបង្រៀនសិស្សពីថ្នាក់ទី៧-៩ ទៅតាមសាលារៀនរៀងៗខ្លួនសម្រាប់រយៈពេល៥ខែ ចាប់ពីខែមករាដល់ឧសភា ឆ្នាំ២០២៤។ ឯកសារបណ្តុះបណ្តាលអក្ខរកម្មឌីជីថលខ្មែរ នឹងផ្តល់ឱ្យសិស្សនូវជំនាញឌីជីថលយ៉ាងសំខាន់ និងចំណេះដឹងអក្ខរកម្មឌីជីថលមូលដ្ឋាន ដែលនឹងឱ្យពួកគេរីកចម្រើនដោយសុវត្ថិភាព និងមានទំនុកចិត្តនៅក្នុងយុគសម័យឌីជីថលនេះ។ សិស្សប្រមាណ៣០០០នាក់ និងគ្រូបង្រៀនចំនួន២៤នាក់នឹងទទួលបានអត្ថប្រយោជន៍ពីកម្មវិធីនេះដោយផ្ទាល់។

ភាពជាដៃគូរវាងអង្គការ ខេប និងក្រុមហ៊ុនមេតា គឺជាយុទ្ធសាស្ត្រល្អមួយដែលជួយខេបឱ្យយល់ដឹងកាន់តែប្រសើរឡើងអំពីការវិវឌ្ឍនាពេលអនាគតក្នុងវិស័យឌីជីថល ព្រោះក្រុមហ៊ុនមេតាជាក្រុមបច្ចេកវិទ្យាដ៏ធំមួយ ដែលបានស្វែងយល់យ៉ាងស៊ីជម្រៅនឹងទិសដៅថ្មីក្នុងបច្ចេកវិទ្យា ដូចជា បញ្ញាសិប្បនិម្មិត។ អង្គការ ខេប សង្ឃឹមថានឹងទទួលបានអត្ថប្រយោជន៍ពីទំនាក់ទំនងនេះដើម្បីអភិវឌ្ឍនាពេលខាងមុខ ទាក់ទងនឹងកម្មវិធីអប់រំឌីជីថល។

# សេចក្តីសង្ខេបហិរញ្ញវត្ថុ

## សាច់ប្រាក់ និងការចំណាយ

| សេចក្តីពណ៌នា | ចំនួនទឹកប្រាក់ជារៀល(៛) |
|---|---|
| ចំណូលថវិកាសរុបក្នុងគម្រោងប្រចាំឆ្នាំ២០២៣ | ២០.៦៣០.៨៥៥.៨៦០,៥១ |
| សមតុល្យចុងគ្រាពីឆ្នាំ២០២២ | ៨៩០.២៨៥.០៩៥,៨៥ |
| ចំណូលការប្រាក់ | ៣២.៧៨៨.៣០៤,០៧ |
| ថវិកាដែលអាចប្រើប្រាស់បានក្នុងឆ្នាំ២០២៣ | ២១.៥៥៣.៩២៩.២៦០,៤៣ |
| សរុបថវិកាចំណាយប្រចាំឆ្នាំ២០២៣ | ១៨.៦៧៥.១២៦.៩២៧,២២ |
| អត្រាប្រើប្រាស់ថវិកា | ៨៧% |

## និន្នាការទទួលថវិកា




## តើថវិកាជំនួយត្រូវយកទៅប្រើប្រាស់ដូចម្តេច?




***សម្គាល់៖*** *អត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ២០២៣ គឺ ១ដុល្លារអាមេរិក = ៤.១១០៛ (និយ័តករគណនេយ្យនិងសវនកម្ម (ACAR))។*

## លំហូរចំណូលឆ្នាំ ២០២៣

| ម្ចាស់ជំនួយ | ចំនួនទឹកប្រាក់ជារៀល (៛) |
|---|---|
| ក្រសួងអប់រំ យុវជន និងកីឡា | ៧.៤៧៦.១៥០.០០០,០០ |
| មូលនិធិគីនចាន | ៧.២៣៧.៤២៦.០២៩,០០ |
| សហភាពអឺរ៉ុប | ១.៥៤៨.២២៧.៩០៨,៤២ |
| អង្គការឆាលហ្វានអាឡឺម៉ង់ | ១.១១៦.៩៩៣.៧៥១,១៨ |
| អង្គការឆាលហ្វានកម្ពុជា | ៧៩២.៥៦៤.៣៨៤,៥៣ |
| ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) | ៦២១.៥២០.០០៥,១៨ |
| អង្គការក្លែនអន្តរជាតិ | ៥៤៥.៦៣៥.៤២៣,១៦ |
| អង្គការយូនីសេហ្វ | ២៧៦.៣០២.៦២៧,១០ |
| អង្គការមូលនិធិអាស៊ី/យូនីសេហ្វ | ២៣០.៩៦៣.៧០១,០០ |
| អង្គការមូលនិធិអាស៊ី | ២០៣.៩៤៤.២១០,៩៤ |
| ទីភ្នាក់ងារ NOREC | ១៨៤.២៣០.០០០,០០ |
| អង្គការ WeWorld | ១៥២.១៩៦.១០០,០០ |
| ក្រុមហ៊ុន Meta | ១២២.៨២០.០០០,០០ |
| អង្គការយូណេស្កូ | ៦១.៤១០.០០០,០០ |
| មូលនិធិអាស៊ាន | ៦០.៤៧១.៧២០,០០ |
| ប្រាក់ចំណូលថ្មីក្នុងឆ្នាំ២០២៣ | ២០.៦៣០.៨៥៥.៨៦០,៥១ |

## សេចក្តីថ្លែងអំណរគុណ!

*ជូនសមុខឲ្យកុមារ គ្រូបង្រៀន ឪពុកម្តាយ និងក្រុមអ្នកទទួលផលទាំងអស់មកពីកម្មវិធីរបស់យើង អង្គការ ខេប សូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយទាំងអស់ដែលបានផ្តត់ផ្គង់ដល់កម្មវិធីខេបនៅក្នុងឆ្នាំនេះ និងឆ្នាំនាពេលកន្លងមក។ ការផ្តត់ផ្គង់ជំនួយហិរញ្ញប្បទានបានធ្វើឲ្យអង្គការខេប ផ្តល់នូវសេវាកម្មជូនអ្នកទទួលផលប្រកបដោយអត្ថន័យគ្រប់គ្រាន់។ សូមអរគុណ!*

# ថ្នាក់គ្រប់គ្រងអង្គការ ខេប ឆ្នាំ២០២៣

## ក្រុមប្រឹក្សាភិបាល


**ហ៊ាង គុយ**
ប្រធាន


**ប៊ុន រិទ្ធី**
អនុប្រធាន


**ធុច ថាត**
សមាជិក


**ហែម មណី**
សមាជិក


**ឯកឧត្តម ឆាយ ទីប៉ា**
សមាជិក


**ថន វ៉ាន់ដុង**
សមាជិក

## ក្រុមអ្នកគ្រប់គ្រងជាន់ខ្ពស់ ( SMT )


**សៅ វណ្ណា**
នាយកប្រតិបត្តិ


**ហ៊ិន ស៊ីមហួន**
នាយករងប្រតិបត្តិ និង
ប្រធានបច្ចេកទេស


**យីត ប្រាឌិនបើក**
ទីប្រឹក្សាបច្ចេកទេស
ជាន់ខ្ពស់


**មូ សម្បត្តិ**
នាយកគ្រប់គ្រង
ហិរញ្ញវត្ថុ


**ឈួន សារ៉ាន**
ប្រធានរដ្ឋបាល និង
ធនធានមនុស្ស


**ហ៊ឹម ម៉ារី**
ប្រធានសម្របសម្រួល
កម្មវិធីអប់រំបរិយាបន្ន


**អ៊ុល រុន**
ប្រធានកម្មវិធីសាលា
រៀនជំនាន់ថ្មី/ទីប្រឹក្សា
ជាតិជាន់ខ្ពស់


**ម៉ៃ សារិទ្ធិ**
អ្នកសម្របសម្រួល
បច្ចេកទេស និង
តស៊ូមតិ

## អ្នកដឹកនាំសំខាន់ៗរបស់អង្គការ ខេប


**បណ្ឌិតសភាចារ្យ ច័ន្ទ រ័ត្ន**
ប្រធានមជ្ឈមណ្ឌល **NGPRC**


**បណ្ឌិត ស៊ុន សុម៉ារ៉ា**
អ្នកសម្របសម្រួល
ការបណ្តុះបណ្តាល


**ពេជ្រ សុភឿន**
ប្រធានគម្រោង


**ស្លេះ តហៀត**
ប្រធានគម្រោង।


**អឿន បូរ៉ា**
ប្រធានគម្រោង


**មុំ ឡៃ**
ប្រធានគម្រោង


**នូ ស៊ីណាត**
ប្រធានគម្រោង


**ស សុផាណាក់**
អ្នកសម្របសម្រួល
ផ្នែកបច្ចេកវិទ្យាអប់រំ


**ផាន់ ប៊ុនណាត**
អ្នកសម្របសម្រួលការ
វាយតម្លៃទទួលស្គាល់
គុណភាពអប់រំ


**សែត សុលក្ខិណា**
អ្នកសម្របសម្រួល
កម្មវិធីអំណាន


**ទុំ ទីតូណា**
ប្រធានគម្រោង


**ស៊ុំ វណ្ណៈ**
ប្រធានបោះពុម្ពផ្សាយ
( ធីធីអូ )*


**ឡោក រដ្ឋា**
ប្រធានក្រុមដឹកនាំ
គម្រោង


**សំ ឡាដែត**
ប្រធានហិរញ្ញវត្ថុ


**កុល វណ្ណី**
ប្រធានគម្រោង


**ប៊ាន ចាន់នី**
អ្នកសម្របសម្រួល
មធ្យមសិក្សា ( NGS )


**ថាន ស្រីទី**
ប្រធានផ្នែកមូលនិធិ


**ផល សុវណ្ណធី**
អ្នកឯកទេស
គុណភាពអប់រំ


**វ៉ាន់ សុខសារៈ**
ប្រធានផ្នែក M&E


**អឿ សាវីន**
មន្ត្រីទំនាក់ទំនង
ជាន់ខ្ពស់


**ឈុន មួយលី**
ប្រធានក្រុមសាលារៀន
ជំនាន់ថ្មី ផ្នែកបឋម
សិក្សា ( NGS-PS)


**ស៊ឹម ផល្លី**
មន្ត្រីគាំពារកុមារ
និងយេនឌ័រ


**ស្ទេនីស្លាស កូវ៉ាលស្គី**
ទីប្រឹក្សាបច្ចេកទេស


**ប៉ៅឡា ម៉ាសា**
ទីប្រឹក្សាអប់រំ


**បណ្ឌិត ជីល ( យីឡា ) រ៉េមើរ**
ទីប្រឹក្សាបច្ចេកទេស


**បណ្ឌិត ម៉ុងតេឡូ ម៉ារីយ៉ា**
ទីប្រឹក្សាបច្ចេកទេស

*****_**សម្គាល់៖**_ *ធនធានអប់រំ (ធីធីអូ) គឺជាក្រុមហ៊ុនស្វយ័តសម្ព័ន្ធជាមួយអង្គការ ខេប។*

# រចនាសម្ព័ន្ធអង្គការ ខេប ក្នុងឆ្នាំ២០២៣




| | |
|---|---|
| AEOs | មន្ត្រីប្រមូលកុមារ និងទំនាក់ទំនងមាតាបិតា |
| ADLP | កម្មវិធីអក្សរកម្មឌីជីថលអាស៊ាន |
| AGPO | មន្ត្រីកម្មវិធីប្រមូលសិស្សរៀន និងអភិបាលកិច្ច |
| BfC | គម្រោងសៀវភៅសម្រាប់កម្ពុជា |
| CO | មន្ត្រីផ្នែកទំនាក់ទំនង |
| CCO | មន្ត្រីប្រឹក្សាអាជីព |
| CO-SAVED | គម្រោង សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម |
| DPO | មន្ត្រីកម្មវិធីថ្នាក់ស្រុក |
| DWD | កម្មវិធីអាហារូបករណ៍របស់កម្មវិធីអភិវឌ្ឍន៍ជំនាញការងារឌីជីថល |
| DTOs | មន្ត្រីបច្ចេកទេសថ្នាក់ស្រុក |
| E2L | គម្រោង ងាយស្រួលរៀន |
| EAO | មន្ត្រីផ្នែកប្រមូលកុមារចូលរៀន |
| EOs | មន្ត្រីអប់រំ |
| EQUAL | គម្រោងពង្រឹងគុណភាពអប់រំសម្រាប់កុមារក្រៅសាលានៅភូមិភាគឦសានក្នុងប្រទេសកម្ពុជា |
| FA | មន្ត្រីជំនួយការហិរញ្ញវត្ថុ |
| FO | មន្ត្រីហិរញ្ញវត្ថុ |
| FOSTER | គម្រោងសហគមន៍នៃសោធបង្កើត |
| | ការងារជាសេដ្ឋកិច្ចវិលជុំនៅបឹងទន្លេសាបភាគខាងលិច តំបន់១ |
| GES | មន្ត្រីគុណភាពអប់រំទូទៅ |
| HCC | គម្រោង កុមារកម្ពុជាវិការាយ |
| ICT in ES | មន្ត្រីជំនាញព័ត៌មានវិទ្យាសម្រាប់ការអប់រំ |
| ICTPO | មន្ត្រីកម្មវិធីបច្ចេកវិទ្យាព័ត៌មានសម្រាប់ការអប់រំ |
| IEP | កម្មវិធីអប់រំបរិយាបន្ន |
| IT&EWSO | មន្ត្រីព័ត៌មានវិទ្យា និងកម្មវិធីប្រព័ន្ធព្រមានទុកជាមុន |
| KDLP | កម្មវិធីអក្សរកម្មឌីជីថលខ្មែរ |
| KLS | គ្រូបង្រៀនភាសាខ្មែរ |
| LLSE | គម្រោងអប់រំបំណិនជីវិតមូលដ្ឋាន |
| LSLAG | គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី |
| M&E | ការតាមដាន និងវាយតម្លៃ |
| M&EA | អ្នកជំនួយការផ្នែកតាមដាន និងវាយតម្លៃ |
| M&EO | មន្ត្រីតាមដាន និងវាយតម្លៃ |
| MIDL | កម្មវិធីអក្សរកម្មប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មានឌីជីថល |
| MoEYS-LPD | កម្មវិធីអភិវឌ្ឍន៍ជាជីវៈភាពជាអ្នកដឹកនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពង្រីកភាពជាអ្នកដឹកនាំ និងសមភាពយេនឌ័រ |
| NAS | ទីប្រឹក្សាគម្រោង NGS (ទំនាក់ទំនងព័ត៌មានវិទ្យាសម្រាប់ការអប់រំ) |
| NGPRC | មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី |
| NGSI | គម្រោង សាលារៀនជំនាន់ថ្មី |
| NIO | មន្ត្រីអប់រំ ICT NGS |
| NOM | ប្រធានប្រតិបត្តិការគម្រោង សាលារៀនជំនាន់ថ្មី |
| QGOs | មន្ត្រីកម្មវិធីផ្នែកគុណភាព និងអភិបាលកិច្ច |
| PA | អ្នកជំនួយការកម្មវិធី |
| PC | មន្ត្រីសម្របសម្រួលថ្នាក់ខេត្ត |
| PED/DCD | នាយកដ្ឋានបឋមសិក្សា/នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| PO | មន្ត្រីកម្មវិធី |
| BMZ/REACH | គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពិសេសសហគមន៍/រីកផ |
| RC | អ្នកសម្របសម្រួលផ្នែកអំណាន |
| RT | គ្រូបណ្តុះបណ្តាលអំណាន |
| RTL | ប្រធានដឹកនាំក្រុមស្រាវជ្រាវ |
| SA | អ្នកសម្របសម្រួលសាលា (2) |
| SAC | មន្ត្រីប្រឹក្សាសាលារៀន |
| SCO | មន្ត្រីទំនាក់ទំនងជាន់ខ្ពស់ |
| SCOs | មន្ត្រីសហគមន៍ជាន់ខ្ពស់ (CIAI) |
| SEA | ជំនួយការអប់រំវិទ្យាសាស្ត្រ |
| SETL | ប្រធានក្រុមអប់រំវិទ្យាសាស្ត្រ |
| SGM | អ្នកប្រឹក្សាអភិបាលកិច្ចសាលារៀន (2) |
| SITO | មន្ត្រីបច្ចេកវិទ្យាព័ត៌មានវិទ្យាជាន់ខ្ពស់ |
| TL | ប្រធានក្រុម |
| TO | មន្ត្រីបណ្តុះបណ្តាល |
| USE-SDP2 | គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ |

ផ្នែកដឹកនាំ

↔ ព្រួញមុខពីរ = ទំនាក់ទំនងជាមួយទីប្រឹក្សា អ្នកសម្របសម្រួលអំណាន និងផ្នែកបច្ចេកវិទ្យាអប់រំ។

ប្រអប់ដាច់ៗ = ស្វយ័តភាពនៃគណៈកម្មការគ្រប់គ្រងមូលនិធិសុខភាពមានស្វយ័តភាពពេញលេញ។

** កម្មវិធីអប់រំបរិយាបន្ន (IEP) មាន៖ កម្មវិធីអាហារូបករណ៍របស់កម្មវិធីអភិវឌ្ឍន៍ជំនាញការងារឌីជីថល (DWD) គម្រោងអប់រំបំណិនជីវិតសម្រាប់កុមារី (LSLAG) ។ "POs" បង្ហាញអំពីមន្ត្រីទាំងអស់នៅក្នុងកម្មវិធី IEP។

*សូមបញ្ជាក់ថា លំដាប់ថ្នាក់ក្នុងរចនាសម្ព័ន្ធខាងក្រោមផ្នែកដឹកនាំ ប្រធានផ្នែកនីមួយៗមិនត្រូវបានបញ្ចូលទៅក្នុងផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស/រដ្ឋបាល ដែលបានកំណត់ហើយនៅក្នុងបញ្ជីឈ្មោះនោះទេ។